

ទស្សនៈពីខ្លួនគិមឆេង

នាយកសាលាបឋមសិក្សាវត្តបុព៌



រៀបរៀងដោយ

ស៊ឹម ឃុនៈ

ព. ស. ២៥៦៣ គ. ស. ២០២០

នៅជាមួយគ្នាចេះតែខុសឆាស់ ពេលបែកឃ្លាតអស់ទើបនឹកស្តាយក្រោយ

រក្សាសិទ្ធិ

ប្រវត្តិរបស់ខ្លួនដែលបានធ្វើការងារនៅសាលាបឋមសិក្សាវត្តបុព៌

ชื่อ ว. ชื่อนามสกุล

ตำแหน่ง / สังกัด ๑๑๑๑๑๑๑๑๑๑

๑๑ มีนาคม ๒๕๖๗

ขอแสดงความนับถือ อย่างสูง

เรียน ศาสตราจารย์ ดร. ชื่อ นามสกุล

๑๑๑๑๑๑๑๑๑๑

អារម្ភកថា

ខ្ញុំមានទឹកចិត្តរំភើបរីករាយក្រៃលែង ដែលមានឱកាសបានបញ្ចេញនូវទស្សនៈផ្ទាល់ខ្លួន តាមរយៈការសរសេរអត្ថបទខ្លីៗ ជាពាក្យកម្រងកែវ ដែលពាក្យទូន្មានខ្លះមាន ឬគ្មានចុងចួន ខ្លឹមសារទាំងនោះឆ្លុះបញ្ចាំងពីតថភាពសង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមទីជនបទស្រុកស្រែចម្ការ ទីក្រុងក្នុងសង្គមខ្មែរបច្ចុប្បន្ន។

ខ្ញុំសូមធ្វើការអភ័យទោសនូវរាល់កំហុសឆ្គង ដោយអចេតនានៃគំនិត និងការសរសេរនូវពាក្យពេចន៍ឃ្លោឃ្លោងទាំងឡាយណា ដែលមិនគប្បីសមរម្យទៅតាមអធ្យាស្រ័យរបស់ប្រិយមិត្ត លោកអ្នកអាន ហើយក៏រង់ចាំទទួលយកនូវការរិះគន់ស្ថាបនាកែលម្អ និងត្រៀមពន្យល់បកស្រាយ រាល់ការសាកសួរចម្ងល់ផ្សេងៗ ពីខ្លឹមសារអត្ថន័យក្នុងសៀវភៅនេះ ជូនមិត្តអ្នកអាននៅគ្រប់មជ្ឈដ្ឋាននានា បានយល់ជ្រាបច្បាស់ ដោយជ្រះថ្លា និងក្តីសោមនស្សរីករាយ។

សេចក្តីថ្លែងអំណរគុណ

ជាដំបូងខ្ញុំមានមោទនភាពរីករាយក្រៃលែង ដែលមានឱកាស រៀបចំគំនិតសរសេរនូវទស្សនៈឆ្លុះបញ្ចាំងពីជីវភាពពិត សង្គមពិតនាពេលបច្ចុប្បន្ន ដើម្បីជំនួយរំលឹកដាស់ស្មារតីដល់ជនប្រុសស្រីកំពុងសិក្សា និងប្រកបកិច្ចការ រកទទួលទានចិញ្ចឹមជីវិតជាប្រចាំថ្ងៃ។

ការសម្រេចបានលទ្ធផលបែបនេះបាន ដោយមានការគាំទ្រផ្តល់ឱកាស ពេលវេលាទំនុកបម្រុងជាកម្លាំងចិត្តយ៉ាងកក់ក្តៅបំផុតពីសំណាក់ឧត្តមភរិយា **ព្រាប-មនោរម្យ** កូនស្រី **ពឹង-ឆលីកា** កូនប្រុស **ពឹង-ឆលីហ៊ាង** ជាទីស្រឡាញ់។ លោកគ្រូ **ស៊ឹម-វតន:** ជួយបង្ហាញពីរបៀប និងរៀបចំនៃការចងក្រងអត្ថបទ។ លោកគ្រូ **សុន្ទរ៍-សាមៀន** ជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ។ លោកបណ្ឌិត **ឆាយ-ហុកផេង** ប្រទេសបារាំងដែលបានគាំទ្រលើកទឹកចិត្ត។ លោកស្រី **លុក-ប៊ុរី** ព្រមទាំងកូននៅប្រទេសបារាំង បានបរិចាគថវិកាចូលរួមចំណែកក្នុងការបោះពុម្ពសៀវភៅនូវទឹកប្រាក់ចំនួន ១,២០០ដុល្លារផងដែរ។

ខ្ញុំសូមឧទ្ទិសស្នាដៃទស្សនៈអប់រំនេះ សម្រាប់ជាគតិក្នុងជីវិតប្រចាំថ្ងៃ ជូនដល់កូនខ្មែរជំនាន់ក្រោយ បានជាប្រយោជន៍តរៀងទៅ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៣

សៀមរាប, ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២០

ពឹង~គិមឆេង

អាចារ្យអ្នកវៀបវៀង

ការអប់រំជាផ្នែកមួយដ៏សំខាន់បំផុតរបស់សង្គមមនុស្សយើង ដែលមិនអាចខ្វះបាន។ បើគ្មានការអប់រំហើយ ផ្នែកដទៃៗទៀតក៏នឹងសាបសូន្យទៅដែរ ព្រោះគ្មានការចេះដឹងនឹងបង្កើតនូវអ្វីដែលថ្មីៗបានឡើយ។ ហេតុដូច្នេះហើយ ទើបលោកនាយកសាលាបឋមសិក្សាវត្តបូពិ ខំពុះពារាល់ឧបសគ្គដើម្បីកែច្នៃសាលាមួយនេះ ឲ្យក្លាយទៅជាសាលាគំរូឈានមុខគេនៅក្នុងខេត្តសៀមរាប រហូតល្បីរន្ទឺទូទាំងប្រទេស មិនត្រឹមតែប៉ុណ្ណោះរហូតដល់បរទេសផងដែរ។ លោកនាយក **ពឹង-តិមរេន** មិនត្រឹមតែធ្វើឲ្យសាលា និងសិស្សានុសិស្សមានរបៀបវិន័យល្អប៉ុណ្ណោះទេ លោកបានទំនាក់ទំនងជាមួយភ្ញៀវជាតិ អន្តរជាតិឲ្យចូលមកទស្សនាថែមទៀត រហូតដល់ភ្ញៀវពេញចិត្ត គេជួយឧបត្ថម្ភជាសិក្ខូបករណ៍ និងថវិកាផ្សេងៗ ដើម្បីផ្គត់ផ្គង់ដល់សាលា ជាច្រើនទៀតផង។ ក្រៅពីពេលទំនេរ លោកនាយកខំប្រឹងស្រាវជ្រាវនូវចំណេះដឹងបន្ថែមទៀត ព្រមទាំងបានសរសេរជាពាក្យស្លោក សុភាសិតល្អៗបានបង្ហោះនៅក្នុងបណ្តាញសង្គម ដែលធ្វើឲ្យអ្នកចូលមើល ហើយសរសើរមិនដាច់ពីមាត់ នូវទឹកដៃដ៏មានអត្ថន័យរបស់លោក។ នៅពេលនោះដែរខ្ញុំក៏បានជួប និងសន្ទនាជាមួយលោកនាយក។ ក្នុងការសន្ទនាជាមួយលោកនាយកសាលានោះ គាត់បានផ្តល់ជាគំនិត និងទស្សនៈល្អៗ គួរយកមកប្រតិបត្តិដូចជា÷

ចតុស្តម្ភមេ មានបួនយ៉ាងគឺ **មេតិត, មេកែ, មេគុណ** និង**មេគុក**÷

១-មេតិត បានសេចក្តីថា ធម្មតាអ្នកដែលជាមេរបស់គេ ត្រូវគិតគ្រប់ជ្រុងជ្រោយទាំងអស់ ដើម្បីឲ្យបានសម្រេចជាលទ្ធផល ដែលផ្សាភ្ជាប់

ជាមួយនឹងការងារ។ **មេគិត** គ្រលាស់មកវិញថា **មិត្តគេ** ព្រោះមេត្រូវធ្វើខ្លួនឲ្យទៅជាមិត្តគេ ធម្មតាមេបើធ្វើខ្លួនជាមេគេ អ្នកដែលធ្វើការនៅក្រោមបង្គាប់ខ្លាចរអា ឯការងារមិនសូវរីកចម្រើនឡើយ បើធ្វើខ្លួនឲ្យទៅជាមិត្តរបស់គេវិញ ការងារទាំងអស់នឹងទៅដោយរលូន ព្រោះអ្នកក្រោមបង្គាប់គេធ្វើការងារដើម្បីមិត្តរបស់ខ្លួន មិនមានការកេងប្រវ័ញ្ចឡើយ។

២-មេកែ អ្នកដែលជាមេរបស់គេ គឺត្រូវចេះកែខ្លួនឯងឲ្យមានឫកពាសមរម្យ ចរិតថ្លៃថ្នូរ ហើយមើលការខុសត្រូវកូនចៅគ្រប់ជ្រុងជ្រោយ។ បើកូនចៅធ្វើខុសហើយ តែងចេះជួយកែតម្រូវឲ្យត្រឹមត្រង់ មិនឲ្យខុសលើកក្រោយៗទៀត ហើយក៏មិនមែនគិតតែពីចាប់កំហុសនោះទេ ព្រមទាំងចេះកែរាល់បញ្ហាដែលធំ ឲ្យទៅជាបញ្ហាតូច បញ្ហាតូចឲ្យទៅជាគ្មានបញ្ហា។ គឺធ្វើយ៉ាងម៉េច ដើម្បីឲ្យស្ថាប័ននោះរីកចម្រើនទាំងបរិមាណ និងគុណភាព ទើបឈ្មោះថា **មេកែ**។ **មេកែ** បើគ្រលាស់មកវិញ គឺម៉ែគេ ធម្មជាតិជាម៉ែតែងជួយទំនុកបម្រុងដល់កូនគ្រប់ពេលវេលា ស៊ូហ៊ានលះបង់អ្វីទាំងអស់ដើម្បីកូន មិនខ្លាចនឿយហត់ ឬបង់ទ្រព្យសម្បត្តិឡើយ ធ្វើយ៉ាងដូចម្តេចដើម្បីកូនរបស់ខ្លួនបាននូវសេចក្តីសុខ យ៉ាងណាមិញអ្នកដែលជាមេរបស់គេក៏ដូច្នោះដែរ។

៣-មេគុណ នៅទីកន្លែងណាក៏ដោយ បើមានការរីកចម្រើនបានក៏ដោយសារអ្នកគ្រប់គ្រងនៅទីនោះមានជំនាញ និងចេះរៀបចំបានល្អ។ ដូច្នេះកិត្តិយសរបស់មេ ត្រូវបានគេលើកតម្កើងទ្វេដង ឬបី ទៅឬនដងក៏មាន គេហៅថា **មេគុណ** គឺគេគុណនូវទង្វើល្អដែលបានធ្វើមក។ មេគុណនេះបានសេចក្តីទៀតថា បើកូនចៅធ្វើការងារម្តង មេត្រូវធ្វើពីរដង ឬបីដង រួចត្រួតពិនិត្យជាច្រើនដងទៀត ដើម្បីឲ្យការងារនោះបានច្បាស់លាស់។

បើសិនជាអាក្រក់វិញ រឿងអាក្រក់ រឿងអសោចរបស់មេ ត្រូវបានគេបកអាក្រាតទ្វេដង ឬច្រើនដងជាងកូនចៅទៅទៀត។ ពាក្យថា**មេគុណ**នេះ គឺជាសេចក្តីល្អរបស់មេទាំងឡាយ ត្រូវតែមានដល់កូនចៅ សំដៅដល់មាននាយកធម៌ទាំងប្រាំមួយគឺ មេត្រូវមានសេចក្តីអត់ធន់, មេត្រូវភ្ញាក់រឭកជាញឹកញាប់, មេត្រូវប្រឹងប្រែងព្យាយាម, ចេះចែករំលែកទ្រព្យសម្បត្តិ, អាណិតអាសូរ និងរំពៃមើលការខុសត្រូវ។ ពាក្យនេះបើគ្រលាស់មកវិញថា មុនគេបានសេចក្តីថា អ្នកដែលជាមេគេ ត្រូវធ្វើការអ្វីឲ្យបានមុនគេ ហ៊ានផ្តើមធ្វើអ្វីៗមុនគេ ដើម្បីជាគំរូដល់កូនចៅ គេនឹងធ្វើតាម។

៥-មេគុក ពាក្យថា **មេគុក** នេះបានសេចក្តីថា ធម្មតាសត្វលោកទាំងអស់ គឺជាប់ជំពាក់ទៅដោយអារម្មណ៍ផ្សេងៗ ព្រមទាំងជាប់ចំណងទាំងឡាយ ស្ទើរតែមិនអាចរើរួចឡើយ ដូច្នេះអ្នកដែលជាមេគេ ត្រូវត្រួតពិនិត្យនូវស្ថានភាពបួនយ៉ាងទៀតគឺ÷ **១-ជីវភាព** ថាតើបុគ្គលិកនោះមានប្រាក់បៀវត្សរ៍ យកទៅផ្គត់ផ្គង់ជីវភាពនៅក្នុងគ្រួសាររបស់គាត់បានធូរធារសមរម្យដែរឬទេ? **២-សុខភាព** អ្នកដែលជាមេគេត្រូវស្គាល់សុខទុក្ខមនុស្សក្រោមបង្គាប់ឲ្យបានច្រើន ថាតើបុគ្គលិកនោះមានសុខភាព និងរាងកាយមាំមួនដែរឬទេ? **៣-សុវត្ថិភាព** ថាតើបុគ្គលិកដែលមកធ្វើការគ្មានគ្រោះថ្នាក់នៅតាមផ្លូវ ឬក៏នៅកន្លែងការងារដែរឬទេ? **៤-គុណភាព** ភាពនៃគុណ, ដំណើរដែលមានគុណប្រយោជន៍ បានសេចក្តីថា របស់ដែលយើងបង្កើតឲ្យមានហើយ គឺត្រូវឲ្យមានទាំងបរិមាណ និងគុណភាព តែបើមានតែបរិមាណទេ វត្ថុទាំងអស់នោះរកសារៈគ្មានឡើយ ហេតុដូច្នេះហើយចំពោះលោកនាយកផ្ទាល់ លោកខំប្រឹងប្រែង គឺដើម្បីឲ្យសាលាមួយនេះ

មានគុណភាពទៅបាន លោកត្រូវដឹកនាំលោកគ្រូ អ្នកគ្រូឲ្យមានចំណេះដឹង និងចំណេះធ្វើ បើគ្រូណាមានត្រឹមតែសញ្ញាប័ត្រទុតិយភូមិ លោកឲ្យទៅរៀនយកបរិញ្ញាបត្រ បើមានបរិញ្ញាបត្រហើយឲ្យរៀនដល់អនុបណ្ឌិតបន្ថែមទៀត... **មេគុក** បើគ្រូលាស់មកវិញ គឺមុខគេ យើងជាមេគេត្រូវធ្វើអ្វីមុខគេជានិច្ច ត្រូវនាំគេប្រព្រឹត្តនូវអ្វីជាគំរូល្អដល់គេ និងជាប្រយោជន៍ឲ្យបានមុខគេ។ ពាក្យនេះ ហៅថា **ចតុស្តម្ភមេគុក** ក៏បាន។

កំណែទម្រង់សាលាបឋមសិក្សាវត្តឫស៊ី

លោកនាយកសាលា **ពឹង-គិមឆេន** បានជំនះរាល់ឧបសគ្គទម្រាំតែសាលាមួយនេះក្លាយជាសាលាគំរូ លោកបានធ្វើការកែតម្រូវ៤ចំណុចគឺ÷

១. ការធ្វើកំណែទម្រង់ដំបូងបំផុត តាំងពីទទួលតំណែងជានាយកសាលាបឋម ក្នុងឆ្នាំ១៩៩៤ លោកបានធ្វើកំណែទម្រង់ជាច្រើន ដែលមិនធ្លាប់មាន ដើម្បីផ្លាស់ប្តូរមុខមាត់ថ្មី ផ្តោតជាពិសេសទៅលើសណ្តាប់ធ្នាប់វិន័យ និងចក្ខុវិស័យសំខាន់ៗ របស់សាលាបឋមសិក្សាមួយនេះ។ ដំណើរការកែទម្រង់ដំបូង ពិតជាមានការលំបាក ដោយសារតែថ្នាក់លើទាំងខ្សែបណ្តោយ និងខ្សែទទឹងមិនយល់អំពីចក្ខុវិស័យរបស់សាលា។

២. កត្តាគ្រូបង្រៀន

លោកនាយកពឹង-គិមឆេន ប្រាប់ទៀតថា គ្រូបង្រៀននៅក្រោមបង្គាប់ទាំងអស់ បានបង្ហាញការមិនសប្បាយចិត្តចំពោះការរឹតបន្តឹងវិន័យដែលតឹងតែងខ្លាំង។ គ្រូបង្រៀនក្នុងសាលាស្ទើរគ្រប់គ្នាយល់ថាប្រាក់ខែ

គ្រូមានកម្រិតដូចៗគ្នាទេ ចុះហេតុអ្វីចាំបាច់ត្រូវធ្វើឲ្យល្អជាងគេយ៉ាងនេះ? ដូច្នេះហើយទម្រាំឲ្យគោលបំណង និងចិត្តគំនិតរបស់លោកជ្រាបដល់បេះដូងអ្នកគ្រប់ៗគ្នា គឺមិនមែនជារឿងងាយស្រួលឡើយ ទម្រាំតែអ្វីៗចាប់ផ្តើមដំណើរការទៅមុខទៀត។

៣. <u>កត្តាឪពុកម្តាយ</u>

នាយកសាលាដែលទទួលបានការវាយតម្លៃកម្រិតស្តង់ដារខ្ពស់ប្រចាំប្រទេសរូបនេះបន្តថាបញ្ហាមួយទៀតនោះគឺមាតាបិតានិងអាណាព្យាបាលរបស់សិស្ស។ មាតាបិតាសិស្សមួយចំនួនមិនទាន់យល់ និងមិនដែលជួបប្រទះចំពោះការរឹតបន្តឹងវិន័យ សណ្តាប់ធ្នាប់របស់សិស្ស។ ដូច្នេះហើយទើបពួកគាត់បានបញ្ចេញនូវប្រតិកម្មយ៉ាងខ្លាំងនាពេលនោះ។ ប៉ុន្តែនាពេលបច្ចុប្បន្នមានមាតាបិតាសិស្សតិចណាស់ ដែលប្រតិកម្មដោយភាគច្រើនឪពុកម្តាយរបស់សិស្សានុសិស្សទាំងអស់ បានបង្ហាញការគាំទ្រចំពោះការរៀបចំរបស់សាលាទៅវិញ។

៤. <u>កត្តាគ្រួសាររបស់លោកផ្ទាល់</u>

ក្រោយមានប្រតិកម្មច្រើនពីលោកគ្រូ អ្នកគ្រូ និងអាណាព្យាបាលរបស់សិស្ស គ្រួសាររបស់លោកនាយក **ពីច-តិមឆេង** មិនជាសប្បាយចិត្តប៉ុន្មាននោះទេ។ មួយវិញទៀតនោះ អ្នកផ្ទះរបស់លោកមិនសប្បាយចិត្តឡើយចំពោះអ្វីដែលលោកបានអនុវត្ត ព្រោះបានចំណាយពេលច្រើនលើការងារ ព្រលឹមចេញ ព្រលប់ចូល ស្ទើរតែរាល់ថ្ងៃ តែទទួលបានមកវិញនូវការប្រតិកម្មជាច្រើនទៅវិញនោះ។ ទោះជាយ៉ាងណាក្តីនាយកសាលារូបនេះឲ្យដឹងថា ទោះជាត្រូវប្រឹងប្រែងដើរទៅមុខដោយលំបាកក្តី ក៏ប៉ុន្តែ

លោកបានជំនះលើព្យុះធំទាំង៤នេះរួចរាល់ហើយ។ រហូតមកដល់ពេលបច្ចុប្បន្ន ការតស៊ូលំបាកប្រឹងប្រែងគ្រប់បែបយ៉ាងក៏ទទួលបានលទ្ធផលយ៉ាងគាប់ប្រសើរបំផុត។ លោកនាយកបានបន្តទៀតថា÷

-ថ្ងៃព្រហស្បតិ៍ឱ្យកូនសិស្សរៀនដូចធម្មតា ជ្បិតសាលាស្អាតជានិច្ចស្អាតរាល់ពេល គ្មានសំរាមមួយទង។

-គ្រូបង្រៀនគ្មានលក់នំក្នុងថ្នាក់។

-កូនសិស្សត្រូវធ្វើសមាធិយ៉ាងហោច៥នាទីរៀងរាល់ថ្ងៃ... ទាំងនេះគឺជាស្នាដៃខ្លះៗតែប៉ុណ្ណោះរបស់លោកពឹង-គិមឆេន នាយកសាលាបឋមសិក្សាវត្តបូពិ ក្នុងក្រុងសៀមរាប។ លោកមានបទពិសោធបង្រៀន និងដឹកនាំសាលាប្រមាណ៤ទសវត្សរ៍មកហើយ, លោកគ្រូពឹង-គិមឆេន បានទទួលរង្វាន់លេខ១ "នាយកសាលាល្អ" ដែលជាពានរង្វាន់របស់ប្រមុខរដ្ឋាភិបាលនិងផ្តួចផ្តើមដោយរដ្ឋមន្ត្រីសិក្សាធិការជាតិ។ វ័យ៦០ឆ្នាំ នាយកល្អរូបនេះរម្លឹកប្រវត្តិក្នុងសំនៀងរដិនបែបអ្នកសៀមរាបថា លោកចូលបង្រៀន តាំងពីឆ្នាំ១៩៨០ គឺតាំងពីបង្រៀនគ្មានប្រាក់ខែ បង្រៀនដូរអង្ករ ជ្បិតកម្ពុជាក្រីក្រទើបតែងើបវារចេញពី "នរកខ្មែរក្រហម"។ លោកថ្លែងបន្តដោយរក្សាកែវភ្នែកភ្លឺថ្លា÷ "ខ្ញុំធ្លាប់លំបាក ខ្ញុំមិនចង់ឃើញកូនខ្ញុំ និងកូនខ្មែរលំបាកដូចខ្ញុំទៀតទេ"។ លោកគ្រូ និងភរិយា មានបុត្តពីរនាក់។ បុត្រីច្បងជាគ្រូពេទ្យ និងកូនប្រុសពៅជាអ្នកច្បាប់។ នៅសល់ពេលមិនច្រើនទៀតទេ ដែលនាយកសាលាល្អរូបនេះនឹងត្រូវចូលនិវត្តន៍។ ក្នុងការដឹកនាំសាលាបឋមសិក្សា រហូតក្លាយជាសាលាគំរូថ្នាក់ជាតិ, លោក**ពឹង-គិមឆេន** បានរក្សាគោលការណ៍ "១មិន ៥មាន"។ "១មិន" គឺមិនអាត្មានិយម ហើយ "៥

មាន" គឺមានឆន្ទៈ, មានក្តីអត់ធ្មត់, មានសេចក្តីព្យាយាម, មានភាពស្មោះត្រង់ និងមានការលះបង់។ ចំពោះការអប់រំកុមារតូចៗរៀងរាល់ថ្ងៃ គឺលោកនាយកសាលាប្រឹងណែនាំបុគ្គលិកសិក្សា យកចិត្តទុកដាក់បង្រៀនឱ្យមានគុណភាព, ឱ្យកូនសិស្សមានចំណេះដឹង និងចំណេះធ្វើ។ ថែមពីនេះត្រូវបង្រៀនឱ្យមានវិន័យបច់ថ្លៃថ្នូរ, មានអនាម័យ និងមានសុខភាពល្អ។ បន្ទាប់ពីសន្ទនារួចមក គាត់ក៏បានពឹងឱ្យខ្ញុំជួយរៀបរៀងសៀវភៅទស្សនៈដែលបានបង្ហោះនៅក្នុងហ្វេសប៊ុក មានជាច្រើនទស្សនៈ និងឯកសារជាសៀវភៅផងដែរ ខ្ញុំក៏បានយកមកធ្វើដោយយកចិត្តទុកដាក់ គឺរៀបតាមលំដាប់អក្សរពី ក ដល់ ឣ រហូតដល់ចប់ និងរៀបចំបោះពុម្ពក្នុងដើមឆ្នាំ២០២០នេះ។

សៀវភៅនេះមានសារប្រយោជន៍សំខាន់ដែរ សម្រាប់អ្នកយកទៅប្រតិបត្តិ ហើយក៏អាចជ្រើសរើសសុភាសិតណាដែលខ្លួនពេញចិត្តយកទៅអនុវត្តិ ឬក៏ដាក់ជាបដាធំៗ ដើម្បីឱ្យជនានុជនអានយកជាចំណេះដឹង ក៏ជាការល្អ សម្រាប់កូនខ្មែរយើងជំនាន់ក្រោយ។

ថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព. ស. ២៥៦៤

សៀមរាប, ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០

ស៊ឹម ៸រតនៈ

ប្រវត្តិរូបសង្ខេប

I. ប្រវត្តិផ្ទាល់ខ្លួន

ខ្ញុំបាទឈ្មោះ **ពីច-តិមឆេង** ភេទប្រុស សញ្ជាតិកម្ពុជា ជនជាតិខ្មែរ

ថ្ងៃខែឆ្នាំកំណើត÷ ថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៦១

ទីកន្លែងកំណើត÷ ភូមិវត្តស្វាយ ឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប។

ទីលំនៅបច្ចុប្បន្ន÷ ភូមិផ្លូកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។

-កម្រិតវប្បធម៌÷ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង (អនុបណ្ឌិត)។

-កម្រិតជំនាញ÷ ក្របខណ្ឌគ្រូកម្រិតមូលដ្ឋាន។

-ស្ថានភាពគ្រួសារ÷ ឪពុកឈ្មោះ **ពីច-ឃក់ឆ** (ប៉ុលពតសម្លាប់)។ ម្តាយឈ្មោះ **សំ-ឈួម** (ស្លាប់)។ ប្រពន្ធឈ្មោះ **ព្រាប-មនោរម្យ** ឆ្នាំកំណើត ៣/៥/១៩៦៥ មុខរបរមេផ្ទះ។ កូន២នាក់ **១.ពីច-ឆលីកា** ភេទស្រី (មានប្តី) មុខរបរគ្រូពេទ្យ (វេជ្ជបណ្ឌិត) បច្ចុប្បន្នរស់នៅរាជធានីភ្នំពេញ។ **២.ពីច-ឆលីហ៊ាង** ភេទប្រុស (នៅលីវ) មុខរបរមន្ត្រីក្រសួងពាណិជ្ជកម្ម បច្ចុប្បន្នរស់នៅរាជធានីភ្នំពេញ។

II.ប្រវត្តិសិក្សា

នៅឆ្នាំ ១៩៦៧ រៀននៅសាលាបឋមសិក្សាវត្តស្វាយ (សៀមរាប)។ ១៩៧២ រៀននៅអនុវិទ្យាល័យអង្គរ (សៀមរាប)។ ១៩៨០វិក្រិតការគ្រូ

បង្រៀន(បំប៉នវគ្គខ្លី១៥ថ្ងៃ)។ ១៩៨៣ វិក្រិតការគ្រូបង្រៀន(បំប៉នវគ្គមធ្យម ៣ខែ)។ ១៩៨៥ វគ្គបំពេញរបមន្ត៧+១ (សញ្ញាបត្រថ្នាក់មធ្យមឯកទេស)។ ១៩៩៧ វគ្គបំប៉នការអប់រំបរិស្ថាននៅកម្រិតបឋមសិក្សា (វិញ្ញាបនបត្រ)។ ២០០១វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងសាលារៀនផ្អែកលើព័ត៌មាន វិញ្ញាបនបត្របញ្ជាក់ដោយក្រសួងអប់រំយុវជន និងកីឡា សហការដោយ UNICEF/Sida)។ ២០០៥ វគ្គបំប៉ននាយកសាលាបឋមសិក្សា (វិញ្ញាបន-បត្របញ្ជាក់ការសិក្សា)២០០៥ វគ្គបណ្តុះបណ្តាលមុខជំនាញកុំព្យូទ័រ(វិញ្ញា-បនបត្របញ្ជាក់ការសិក្សា)។ ២០០៨រៀននៅសកលវិទ្យាល័យចម្រើនពហុ បច្ចេកវិទ្យា(បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាល)។

សាធារណៈ (អនុបណ្ឌិត)

២០១០ វគ្គបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាននៅសាលគរុកោសល្យ ភូមិភាគបាត់ដំបង។(បរិញ្ញាបត្រគ្រូបង្រៀនកម្រិតមូលដ្ឋាន)។ ២០១៦ វគ្គ បណ្តុះបណ្តាល ស្តីពីការបញ្ជាបការ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (វិញ្ញាបនបត្របញ្ជាក់ការសិក្សាចេញដោយក្រសួងអប់រំយុវជន និងកីឡា)។

III.ប្រវត្តិការងារ

ថ្ងៃទី២៤ កញ្ញា ១៩៨០ ចូលបម្រើការជាគ្រូបង្រៀន (ត្រៀម)។ ថ្ងៃទី០២ មីនា ១៩៨២ បម្រើការគ្រូបង្រៀន (តែងតាំងស៊ប់)។ ឆ្នាំ១៩៨២ ដល់១៩៨៤ ជាគ្រូបង្រៀន និងជានាយកសាលាបឋមសិក្សាក្រសាំងរលើង (ស្រុក/ខេត្តសៀមរាប)។ ឆ្នាំ១៩៨៤ដល់១៩៨៨ ជានាយករងអប់រំសង្កាត់ លេខ៣ ទីរួមខេត្តសៀមរាប (ទទួលបន្ទុកអក្ខរកម្ម)។ ឆ្នាំ១៩៨៨ ដល់ ១៩៩១ ជាជានាយកអប់រំសង្កាត់លេខ៣ ទីរួមខេត្តសៀមរាប។ ឆ្នាំ១៩៩១

ដល់១៩៩៣ ជានាយកសាលាបឋមសិក្សាកេសរារាម (ស្រុកសៀមរាប)។ ឆ្នាំ ១៩៩៣ដល់២០១៨ ជានាយកសាលាបឋមសិក្សាវត្តបូពិ (ក្រុសៀមរាប)។

IV.ស្នាដៃការងារ

១/ស្នាដៃបុគ្គល÷

ឆ្នាំ២០០៧ ប្រកាសនីយប័ត្រ គ្រឿងឥស្សរិយយសមេដាយការងារ ថ្នាក់មាស។ ឆ្នាំ២០១៣ ប្រកាសនីយប័ត្រគ្រឿងឥស្សរិយយសមេដាយ ការងារថ្នាក់មាស។ ឆ្នាំ២០១៥ ប្រកាសនីយប័ត្រ ពានរង្វាន់សម្តេចតេជោ សែន នាយកល្អចំណាត់ថ្នាក់លេខ១។ ឆ្នាំ២០១៥ ពានរង្វាន់ WAT BO PRIMARY SCHOOL, SIAM REAP CAMBODIA ASEAN ECO-SCHOOLS AWARD 2015 Primary School Category។ ឆ្នាំ២០១៥ លិខិតសរសើរប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តសៀមរាប។ ឆ្នាំ២០១៦ ប្រកាសនីយប័ត្រ គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ។ ឆ្នាំ ២០១៦ ប័ណ្ណសរសើររដ្ឋមន្ត្រីក្រសួងបរិស្ថានជូននាយកសាលាគំរូ ដែល មានស្នាដៃល្អក្នុងការបញ្ជាបចំណេះដឹងបរិស្ថាន។ ឆ្នាំ២០១៧ ប្រកាស-នីយប័ត្រគ្រឿងឥស្សរិយយសមេដាយការងារបារាំងថ្នាក់មាស។

២/ស្នាដៃអង្គភាព÷

ឆ្នាំ២០១៦ ប្រកាសនីយប័ត្រកិត្តិយសកម្មវិធីមហោស្រពតន្ត្រី និង ចម្រៀងកុមារ ២០១៦ ដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន។ ២០០២ ប័ណ្ណសរសើរ (ចំណាត់ថ្នាក់លេខ១) រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា។ ២០០៦ ទង់ជ័យលាភីថ្នាក់លេខ២ ដោយរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា។ ២០០៩ ប័ណ្ណសរសើរ (ចំណាត់ថ្នាក់លេខ១) រដ្ឋមន្ត្រីក្រសួងអប់រំយុវជន

និងកីឡា។ ២០១១ ទង់ជ័យលាភីថ្នាក់លេខ១ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា។ ២០១៤ ប័ណ្ណសរសើរ (សុខភាពអនាម័យ) ក្រសួងអប់រំយុវជននិងកីឡា/ក្រសួងសុខាភិបាល។ ២០១៦ ប័ណ្ណសរសើរដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន។ ២០១៧ វិញ្ញាបនបត្រទទួលស្គាល់ (ការអនុវត្តស្តង់ដាសាលាស្អាត) រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

V.ប្រវត្តិនៃសាលាកិច្ចសិក្សា

ប្រទេសថៃចំនួន១៥ដង។ ប្រទេសកូរ៉េចំនួន២ដង។ ប្រទេសជប៉ុនចំនួន៥ដង។ ប្រទេសម៉ាឡេស៊ីចំនួន១ដង។ ប្រទេសមីយ៉ាម៉ាចំនួន១ដង។ ប្រទេសសេនីកាល់ចំនួន១ដង (ទ្វីបអាហ្វ្រិច)។

VI.បទពិសោធន៍

ដើម្បីដឹកនាំអង្គភាពមានការអភិវឌ្ឍដូចបច្ចុប្បន្នយើងបានចំណាយពេលវេលា២៤ឆ្នាំកន្លងផុតទៅ ប្រកបដោយការលំបាក ក្នុងការដឹកនាំផ្លាស់ប្តូរនូវផ្នត់គំនិតរបស់សហគមន៍ ចូលរួមចំណែកកសាងវិស័យអប់រំឲ្យមានការយល់ដឹងពីអត្ថប្រយោជន៍នៃការសិក្សាសម្រាប់អនាគតកូនចៅជំនាន់ក្រោយ។ បទពិសោធន៍ជាក់ស្តែង ដែលត្រូវបានយកមកអនុវត្តន៍កន្លងមកនោះរួមមាន÷

១/ការសិក្សាស្ថានភាពសហគមន៍

សីក្សាពីជីវភាពគ្រួសារ និងសិក្សាពីតម្រូវការទីផ្សារ (តម្រង់ទិសដៅបច្ចុប្បន្ន និងអនាគត)។

២/គោលនយោបាយ

ក/ គោលនយោបាយក្រសួង÷

សិក្សាស្វែងយល់ពីគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡាជាគោល ដើម្បីរៀបចំគោលនយោបាយរបស់សាលារៀន ស្របតាមគោលនយោបាយរបស់ក្រសួង។

ខ/ គោលនយោបាយសាលារៀន

គុណភាពបង្រៀន និងរៀនសូត្រ, សុខភាពអនាម័យ, ឥរិយាបថ (សុជីវធម៌ សីលធម៌ គុណធម៌)។

៣/ ចក្ខុវិស័យ

ការថែរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់, ការគាំពារសុខភាពសិស្សគ្រូ, បង្រៀន និងរៀនឲ្យមានចំណេះដឹង ចំណេះធ្វើ ឥរិយាបថល្អ និងចេះរួមរស់ដោយសុខដុម។ លើកស្ទួយជីវភាព និងសមត្ថភាពចំណេះដឹងទូទៅ និងជំនាញគ្រូបង្រៀនឲ្យកាន់តែប្រសើរ។

៤/ យុទ្ធសាស្ត្រអប់រំ (ប្រមូលកម្លាំងអប់រំ) ដើម្បីសម្រេចបានជោគជ័យនៃការអប់រំ សាលារៀនមិនអាចខ្វះការចូលរួមពីសំណាក់ភូមិ និងវត្តបានឡើយ។ ដូច្នេះភាពជោគជ័យក្នុងការអប់រំទៅបាន គឺអាស្រ័យដោយមានធនធានអប់រំពីគ្រួសារ គ្រូបង្រៀន និងសាសនា ជាកម្លាំងចលករយ៉ាងសំខាន់ដែលមានតួនាទីជាអ្នកអប់រំ។

៥/ <u>យុទ្ធវិធីការអប់រំ</u> (សមាសភាគអប់រំ៥)

ក-ការអប់រំបញ្ញា, ខ-ការអប់រំកាយ, គ-ការអប់រំសិល្បៈ, ឃ-ការអប់រំពលកម្ម, ង-ការអប់រំសោភ័ណ។

៦/ ការទំនាក់ទំនងជាតិ អន្តរជាតិ

-ការទំនាក់ទំនង គឺមិនអាចកាត់ផ្តាច់ពីការអភិវឌ្ឍបានឡើយ ជាពិសេសការទំនាក់ទំនងជាមួយសហគមន៍ គឺជាកត្តាគន្លឹះ និងចម្បងដែលអាចទាក់ទាញ មជ្ឈដ្ឋានខាងក្រៅមកចូលរួមអភិវឌ្ឍន៍ទាំងធនធានមនុស្ស ថវិកា សម្ភារបរិក្ខារ ផ្សេងៗផងដែរ។

៧/ <u>លក្ខណៈសម្បត្តិអ្នកដឹកនាំ</u>

ចំណេះដឹងពិតសមល្អម (ទាបបំផុតបរិញ្ញាប័ត ចេះយ៉ាងតិច២ ភាសា និងចេះ ប្រើ ICTបាន។ ឥរិយាបថថ្លៃថ្នូរ (សុជីវធម៌ សីលធម៌ គុណធម៌ប្រសើរ), ស្មារតីលះបង់ កម្លាំងកាយចិត្ត ថវិកា ទ្រព្យធន និងចេះចែករំលែក, ការសម្រេចចិត្តចំគោលដៅ, ធ្វើកិច្ចការមុនទទួលផលក្រោយធ្វើជាគំរូល្អ ភាពធ្វើជាម្ចាស់ (ការទទួលខុសត្រូវ), ស្មោះត្រង់ មិនពុករលួយកេងប្រវ័ញ្ច, យុត្តិធម៌ គ្មានការស្អប់ស្រឡាញ់, បង្កបរិយាកាសសប្បាយៗ។

៨/ រក្សាគុណតម្លៃនៃការអប់រំ

ផ្តល់ទំនុកដល់មាតាបិតាដែលប្រើប្រាស់សេវា, ខិតខំបំពេញភារកិច្ចអស់ពីសមត្ថភាព, រក្សាសមធម៌ក្នុងការសិក្សា, ជៀសវាងការកេងប្រវ័ញ្ច និងពុករលួយ, ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវក្រមសីលធម៌គ្រូបង្រៀន។

៩/ ប្រភពចំណូល គ្រប់គ្រងនិងប្រើប្រាស់ថវិកា

គ្រប់គ្រងថវិកាដោយតម្លាភាព (គណៈកម្មការគ្រប់គ្រង), ប្រើប្រាស់ថវិកាចំគោលដៅ និងមានប្រសិទ្ធភាព, ប្រភពចំណូលថវិកាដោយស្ម័គ្រចិត្តសប្បុរសធម៌។

១០/ទិសដៅ

ត្រៀមបង្កើតជាសាលាកម្រិតមូលដ្ឋាន (ពង្រឹងចំណេះដឹងដល់៩ឆ្នាំ), ត្រៀមសាងសង់អាហារដ្ឋានទំនើប (សុខភាព អនាម័យ), ការហ្វឹកហ្វឺនអប់រំវិរិយាបថសិស្ស(សុជីវធម៌ សីលធម៌ គុណធម៌) ក្លាយជាមនុស្សពិត។

ពុទ្ធភាសិត

សុខំ សុបតិ ពុទ្ធោ ច យេន មេត្តា សុភាវិតា

បុគ្គលអ្នកចម្រើនមេត្តាល្អហើយ រមែងដេក និងក្រោកឡើងជាសុខ។

ក ~ ក

*កតញ្ញូជាធម៌ល្អពិត
កម្រជីវិតលំឱនតាម។

*កត្តាជោគជ័យមិនស្ថិតត្រឹមទ្រឹស្តីថា
ត្រូវគិតវិចារពីហេតុការណ៍ផលជាក់ស្តែង។

*កត្តានាំឲ្យជោគជ័យប្រាកដ
គឺអំណត់អត់ធ្មត់ដោយព្យាយាម។

*កន្លែងណាក៏ជាសាលារៀន
ព្រោះវិជ្ជាមាននៅជុំវិញប្រាណ។

*កម្តៅថ្ងៃមិនអាចប្រល័យ
កម្តៅនិស្ស័យនៃឆន្ទៈ។

*កម្រិតនៃការដឹកនាំជោគជ័យ
ពឹងលើតម្លៃលទ្ធផលជាក់ស្តែង។

*កាន់សីលមានន័យថា
កាយវាចាចិត្តប្រព្រឹត្តល្អជាប្រចាំ។

*កាយនឿយហត់ចិត្តអត់ធ្មត់នឹងធឹង
គឺជាព្រលឹងប្ងូរយកតម្លៃ។

*ការកើតមានរឿងក្តីជម្លោះ
ព្រោះគូឈ្លោះគ្មានអធ្យាស្រ័យ។

*ការកែចរិតមនុស្សពាល
ប្រៀបដូចប្រមៀលថ្មឡើងភ្នំ។

*ការខឹងក្រោធ
នាំឲ្យខូចប្រយោជន៍ដល់អាត្មា។

*ការខឹងក្រោធ
នាំឲ្យអសោចនៅក្នុងសន្តាន។

*ការខំព្យាយាមជួយដោយខ្លួនឯង
មិនសូវគិតខ្ជិលក្រែងដូចពឹងគេជួយ។

*ការខ្ជះខ្ជាយជាកម្មសម្ភាយ
ព្រោះតែមិនងាយកែចរិត។

*ការគិតច្រើន
នាំបង្កើនកោសិកា។

*ការគិតធ្វើទទួលលទ្ធផលអស្ចារ្យ
ទើបជាផ្លែផ្កានៃមនុស្សជោគជ័យ។

*ការគិតបានបង្កើនកោសិកា
ជាផលផ្លែផ្កាបញ្ញាស្មារតី។

*ការគិតប្រកបដោយបញ្ញា
ធ្វើឲ្យកិច្ចការបានសម្រេច។

*ការគិតឥតខ្ចោះនៅមានធ្ងន់ធ្ងាយ
ទម្រាំគិតងាយអន្តរាយរិតធំ។

*ការគ្មានគំនិតព្រោះមិនបានព្យាយាមសិក្សា
ចិត្តចាំឥស្សាប្រមាទថាគេមិនស្មើអញ។

*ការគ្រប់គ្រងបុគ្គលិកមានរបៀប
ទើបប្រសិទ្ធភាពការងារប្រសើរ។

*ការគ្រប់គ្រងសំរាមនៅក្នុងធុងបាន
ទាល់តែសន្តានមានសំរាមក្នុងចិត្ត។

*ការងារងាយៗបែរធ្វើមិនបាន
មកពីសន្តាននៃមនុស្សខ្ជិល។

*ការងារជោគជ័យផ្តើមពីឆន្ទៈ
ដែលអាចទាញទាក់ឲ្យអ្នកចូលរួម។

*ការងារប្រចាំមានបញ្ហាបានធ្វើ
គឺជាទង្វើគ្មានមនសិការ។

*ការងារដែលជោគជ័យ
គឺអាស្រ័យពេលវេលា។

*ការងារដែលប្រសើរពិបាកធ្វើ
ការងារអត់អំពើងាយធ្វើកន្លង។

*ការងារតូចងាយជួយកិច្ចការធំ
គប្បីគួរកុំគិតហើយរំលង។

*ការងារធ្វើរឿយៗអាចស្ទាត់
នាំឲ្យអភិវឌ្ឍន៍នូវជំនាញ។

*ការងារមិនត្រូវចេះត្រឹមតែថា
គួរគិតយ៉ាងណាធ្វើឲ្យប្រាកដ។

*ការងារល្អទំនាក់ទំងល្អ ចំណេះដឹងខ្ពង់ខ្ពស់
ជាកិត្តិយសសម្រាប់សង្គម។

*ការងារល្អមានទំនាក់ទំនង
ទើបមិនឲ្យឆ្គងនូវគ្រប់កិច្ចការ។

*ការងារល្អ រាក់ទាក់បន្ត
កិត្តិយសប្រពៃ។

*ការងារអ្វីកុំរង់ចាំជំនួយ
ត្រូវព្យាយាមជួយខ្លួនឯងមុនសិន។

*ការចាញ់ដោយមានកិត្តិយស
ជាងឈ្នះមានឈ្មោះយសបាត់បង់។

*ការចាយវាយមិនចេះប្រមាណ
គឺជាសន្ដានក្ដីវិនាស។

*ការចាយវាយខ្ជះខ្ជាយមិនប្រមាណ
នាំទុក្ខរុំប្រាណព្រោះតែបំណុល។

*ការចាយវាយមិនប្រមាណ
នាំចិត្តប្រាណមិនបានសុខ។

*ការចិញ្ចឹមចិត្តខឹងប្រទូស្ត
មិនមែនមានឈ្មោះជាខន្តី។

*ការចែករំលែកជាផ្នែកមួយមិនអាចខានបាន
ដើម្បីសុខសាន្តរួមចំណែកជួយដល់សង្គម។

*ការចែករំលែកឲ្យគេរស់
កំពុងសង្គ្រោះដល់ខ្លួនឯង។

*ការចំណាយធំជាងចំណូល
គឺជាប្រផ្នែលមិនប្រសើរ។

*ការចេះចែករំលែកជួយសង្គ្រោះ
គឺមានកិត្តិយសជាបុព្វជន។

*ការចេះប្រមាណសមត្ថភាព
ទើបមិនបន្ទាបន្ទូវតម្លៃ។

*ការចេះប្រមូលផ្តុំគំនិត
នាំឲ្យការគិតអស់កង្វល់។

*ការចេះប្រើក្តាប់ឆក់បង្កឱកាស
គឺជាយុត្តិសាស្ត្រនៃចំណែកជោគជ័យ។

*ការចេះលើកស្នួយ
ជាពន្លឺមួយនៃការអភិវឌ្ឍ។

*ការចេះខ្មាសអៀនទង្វើត្រវខុស
ជាប្រភេទមនុស្សវិចារណញ្ញាណ។

*ការចេះគិតស្តាប់គំនិតអ្នកដទៃ
យកមកកែច្នៃឲ្យជីវិតប្រសើរ។

*ការចេះគោរពគ្រូមាតាបិតា
តាមកាយវាចាជាសីលធម៌ប្រពៃ។

*ការចេះទទួលន្ទូវកំហុស
ជាមនុស្សខុសទទួលត្រូវ។

*ការចេះទំនាក់ទំនង
គឺជាគន្លងដឹកនាំ

*ការចេះធ្វើសម្បទាន
នាំឲ្យគ្មានកើតវិបត្តិ។

*ការចេះផ្តល់ន្ទូវអភ័យ
ជានិស្ស័យនៃមនុស្សល្អ។

*ការចេះយោគយល់
នោះទើបបានដល់ន្ទូវក្តីសន្តោស។

*ការចេះឬល្ងង់គ្មានអ្វីថ្លឹង
ប៉ុន្តែអាចដឹងតាមលទ្ធផល។

*ការចេះលើកលែងកំហុស
គឺសន្តោសអធ្យាស្រ័យ។

*ការចេះលើកស្នួយ
ជាពន្លឺមួយនៃការអភិវឌ្ឍ។

*ការចេះស្តាប់គិតមើល
ទើបជាទង្វើគាប់ប្រសើរ។

*ការច្រណែននឹងអ្នកដទៃ
គឺគ្មានន័យអ្វីដល់ខ្លួនឯង។

*ការច្រណែនឈ្នានីសនិន្ទា
នាំទុក្ខវេទនាចិត្តខ្លួនឯង។

*ការច្រណែនយសសក្តិលាភទ្រព្យធន
គឺជាទម្ងន់ចិត្តផ្សាទុក្ខព្រួយ។

*ការជួយដល់អ្នកដទៃ
មានន័យដូចជួយខ្លួនឯង។

*ការជឿត្រូវចេះមើលតាមដាន
ទើបជាសន្តានៃអ្នកដឹង។

*ការជឿនាំឲ្យមានក្តីសង្ឃឹម
រស់គ្មានព្រលឹងព្រោះការបោកប្រាស់។

*ការជឿពិធីឬបាតុភូតប្លែកៗ
មិនសិក្សាហេតុអាចវិនាសទ្រព្យធន។

*ការឈប់សម្រាកថ្ងៃបុណ្យជាតិមិនសូវបញ្ហា
គួរថ្ងៃធ្វើការបុគ្គលិកប្រើពេលឲ្យទៀងទាត់។

*ការឈ្នះក្តីក្រោធដោយចិត្តស្ងប់
ទើបអាចរំងាប់ឈ្នះបញ្ហា។

*ការឈ្លោះជាមួយបុគ្គលពាល
នាំឲ្យងាយបាត់បង់កិត្តិយស។

*ការឈ្លោះប្រកែក
ជាដើមហេតុនៃបរាជ័យ។

*ការជាច់ឆ្នាំចាស់ផ្តាស់ចូលឆ្នាំថ្មី
គប្បីឃ្លាតខ្ទីសាងសេចក្តីល្អ។

*ការជាស់តឿនជារឿយៗ
ជាជំនួយដល់ការចងចាំ។

*ការដឹកនាំគំនិតច្នៃប្រតិដ្ឋ
នាំឲ្យជីវិតការងារជោគជ័យ។

*ការដឹកនាំគ្រាន់ឬមិនគ្រាន់
អាស្រ័យជំនាន់ក្រោយកំណត់។

*ការដឹកនាំចាត់ទុកថាចោលម្យៀត
បើគ្មានមារយាទគ្រប់គ្រងឲ្យល្អ។

*ការដឹកនាំចាំបញ្ហាមិនរៀរចំគោលដៅ
ដឹកដោយកម្តៅព្រោះខ្លៅគ្មានគំនិត។

*ការដឹកនាំចេះត្រឹមចម្ងងកូពីជាស់
សិក្សាមិនច្បាស់ពិតជាមិនអាចជោគជ័យ។

*ការដឹកនាំដែលចេះច្នៃប្រតិដ្ឋ
គឺជាគំនិតធ្វើការជោគជ័យ។

*ការដឹកនាំដែលធ្វើតែតាមអាជ្ញា
គ្មានបញ្ញាដោះបញ្ហាមិនជោគជ័យ។

*ការដឹកនាំដែលមានបំណងល្អ
សុខដោយកម្រស្មាញស្មុកប្រចាំ។

*ការដឹកនាំដោយគ្មានមនសិការ
កំពុងប្រហារអង្គភាពឲ្យក្ស័យ។

*ការដឹកនាំត្រូវចេះគួបផ្សំចំណេះទាំងព្រម
ទើបអាចសមល្មមដឹកនាំមានទេពកោសល្យ។

*ការដឹកនាំទទួលខុសត្រូវ
បើកចំហផ្លូវការចូលរួម។

*ការដឹកនាំផ្អែកលើលទ្ធផល
បានប្រយោជន៍ដល់ជាតិសង្គម។

*ការដឹកនាំមានគំនិតមហិច្ឆតា
ជាតម្រូវការនៃអង្គភាពសង្គម។

*ការដឹកនាំមានប្រយោជន៍គ្រប់គ្រាន់
អាស្រ័យជំនាន់ក្រោយវាយតម្លៃ។

*ការដឹកនាំមានភាពអំណត់
ប្រាកដនាំមកនូវជោគជ័យ។

*ការដឹកនាំមានហេតុផលតម្លាភាព
គឺជារបៀបនាំអង្គភាពជោគជ័យ។

*ការដឹកនាំមិនត្រឹមត្រូវបានល្អ
លទ្ធផលកម្រមានការចូលរួម។

*ការដឹកនាំមិនបត់បែនទម្លាប់
គឺជំពាក់ជាប់កើនច្រើនបញ្ហា។

*ការដឹកនាំមិនអាចតម្រូវចិត្តគ្រប់មនុស្ស
សំខាន់ឈ្នួលឈ្នួសឲ្យគេជោគជ័យទើបប្រសើរ។

*ការដឹកនាំរស់សោយសុខលើគំនរទុក្ខ
គឺជាប្រមុខនាំមកនូវក្តីវិនាស។

*ការដឹកនាំអង្គភាពរបៀបហែអើ
ធ្វើឲ្យដំណើរអភិវឌ្ឍគ្មានន័យ។

*ការដឹកនាំឲ្យមានការចូលរួម
គឺបានបង្រួញពេលអភិវឌ្ឍន៍។

*ការដើរផ្លូវលើឬខាងក្រោមស្ពាន
បើឆន្ទៈមានជាគោលដៅរួម។

*ការដែលខឹងប្រាកដជាខុស
ចេះស្គាល់កំហុសពិតជាត្រូវ។

*ការដោះស្រាយបញ្ហាកំពុងខឹង
គឺគ្មានលំនឹងគិតពិចារណា។

*ការតាំងចិត្តអស្ចិមានៈ
គឺជាកញ្ចុះកណ្ដាខ្លៅ។

*ការទទួលទូន្មានពីអ្នកដទៃ
គឺលើកតម្លៃដល់ខ្លួនឯង។

*ការទន្ទេញបានត្រឹមចាំរត់មាត់
បើចង់ចេះស្ទាត់ត្រូវរកស្រាវជ្រាវ។

*ការទុកដាក់ប្រើប្រាស់គ្មានរបៀប
គឺជាមារយាទនៃអ្នកខ្ជះខ្ជាយ។

*ការទុកដាក់ប្រើប្រាស់គ្មានរបៀប
គឺជាមារយាទនៃអ្នកគ្រប់គ្រង។

*ការទូន្មានពាលមិនងាយកែ
បើសេពគប់ក្បែរតែងវិនាស។

*ការធ្វើកិច្ចការដោយខ្វះនូវឆន្ទៈ
គឺអាចនឹងធ្លាក់ក្នុងភាពបរាជ័យ។

*ការធ្វើកំណែទម្រង់គង់បានសម្រេច
តែត្រូវចាំបាច់ព្យាយាមអំណត់។

*ការធ្វើខុសជារឿងធម្មតា
ចាប់កំហុសថាទើបបរាជ័យ។

*ការធ្វើខុសអាចគិតថ្មីបាន
ឲ្យតែសន្តានមានសតិ។

*ការធ្វើគុណពិតមិនសូវសម្តែង
បើធ្វើគុណកេងបំណងចង់ល្បី។

*ការធ្វើបុណ្យប្រកបដោយបញ្ញា
ទើបអាចប្រាថ្នាតែងបានសម្រេច។

*ការធ្វើបុណ្យរំពៃស្វែងរកលាភ
ទធ្វើថោកទាបបង្អូចសាសនា។

*ការធ្វើបំពានមិនហ៊ានសារភាព
ចេះត្រឹមប្រៀបធៀបចរិតដោះសារ។

*ការធ្វើរមែងតែងតែមានន្ទ្រវកំហុស
ប្រៀបដូចសក់ជ្រុះនៃមនុស្សជាប្រចាំ។

*ការធ្វើល្អកម្របានប្រសើរ
ពេលកំពុងដើរអាចជួបគ្រោះបាន។

*ការធ្វើល្អមិនចាញ់ក្តីស្អប់
គង់ប្រែត្រឡប់មកស្រឡាញ់។

*ការធ្វើសត្រូវជាមួយពាលចិត្ត
ទើបនាំជីវិតឲ្យជួបជោគជ័យ។

*ការធ្វើអ្វីដែលចេញពីក្នុងចិត្ត
ទើបនាំជីវិតរស់ដោយជោគជ័យ។

*ការធ្វើអ្វីមិនប្រើសតិ
កំពុងប្រតិកម្មនឹងផល។

*ការនិយាយដោយពោលពាក្យខ្លាំងៗ
កំពុងប្រឆាំងអារម្មណ៍អ្នកស្តាប់។

*ការនឿយហត់ចិត្តអត់ធ្មត់នឹងធឹង
គឺជាព្រលឹងប្ជុរយកតម្លៃ។

*ការនាំគេឲ្យធ្វើអំពើល្អ ដូចអ្នកជិះស្តីដើរឡើងភ្នំ
តែបើនាំឲ្យធ្វើអំពើមិនសមរម្យ ដូចជិះស្តីទម្លាក់ពីលើភ្នំមកដី។

*ការបង្កឱកាសអ្នកដើរទាត់ខ្យល់មានខ្យល់ទាត់
ទើបអភិវឌ្ឍន៍ធនធានមុខមាត់សង្គមជាញឹយ។

*ការបង្រៀនត្រូវឲ្យមានល្បិច
គឺត្រូវតាមចិត្តគរុកោសល្យ។

*ការបង្រៀនដែលមិនមានល្បិច
តើធ្វើម្តេចឲ្យសិស្សឆាប់យល់។

*ការបង្រៀនមិនបានអប់រំ
ជាគ្រោះដ៏ធំដល់អ្នកសិក្សា។

*ការបង្ហាញប្រាប់ពីបទពិសោធនិងដឹកនាំធ្វើ
គឺជាអំពើប្រសើរជាងចេះសូធ្យថាត្រឹមទ្រឹស្តី។

*ការប៉ងប្រាថ្នាមានលើគ្រប់រូប
គួរតែរើសយកប្រាថ្នាត្រឹមត្រូវ។

*ការបន្ទាបខ្លួនក្នុងតំណែងខ្ពស់
កំពុងសាងយសកាន់តែប្រពៃ។

*ការប្លងស្លងបែរបន់
គ្រាន់តែស្រេនអារម្មណ៍។

*ការបំបាត់សំរាមត្រឹមចាំបោសរើស
មិនស្មើដួចទើសរើសសំរាមក្នុងចិត្ត។

*ការប្រកាន់ចម្រើនបានខឹង
មិនសិក្សាដឹងពីហេតុផល។

*ការប្រកាន់ជ្រុលបានត្រឹមបែកបាក់
ព្រោះជាអន្ទាក់បែកធ្លុងសាមគ្គី។

*ការប្រកាន់ព្រោះមិនចង់ឲ្យចាញ់ចិត្ត
តែងនាំជីវិតធ្លាក់ក្នុងភាពអន្តរាយ។

*ការប្រទូស្តនឹងអភិវឌ្ឍន៍
ព្រោះសន្តានធ្លាប់ទំលាប់ខ្ជិល។

*ការប្រព្រឹត្តជីវិតឲ្យថ្លៃ
គឺមានតម្លៃមិនសាបសូន្យ។

*ការប្រមាទ
គឺជាអាទិ៍បំផ្លាញអនាគត។

*ការប្រមាទចំពោះសត្រូវ
គឺអាចជាផ្លូវបរាជ័យ។

*ការប្រយ័ត្ននាំមិនឲ្យបាត់ប្រយោជន៍
យសកេរ្តិ៍អសោចព្រោះបាត់បង់តម្លៃ។

*ការប្រាប់ពីគំនិតខ្លួនឯងធ្វើបាន
ទើបញាតិសន្តានជឿជាក់ធ្វើតាមងាយ។

*ការប្រើប្រាស់នូវអំពើហិង្សា
មិនទីប្រាថ្នានៃមនុស្សលោក។

* ការប្រើប្រាស់នូវអំពើហិង្សា
  មិនទីប្រាថ្នារបស់សត្វលោក។

* ការប្រើប្រាស់នូវអំពើហិង្សា
  វិនាសខ្ចោចផ្សាគ្រួសារសង្គម។

* ការប្រើប្រាស់សម្តីចោលមៀត
  បង្ហាញមារយាទការអប់រំ។

* ការផ្តល់ដំបូន្មានថ្វីមាត់ប្រៃ
  ដោយគុណតម្លៃនៃស្នាដៃខ្ពស់។

* ការផ្តល់នូវអភ័យ
  ជានិស្ស័យនៃមនុស្សល្អ។

* ការផ្លាស់ប្តូរផ្តើមពីការអប់រំ
  ទើបបានសង្គមមានការប្រែប្រួល។

* ការពឹងពាក់អ្នកតូចនិងអ្នកធំ
  តែងសុខដុមដូចខ្នាក់ពំនាក់ខ្នែន។

*ការព្យាយាមធ្វើឲ្យបានកើត
ទើបជាកំណើតពិតប្រាកដ។

*ការព្យាយាមរមែងបានជាប្រយោជន៍
ប៉ុន្តែយ៉ាងហោចអាចរងការឈឺចាប់។

*ការព្យាយាមរៀនដើម្បីចំណេះ
ពិតជាពិសេសគ្មានអ្វីប្រៀបបាន។

*ការព្យាយាមរៀន
ទើបមានគំនិត។

*ការមានះដោយភាពល្ងង់ល្ងិត
នាំហេតុផលពិតគឺមរណា។

*ការមិនយល់ជាឫសគល់នៃបញ្ហា
ធ្វើមិនយល់ជាសញ្ញាបរាជ័យ។

*ការមិនហ៊ានសម្រេចចិត្តធ្វើត្រូវ
គឺជាសត្រូវជាមួយមនសិការ។

*ការយកទ្រឹស្តីកែច្នៃជាគំនិត
អនុវត្តពិតៗនាំជីវិតមានន័យ។

*ការយកសុរាធ្វើជាត្រីមុខ
កំពុងនាំទុក្ខស្រយុតតម្លៃ។

*ការយល់បានមកពីពន្យល់ត្រូវ
ទើបបានជាផ្លូវនៃការចូលរួម។

*ការរក្សាមារយាទឱ្យថ្លៃ
ជានិស្ស័យនៃមនុស្សល្អ។

*ការរក្សាសណ្តាប់ធ្នាប់និងវិន័យ
ជាភាពជោគជ័យនៃតម្លៃសង្គម។

*ការរង់ចាំមិនអាចសង្ឃឹមប្រាកដ
អ្វីអាចសន្មតគឺសម្រេចចិត្តធ្វើ។

*ការរស់នៅដោយចេះចែករំលែក
គឺរួមចំណែកជួយដល់សង្គម។

*ការរឹងចចេសមានៈ
មិនដែលឈ្នះដល់អាត្មា។

*ការរួមគ្នាកាត់បន្ថយប្តាស្ទឹក
ទើបជួយជីវិតផុតពីអន្តរាយ។

*ការរៀនគិតមើលធ្វើស្តាប់
គឺជាប្រជាប់កែប្រែវិញ្ញាណ។

*ការរៀន
គឺជាវិញ្ញាណនៃអនាគត។

*ការរៀនចេះទទួលន្ធវកំហុស
ធ្វើឱ្យកំហុសផ្តល់ជាតម្លៃ។

*ការរៀនមិនមែនដើម្បីតែរៀន
គឺរៀនឱ្យចេះទុកជាមេរៀន។

*ការរៀនដោះស្រាយន្ធវរាល់បញ្ហា
នោះទើបជាការរៀនពីជីវិត។

*ការរៀនមើលសាកល្បងគិតស្តាប់
គឺជាប្រដាប់នៃការធ្វើ។

*ការរៀនឲ្យចេះមើលធ្វើគិតស្តាប់
គឺជាប្រដាប់នៃការអភិវឌ្ឍ។

*ការរៀបចំទុកដាក់ឲ្យមានរបៀប
គឺជាមារយាទមានទម្លាប់ថ្លៃថ្នូរ។

*ការរិះគន់
គឺវាស់ស្ទង់ពីអាត្មា។

*ការរិះគន់ដោយគំនិតស្ថាបនា
ជាបំណងប្រាថ្នានៃបណ្ឌិត។

*ការរិះគន់ដោយបញ្ចើចបញ្ចើ
មិនមែនដំណើរចិត្តសប្បុរស។

*ការលើកតម្កើងបុគ្គលមិនថ្លៃ
នាំបាត់តម្លៃសាមីខ្លួនឯង។

*ការលើកតម្កើងមារយាទថ្លៃថ្នូរ
ជាការផ្គាស់ប្តូរតំរិយាបថប្រពៃ។

*ការលើកតម្កើងហួសប្រមាណ
ជាសន្ដានៃក្ដីវិនាស។

*ការលេងល្បែងស៊ីសងថាកម្បាន្ដ
អសោចសន្ដានពូជទាំងគ្រួសារ។

*ការលះបង់ដល់កម្រិតតែងជួបភាពល្វីងជូរចត់ប្រៃ
តែស្គាល់និស្ស័យតម្លៃរសជាតិពិតនៃជីវិតមនុស្ស។

*ការលះបង់ដោយមានឆន្ទៈ
ទើបជាធ្នាក់ទាក់យកជោគជ័យ។

*ការវាយតម្លៃផ្អែកលើលទ្ធផល
ពិនិត្យហេតុផលទើបដឹងគុណភាពពិត។

*ការវាយឫកកាច់រាងគ្មានប្រយោជន៍
នាំតែអសោចពាក្យដំណៀលកេរ្តិ៍។

*ការវិនិច្ឆ័យខុស
ជាកំហុសអ្នកដឹកនាំ។

*ការសង់អគារលំបាកតែងាយស្រួល
ប៉ុន្តែភ័យព្រួយខ្វះមារ៉ាយាទរក្សា។

*ការសន្មតបុគ្គលវ័យចាស់ឬក្មេងដឹកនាំល្អ
គឺជាជំហរបេះដូងដែកចិត្តស្មោះផលប្រពៃ។

*ការសប្បាយចាយវាយតាមកម្រិត
សំរាំងសំរិតជីវិតរីករាយ។

*ការសាងសង់អាគារអាចបានដោយងាយ
លំបាកពណ្ណរាយសាងនូវមនុស្សពិត។

*ការសាបព្រោះតែសន្តានកខ្វក់
បានផលអាក្រក់តពូជតពង្ស។

*ការសិក្សាគ្រាន់តែជាមាគ៌ា
ឆន្ទៈការងារផ្តើមពីនិស្ស័យ។

*ការសិក្សាចប់ប្រតិបត្តិប្រៃប្រួល
ទើបជាជំនួយអភិវឌ្ឍជាក់ស្តែង។

*ការសិក្សាពីជីវិតខ្លួនឯង
ទើបអាចចេះក្រែងបុគ្គលដទៃ។

*ការសិក្សាទទួលជោគជ័យ
ព្រោះមានវិន័យជាចម្បង។

*ការសិក្សាដោយទឹកចិត្តសប្បាយៗ
នាំឲ្យរាងកាយមាំមួនបញ្ញាភ្លឺថ្លា។

*ការសិក្សាជោគជ័យប្រពៃ
ត្រូវមានវិន័យជាចម្បង។

*ការសិក្សាផ្នែកសិល្បៈតន្ត្រី
នាំកើតសិរីដល់កាយបញ្ញា។

*ការសិក្សាពីភាពខុសនិងត្រូវ
ទើបបានជាផ្លូវនៃភាពជោគជ័យ។

*ការសិក្សាពីភាពបរាជ័យ
គឺមានតម្លៃដល់ជ័យជំនះ។

*ការសិក្សាពីសហគមន៍
ជាប្រភពទុនមិនរីងស្ងួត។

*ការស៊ូទ្រាំលំបាកចិត្តកាយឲ្យអ្នកដទៃសុខ
គឺជាប្រមុខនៃអ្នកដឹកនាំល្អដែលកម្រមាន។

*ការសេពគប់ជាមួយបណ្ឌិត
គឺមានគំនិតអភិវឌ្ឍន៍។

*ការសេពគប់មិត្តតែរូបរាងកាយ
ខូចឈ្មោះបង់កាយព្រោះមិនស្គាល់ចិត្ត។

*ការស្គាល់ចំណេះមិនទាន់ចេះ
ទើបបានចំណេះអាចចេះកើន។

*ការស្គាល់ពីតម្លៃខ្លួនឯង
រមែងតែងជាកត្តាសម្រេច។

*ការស្តាប់គិតពិចារណា
គឺជាអាហារនៃជីវិត។

*ការស្តាប់ច្រើនចម្រើនគំនិត
សម្រាប់ទុកគិតពិចារណា។

*ការស្លាប់ដោយសារតែក្តីល្ងង់
ជាអន្តង់ទុក្ខតសន្ធាន។

*ការស្លៀកពាក់សមរម្យ
គឺធ្វើឲ្យខ្ញុំមានតម្លៃ។

*ការស្រវឹងមានច្រើនប្រការ
គ្រឿងញៀនស្រីស្រាអបាយមុខ។

*ការស្អប់ស្រឡាញ់គួរកុំទោម្នេញ
ធ្វើល្អម្តេចមិញគង់មានគេស្អប់។

*ការហ៊ានសម្រេចចិត្តមើលហើយធ្វើ
ទើបជាអំពើនាំឲ្យជោគជ័យ។

* ការហ៊ឺហារខ្ជះខ្ជាយខុសទំនង
កំពុងអន្ទងអ្នកផងមាក់ងាយ។

* ការអប់រំកុមារត្រូវមានគ្រូបី
គឺមាតុប្រុសស្រីគ្រូនិងព្រះសង្ឃ។

* ការអប់រំកុំគិតត្រឹមតែប្រយោជន៍គ្រួសារ
គួរចែកផ្លែផ្កាអប់រំដល់សង្គមទើបមានន័យ។

* ការអប់រំខ្វះសិល្បៈតន្ត្រី
ពុំសូវមានន័យដល់ការសិក្សា។

* ការអប់រំចំគោលដៅនៃបញ្ហា
ទើបមានផ្លែផ្កាដល់គ្រួសារសង្គម។

* ការអប់រំចំពោះមនុស្សពាល
ដូចជាប្រមៀលថ្មឡើងលើភ្នំ។

* ការអប់រំតាមរយៈសិល្បៈតន្ត្រី
ជាវិធីប្រពៃប្រសើរពេកកន្តង។

*ការអប់រំតែងតែរងប្រទូស្ត
មិនខំឈ្លុលឈ្លុសគឺបរាជ័យ។

*ការអប់រំបញ្ជាបបរិស្ថានក្នុងបេះដូង
ទើបជាគន្លងថែបរិស្ថានជោគជ័យ។

*ការអប់រំប្រយោជន៍បានក្លូនគេ
ពាក្យប្រមាទជេរបានមកយើង។

*ការអប់រំមិនចំគោលដៅបញ្ហា
នាំឲ្យកិច្ចការមិនសម្រេចបំណង។

*ការអប់រំលក្ខណៈអាត្មានិយម
អាចនាំសង្គមឲ្យបែកបាក់សាមគ្គី។

*ការអប់រំវិវឌ្ឍន៍តាមសង្គម
ទើបមិនជាប់ឃុំប្រវត្តិសាស្ត្រ។

*ការអប់រំឲ្យយល់តាមផ្លូវត្រូវ
ពិបាកយកទៅទូន្មានចិត្តពាល។

*ការអភិវឌ្ឍបុគ្គលគ្រួសារ
មកពីកត្តាសង្គមចម្បង។

*ការអានច្រើនចម្រើនបញ្ញា
នូវរាល់បញ្ហាដែលចង់ចេះ។

*ការឲ្យតម្លៃដល់អ្នកដទៃ
គឺមានន័យផ្តល់តម្លៃខ្លួនឯង។

*កាលនៅរស់គួរចេះឲ្យតម្លៃ
កុំចាំក្បិណក្បុំយទើបលើកតម្កើង។

*កិច្ចការខ្លះធ្វើតាមទម្លាប់ចាស់ពីសង្គម
គួរចេះពួតផ្គុំគំនិតថ្មីទើបនិស្សំយល្អ។

*កិច្ចការជោគជ័យព្រោះមានឆន្ទៈ
សម្រាប់ធ្វើផ្នាក់ទាក់ចិត្តចូលរួម។

*កិច្ចការដែលស្រឡាញ់ពេញចិត្ត
តែងជួបជីវិតចិត្តឈឺផ្សា។

*កិច្ចការថ្ងៃនេះជាបទពិសោធន៍ថ្ងៃស្អែក
ហើយរកចំណុចប្លែកសិក្សាកែលម្អ។

*កិច្ចការធ្វើដោយចិត្តផ្ចិតផ្ចង់
ទើបមិនបាត់បង់នូវឱកាស។

*កិច្ចការធ្វើមធ្យ័តជាបញ្ញត្តិជោគជ័យ
បើធ្វើបង្គ្រប់ន័យបរាជ័យប្រាកដ។

*កិច្ចការធ្វើមានរបៀប
ទើបជាមារយាទថ្លៃថ្នូរ។

*កិច្ចការលំបាកតែនៅធ្វើបាន
គឺអាចប៉ាន់ស្មានពីសមត្ថភាព។

*កិច្ចការសង្គមមិនជួយឈឺឆ្អាល
គឺអាចបណ្តាលជួបគ្រោះអភិវឌ្ឍន៍។

*កិច្ចការសំខាន់មិនគួរទុកក្រោយ
ត្រូវរៀបចំឲ្យសកម្មទៅមុខ។

*កិច្ចតែងការគឺជាអាវុធ
សម្រាប់ប្រយុទ្ធពេលបង្រៀន។

*កិច្ចសហការមានតម្លៃកន្លង
បែរជាអ្នកផងមិនដែលគិតដល់។

*កិត្តិយសខ្ពង់ខ្ពស់តែឈ្មោះអប្រិយ
ដូចធ្លាក់អវិចីប្រល័យខ្លួនឯង។

*កិត្តិយសខ្ពង់ខ្ពស់ឥរិយាបថសុភាព
ជាអានុភាពនៃបុគ្គលដឹកនាំល្អ។

*កុមារទាំងឡាយប្រៀបដូចជាផ្កា
ដែលតែងត្រូវការទន្លូវទឹកសន្សើម។

*កុមារប្រៀបដូចជាក្រដាសពណ៌ិស
ចាត់ជាមនុស្សល្អនៅក្នុងពិភពលោក។

*កូនមាន់ចឹកសម្បកចេញមកខ្លួនឯងទើបអាចរស់បាន
មនុស្សថ្កើងថ្កានរស់បានព្រោះគំនិតចេះពិចារណា។

*-កើតជាមនុស្សកុំអន់ជាងសត្វ
ត្រូវប្រតិបត្តិធម៌ដែលប្រសើរ។

*កើតជាមនុស្ស
មិនគួររស់លើទុក្ខអ្នកដទៃ។

*កើតជាមនុស្សត្រូវស្គាល់ត្រូវខុស
មិនទម្លាក់កំហុសលើអ្នកដទៃ។

*កើតមួយជាតិគប្បីឆ្លៀតសងគុណសង្គម
កុំរស់ធាត់ធំបំផ្លាញសង្គមជាតិឯង។

*កើតយសអត់យសព្រោះតែប្រតិបត្តិ
អាចខូចខាតបាត់ព្រោះមារយាទចម្បង។

*កុំគិតថាគ្រាន់បើមិនទាន់ចេះ
កុំរកតែលេសយកមកដោះសា។

*កុំគិតថាគ្រាន់ពេលខ្លួនគ្មានកំណើត
ព្រោះផលដែលកើតមានគេកំពុងជួយ។

*កុំខ្វើកតាមខ្យល់ កុំខ្វល់តាមពាល
មិនងាយកែព្រោះតែចរិតអន់។

*កុំខ្វើកតាមខ្យល់
កុំខ្វល់តាមឥស្សា។

*កុំឃាត់មាត់ចំពោះអ្នកថា
ធ្វើឲ្យអស្ចារ្យការប្រតិបត្តិ។

*កុំឃាត់មាត់អ្នកថា
ត្រូវពិចារណាអ្វីគួរប្រតិបត្តិ។

*កុំឃើញគុណអ្នកឆ្ងាយច្រើនជាងអ្នកជិត
ព្រោះថ្វីត្បិតអ្នកដែលជិតជួយប្រចាំ។

*កុំឃើញគេខុសព្រោះខ្លួនថាត្រូវ
តម្រូវតាមអំណាចជាអ្នកដឹកនាំ។

*កុំឃើញភាពខ្មៅងងឹតសម្រាប់ខ្លួនឯង
ត្រូវខំប្រឹងប្រែងធ្វើឲ្យជីវិតមានន័យ។

*កុំយើញអ្នកឆ្ងាយល្អជាងអ្នកជិត
តាមការពិតអ្នកជិតជួយរាប់ឆ្នាំ។

*កុំចេះចាំត្រឹមសូធ្យរត់មាត់
អនុវត្តភ្លាំងភ្លាត់មិនចេះធ្វើ។

*កុំចេះតែបង្រៀនដល់គេ
ត្រូវរិះរៀនខ្លួនឯងផង។

*កុំចេះត្រឹមថាឲ្យគេកោត
តែធ្វើមិនកើតជាលទ្ធផល។

*កុំចេះបានតែត្រឹមថា
ធ្វើកើតផងណាទើបប្រពៃ។

*កុំចេះបានត្រឹមតែការរៀនសូត្រ
មិនអាចប្រដូចរៀនហើយចេះធ្វើ។

*កុំជឿតែលើមាត់គេថា
មើលធ្វើផងណាទើបត្រឹមត្រូវ។

*កុំតាំងខ្លួនជាអ្នកចេះសព្វគ្រប់
ដែលគ្មានប្រភពពីការសិក្សា។

*កុំតាំងខ្លួនឲ្យខ្ពង់ខ្ពស់ហួស
ក្រែងរងគ្រោះព្រោះចរិតអន់។

*កុំទន្ទឹងរំពឹងរង់ចាំតែជំនួយ
គប្បីរិះព្រួយជួយខ្លួនឯងទើបប្រសើរ។

*កុំទាន់ជឿត្រឹមពាក្យនិយាយ
ត្រូវចេះស្វាធ្យាយគិតហេតុផល។

*កុំទាន់ជឿសម្តីនិយាយល្អ
សង្កេតបន្តមារយាទរាល់ថ្ងៃ។

*កុំទាន់ជឿអ្នកថា
ត្រូវជឿវិញ្ញាណាលទ្ធផលអ្នកធ្វើ។

*កុំទាស់តែនឹងទង្វើត្រូវ
ព្រោះមិនតម្រូវចិត្តអ្នកថា។

*កុំទុកព្រលឹងជាតិប្រៀបនឹងដបស្រា
នាំឲ្យអប្បញ្ញាដល់ផៅសន្តាន។

*កុំទុកមារយាទផ្ទើនឹងសំរាម
គួរផ្ទើសំរាមនឹងមនសិការ។

*កុំទោមនស្សជាមួយអ្វីដែលគ្មាន
ត្រូវថែអ្វីមានហើយកុំឲ្យបាត់។

*កុំធ្វើខ្លួនដូចសត្វឈាមរា
មានចរិតជាដូចរាជសីហ៍។

*កុំធ្វើខ្លួនមនុស្សតែឈ្មោះ
ខំប្រឹងរស់ដូចតិរច្ឆាន។

*កុំធ្វើអ្វីដើម្បីតែធ្វើ
មិនរំពឹងមើលពីលទ្ធផល។

*កុំនិយាយពីរោះស្តាប់តែខ្លួនឯង
គប្បីគិតក្រែងដល់ចិត្តអ្នកស្តាប់ផង។

*កុំបានខាងសុំមិនធំរក្សា
បង់យសឥតការដោយសារមារយាទ។

*កុំបានគ្រាន់ដោយមិនចេះក្រែង
ដែលជាកន្លែងស្វែងបាត់យស។

*កុំបានត្រឹមតែចេះគិតមាត់ថា
ធ្វើកើតផងណាទើបការប្រពៃ។

*កុំបានត្រឹមថា
ត្រូវធ្វើយ៉ាងណា ថាហើយធ្វើកើត។

*កុំប្រទូស្តជាមួយជនពាល
នាំតែមាក់ងាយដល់អាត្មា។

*កុំប្រទូស្តជាមួយពាល
នាំឲ្យងាយបាត់បង់យស។

*កុំប្រៀបព្រលឹងជាតិនឹងសុរា
ពេលផឹកកាលណាភ្លេចជាតិកំណើត។

*កុំមានទស្សនៈចាំតែពឹងគេ
មិនប្រសើរទេអាចគេមើលងាយ។

*កុំមើលងាយសមត្ថភាពខ្លួនឯង
តែត្រូវកោតក្រែងចេះអ្នកដទៃ។

*កុំយកឫស្សីធ្វើរបងការពារវាំងមនុស្ស
អប់រំចិត្តនោះធ្វើជារបងទើបប្រសើរ។

*កុំរស់តែឈ្នោះត្រូវយសបាត់បង់
ព្រោះល្បិចវៀចវ៉ង់បន្តិកេងកិប។

*កុំរស់សម្រាប់ស្លាប់
កុំឆាប់សម្រាប់ឃ្លរ។

*កុំរើសអើងតែរកវិធីការពារ
កូវីដរោគាជាភ្នាក់ងារចម្លង។

*កុំរៀនដើម្បីរៀនតែគ្មានគំនិត
នាំឲ្យជីវិតធ្លាក់ក្នុងអន្តរាយ។

*កុំរំពឹងលើសម្តីគ្រូទាយ
ត្រូវចេះស្វាធ្យាយពឹងគិតខ្លួនឯង។

*កុំឮគេថា
ត្រូវពិចារណា ហើយសឹមស្រដី។

*កុំលើកដៃចាប់ជើងខាងក្រោមជាន់
កុំគិតថាគ្រាន់តីពុតអាក្រក់។

*កុំលូងយកស្មៅទៅដាំកណ្តាលខ្សាច់
បើលូងមិនបាច់ធ្វើប្រាជ្ញកណ្តាលខ្លៅ។

*កុំសង្ឃឹមគិតចាំតែជំនួយ
គួរខ្លួនខំជួយទើបជាដើមទុន។

*កុំសម្តីងតែទោសអ្នកដទៃ
គប្បីរំពៃកំហុសខ្លួនឯង។

*កុំសេពគប់មិត្តមានប្រាក់ជួបសប្បាយ
អស់លុយមិត្តឆ្ងាយនាំបង់គំនិត។

*កុំហ៊ីហាតែសភាពក្រៅប្រាណ
ប៉ុន្តែរហាមសភាពក្នុងចិត្ត។

*កុំឡើងហើយក្តិច
កុំជាន់ពន្លិច អ្នកនៅពីក្រោម។

*កំណើតមនុស្សល្អកុំក្រមារយាទ
គប្បីជួយញាតិមិត្តទន់ទាបជាងខ្លួន។

*កំពុងខឹងកុំទាន់ស្រាយ
នៅពេលរសាយចាំដោះ។

*កំហឹងខឹងមិនបានបំភ្លេច
ប្រៀបដូចកម្ទេចភ្លើងក្នុងប្រាណ។

*កំហុសកុំរំពៃតែទោស
គួរចេះសន្តោសទើបប្រពៃ។

*កំហុសគឺជាមេរៀន
តែត្រូវរៀនកុំឲ្យខុស។

*កំហុសច្រើនមានតែលើអ្នកធ្វើ
អ្នកដែលចាំមើលខុសរាប់មិនអស់។

*កំហុសច្រំដែល
មិនដែលអភិវឌ្ឍ។

*កំហុសដូចស្រមោលអន្ទោលតាមប្រាណ
ធ្វើមិនប្រមាណប្រមាទពិតជាខុស។

*កំហុសតែងកើតមានជាធម្មតា
ជីងខុសត្រង់ណាមិនកែ ទើបជា
ប្រការមិនធម្មតាឡើយ។

*កំហុសតែងតែមានជាប្រចាំ
គប្បីចំណាំកុំខុសពេលក្រោយ។

*កំហុសត្រូវចាត់ទុកជាគំរូ
កុំខុសយូរៗនៅតែច្រំដែល។

*កំហុសត្រូវបានលើកលែង
កុំខុសកន្លែងហ្នឹងម្តងហើយម្តងទៀត។

*កំហុសនៃអ្នកដទៃ
គួររំពៃមកខ្លួនឯង។

*កំហុសអ្នកដទៃកុំរំពៃមើល
ត្រូវខិតខំធ្វើអំពើប្រពៃពិត។

*ក្តីសុខមានហើយគួរចេះរក្សា
កុំដល់ប្រេះឆាទើបនឹកស្តាយក្រោយ។

*ក្នុងលោកអ្វីៗសុទ្ធតែប្រែប្រួល
អ្នកមើលថាស្រួលអ្នកទទួលថាពិបាក។

*ក្រទ្រព្យគង់អាចរកបាន
ក្រសន្តានគឺកែយ៉ាប់។

*ក្រទ្រព្យមាសប្រាក់គង់អាចរកបាន
ក្រចិត្តសន្តានក្រមួយជីវិត។

*ក្រទ្រព្យអាចនៅសង្គ្រោះបាន
ក្រមារយាទវិញគ្មានបានអ្វីសង្គ្រោះ។

*ក្រុមគ្រួសារមានកិច្ចសហការ
ធ្វើឲ្យកុមារមានភាពរឹងមាំ។

*ក្រុមជនផ្តាច់ការ
ចរិតបាតផ្សារ អាត្មានិយម។

*ក្រុមជនផ្តាច់ការ
មិនដែលស្នេហាប្រជាធិបតេយ្យ។

*ក្រុមទមិឡតែងតែរមិលគុណ
ព្រោះខំរែកពុនសំពាយអាក្រក់។

*ក្មេងនឹងទឹក ក្មេងនឹងព្រៃ ក្មេងនឹងដី
ចូរឪពុកម្តាយឃ្លាតខ្ចីប្រុងប្រយ័ត្ន
កុំឲ្យថ្ពោះឆ្ពោយក្រែងលោមានវិបត្តិ
ឧបសគ្គមកកម្ចាត់ពិបាកកែកុន។

ខ ~ ង

*ខន្តីខំប្រឹងអត់ធ្មត់
នាំឲ្យរលត់កំហឹង។

*ខន្តីគឺជាស្ពាន
នាំឲ្យមានក្តីសុខ។

*ខន្តីជាទ្រព្យដ៏កម្រ
កិលេសបង្កឲ្យចិត្តខឹង។

*ខន្តីជាទ្រព្យមិនប្រព្រឹត្តរក
ព្រោះម្នាក់ៗជ្រកក្រោមម្លប់កំហឹង។

*ខន្តីជួយសម្រួលអារម្មណ៍ចិត្ត
នាំឲ្យឈ្នះមិត្តបាបចិត្តឫស្យា។

*ខន្តីនាំឲ្យស្មារតីស្ងប់ស្ងាត់
រំងាប់វិបត្តិបង្កាត់ជាភ្លើង។

*ខឹងកុំទាន់ស្រាយ
រសាយចាំដោះ។

* ខុសឬត្រូវតម្រូវតែលើអ្នកថា
បានពិចារណាឬអាចារ្យតែចេះ។

* ខ្ជិល!
គឺជាមន្ទិលនៃក្តីសុខ។

* ខ្ជិលគឺជាមន្ទិលនៃភាពក្រ
អាក្រក់ឬល្អកើតដោយប្រតិបត្តិ។

* ខ្ជិលជាមន្ទិលនៃអន្តរាយ
ធ្វើល្អសប្បាយសន្សំបុណ្យ។

* ខ្មែរមិនចេះខ្មែរចេះតែអង់គ្លេស
អសោចកើរ្តិ៍ណាស់បរទេសមិនយល់។

* ខ្មែរមិនចេះខ្មែរថាចេះតែបរទេស
គួរសង្វេគណាស់កូនខ្មែរមិនចេះខ្មែរ។

* ខ្យល់ស្ងប់មិនប្រាកដគ្មានទឹករលក
ជីវិតសត្វលោកសុខទុក្ខជាធម្មតា។

* ខ្លាចស្ងប់ប្រសើរជាងខ្លាចខ្លៅ
នាំធ្លាក់រណ្តៅព្រោះខ្លៅតាំងខ្លួនចេះ។

គ ~ ឃ

*គតិបណ្ឌិតនាំឲ្យសង្គមផ្លូវផង់
ព្រោះមិនបាត់បង់ឆន្ទៈមនសិការ។

*គប់បណ្ឌិតនាំជីវិតរុងរោចន៍
គប់ពាលរុះរោចហិនហោចរលាយ។

*-គប់បណ្ឌិតនាំជីវិតរុងរោចន៍
គប់ពាលអសោចនាំតែរឿងរ៉ាវ។

*គប់បណ្ឌិតនាំជីវិតរុងរឿង
គប់ពាលនាំរឿងវិនាសអន្តរាយ។

*គប់បណ្ឌិតបានសុខកន្លង
គប់ពាលសៅហ្មងអសោចកើរ្តិ៍។

*គប្បីកុំខ្លាចស្រមោលអ្នកដទៃ
ត្រូវធ្វើអ្វីៗខ្លាចស្រមោលខ្លួនឯង។

*គប្បីកុំចាញ់ការធ្វើសេចក្តីល្អ
គួរកុំត្រេកអរធ្វើអំពើអាក្រក់។

*គប្បីកុំចាំតែប្រទូស្ត
ត្រូវជួយឈ្លុលឈ្លុសរកវិធី។

*គប្បីកុំទុកមារយាទផ្ញើនឹងសំរាម
ត្រូវតែចងចាំទុកសំរាមផ្ញើនឹងសតិ។

*គប្បីកុំពូកែប្រើតែថ្ងៃមាត់
នៅពេលអនុវត្តចរិតអន់។

*គប្បីកុំសប្បាយក្លាយជាទុក្ខ
រីករាយមានមុខកើតទុក្ខបាត់កាយ។

*គប្បីគិតហេតុផលវិជ្ជមាន
ទើបបានជាស្ពាននៃគំនិត។

*គប្បីគិតអ្វីបានជាប្រយោជន៍។
ទើបមិនអសោចទុកតជាកេរ្តិ៍។

*គប្បីទម្លាប់ចេះសង្កេត
ទើបអាចជាភ្នែកនៃបេះដូង។

*គប្បីធ្វើជាមនុស្សធ្យូងចំបក់
សម្បុរអាក្រក់តែមារយាទថ្លៃ។

*គប្បីធ្វើអ្វីដែលក្រហើយមាន
នោះជាសន្តានចិត្តសប្បុរស។

*គប្បីប្រើសតិគ្រប់គ្រងនិស្ស័យ
ទើបជួយកែច្នៃតម្លៃនៃជីវិត។

*គប្បីព្យាយាមរក្សារបស់ដែលមាន
ប្រសើរជាងរៀនស្វែងរករបស់ដែលអត់។

*គប្បីមានសតិមុនគិតធ្វើ
ទើបជាទង្វើមិនងាយឆ្គោះឆ្គាយ។

*គប្បីមានសតិមុនធ្វើ
ទើបបានទង្វើមិនថ្គោះឆ្គាយ។

*គប្បីរស់ដោយចេះចែករំលែក
ប្រសើរពន់ពេករស់ជួយសង្គម។

*គប្បីរួមគ្នាគិតធ្វើថា
ទើបជាកត្តានៃជោគជ័យ។

*គប្បីសាងស្មាដៃឲ្យកើតជាមុន
ទើបបានជាទុនជំនឿអភិវឌ្ឍ។

*គិតមិនហ៊ានធ្វើ
គិតឥតអំពើ គិតដើម្បីគិត។

*គុណកើតមានក្នុងសន្តានចិត្ត
ទើបអាចបដិបត្តិទង្វើល្អ។

*គុណគេធ្វើមកលើឯងមិនដែលឲ្យតម្លៃ
ល្មើសគុណចង់ថ្លៃប្រទូស្តបំភ្លៃដោយទុច្ចរិត។

*-គុណបំណាច់គេច្រើនឆាប់បំភ្លេច
គំនុំតូចតិចច្រើនចាំបានយូរ។

*គុណភាពប្រសិទ្ធភាពគ្រូបង្រៀន
អាចនាំឲ្យមានសហគមន៍ចូលរួម។

*គួរកុំសប្បាយភ្លើតភ្លើនភ្លេចខ្លួន
ខណៈគាប់ចួនខ្លួនកំពុងក្រ។

*គួរចេះថែតំណមារយាទដែលថ្លៃ
ទើបជាបច្ច័យជោគជ័យមាននិរន្តរ៍។

*គួរធ្វើឲ្យប្រាកដមិនខ្ជះខ្ជាយ
ទើបមានពណ្ណរាយក្នុងជីវិត។

*-គេធ្វើខុសម្តងខ្លួនចាំបានច្បាស់
បើល្អច្រើនណាស់មិនសូវចាំទេ។

*-គេធ្វើខុសម្តងពូកែចាំ
ធ្វើល្អរាប់ឆ្នាំពូកែភ្លេច។

*គោរពច្បាប់ចរាចរណ៍
ជាសុជីវធម៌នៃអ្នកបើកបរ។

*គោរពពេលវេលាមិនបាន
នាំឲ្យរំខានភាពជោគជ័យ។

*គំនិតគិតត្រូវតែនៅមានកំហុស
ព្រោះមិនទុកខុសសម្រាប់ជាមេរៀន។

*គំនិតគិតធ្វើដដែលៗ
លទ្ធផលប្រហែលគ្មានស្ថេរភាព។

*គំនិតគិតធ្វើតែរឿងដដែល
ផលមិនក្រាស់ក្រែលប្រសើរជាងមុន។

*គំនិតចេះទុករើសចោលសំរាមបានថ្លៃ
គំនិតចង្រៃបោះទុកចោលឲ្យគេរើស។

*គំនិតដែលថោកឬមានតម្លៃ
ប្រាប់តាមសម្តីឬការសរសេរ។

*គំនិតដែលបានឲ្យអភ័យ
គឺមានន័យស្មើសប្បុរស។

*គំនិតបញ្ជាក់ពីសញ្ញាណកំណើត
ដែលអាចធ្វើកើតអត្ថប្រយោជន៍ពិត។

*គំនិតពាលពិតជាមិនងាយកែ
គួរចៀសកុំក្បែរសេពគប់ជាមិត្ត។

*គំនិតពាលមិនងាយបង្ហាញមុខ
គំនិតសុកមម៉ុកចាក់រុកពីក្រោយ។

*គំនិតមានតែគ្មានមារយាទ
មិនអាចពឹងញាតិជួយជាប្រចាំ។

*គំនុំតែងគ្មានកំណើត
បានត្រឹមកើតតែបញ្ហា។

*គ្មានកិច្ចសហការសាលានិងគ្រូសារ
លទ្ធផលសិក្សាគ្មានគុណភាព។

*គ្មានគំនិតបង់មារយាទ
នាំឲ្យជាតិបាត់តម្លៃ។

*គ្មានតម្លៃទេ បើអ្នកអប់រំគេ
ធ្វើខ្លួនមិនឲ្យអ្នកដទៃគោរព។

*គ្រូកាចធ្វើឲ្យសិស្សមិនចង់រៀន
គ្រូប្រិតប្រៀនទាំឲ្យសិស្សឆាប់ចេះ។

*គ្រូនៃការសិក្សាគឺមាន៤
វដ្ត:ឲ្យគាប់ជួនមើល ស្តាប់ គិត ធ្វើ។

*គ្រូបង្រៀនក្រតែទ្រព្យមែនពិត
អាចនាំជីវិតអ្នករៀនរុងរឿង។

*គ្រូបង្រៀនជាទឹកភ្លៀង
សិស្សដែលរៀនជាវាលស្រែ ពុកម៉ែដូចជាជីវជាតិ។

*គ្រូបង្រៀនត្រូវក្លាយជាក្បាលម៉ាស៊ីនថ្មី
កុំមានត្រឹមន័យសមត្ថភាពថ្មីទម្លាប់ចាស់។

*គ្រូបង្រៀនមានចំណេះដឹងឥរិយាបថល្អ
ទើបជាសសរក្រមសីលធម៌អប់រំប្រាកដ។

*គ្រូអប់រំសិស្សស្រុះដូចអង្រ្កង
សម្រេចបំណងដល់អ្នកសិក្សា។

ឍ ~ ឃ

*- ឃើញគេធ្វើល្អច្រើនហួសរំលង
បើគេខុសឆ្គងខ្លួនចាំជានិច្ច។

* ឃើញអ្នកដទៃខុសកុំទោម្នេញ
ព្យាយាមជួយវិញដោយចិត្តស្មោះ។

* ឃុំឃាំងរនាំងនៃអវិជ្ជា
គប្បីម្ចឹម្នាដោះដោយបញ្ញា។

*- ឃ្លាំងគំនិតសម្រាប់ពិចារណា
គួរផ្ទៀងសោតាស្តាប់ឲ្យបានច្រើន។

ច ~ ង

*ងងឹតព្រោះពន្លឺអាចបំភ្លឺបាន
ងងឹតសន្តានមិនងាយកែឲ្យភ្លឺ។

*ងប់ងុលនឹងកាមរហាមបញ្ញា
ងប់លាភសក្តាតែងអស់តម្លៃ។

*-ងប់ងុលនឹងកុសល
តែងតែផ្តល់បានក្តីសុខ។

*ងប់ងុលនឹងពាក្យបញ្ចោរបញ្ចើច
បានត្រឹមគេសើចនៅពីក្រោយខ្នង។

*-ងប់ងុលនឹងសម្រស់
ច្រើនតែអស់នូវទ្រព្យធន។

*ងប់ងុលសម្រស់អាចអស់ធនទ្រព្យ
ងប់សម្តីងាប់ខួចយសប្រយោជន៍។

*ងារជាខុកញ៉ាព្រោះបានជួយជាតិ
ប៉ុន្តែកុំឆ្លៀតបំផ្លាញសង្គម។

ច ~ ឆ

*ចង់ក្លាយជាអ្នកអប់រំគេ
ត្រូវរិះរេស្វ័យពិនិត្យខ្លួនឯង។

*ចង់ឈ្នះត្រូវរៀនជំនះបញ្ហា
ស្របតាមស្ថានការណ៍ដែលអាចធ្វើបាន។

*ចង់ឈ្នះមិនបណ្តោះការហ្វឹកហាត់
នាំឲ្យបង់បាត់ធនធានមនសិការ។

*ចរិតខ្នះខ្នាយខ្វីខ្វា
គឺជាងារនៃវិនាស។

*ចរិតថ្លៃថ្នូរហើយសាមញ្ញ
គឺមិនចុះចាញ់ក្តីប្រមាទ។

*ចរិតបុគ្គលពាលមិនងាយកែ
បើសេពគប់ក្បែរនាំតែទារុណ។

*ចរិតមិនខ្មេះដែលមិនចេះខ្មាស់
គំនិតគ្រាន់ណាស់តែគ្មានតម្លៃ។

*ចរិតដល់ត្រើយសើយគួទ
មិនមែនជាពូជអ្នកជា។

*ចរិតប្រកាន់ខឹងមានះ
ព្រោះតែកញ្ជះនៃតណ្ហា។

*ចរិតប្រកាន់មានះឆាប់ខឹង
ព្រោះមិនខំប្រឹងសម្មាទិដ្ឋិ។

*ចរិតមានះដែលគ្មានហេតុផល
នាំទុក្ខកង្វល់ដល់អនាគត។

*ចរិតរើសអើង
ជាភ្លើងចំបើងបំផ្លាញសង្គម។

*ចាក់ដីខ្ពស់ព្រោះមិនចង់ឲ្យលិចទឹក
មិនបានជានឹកលិចផ្ទះអ្នកដទៃ។

*ចាក់ដីខ្ពស់ព្រោះមិនចង់ឲ្យទឹកលិច
លទ្ធផលសម្រេចលិចផ្ទះជិតខាង។

*ចាយតិចៗអាចសន្សំបាន
ចាយមិនប្រមាណក្រឆាប់ៗ។

*ចាស់តែកាយមានគំនិតថ្មី
គឺជានិស្ស័យនៃអ្នកដឹកនាំ។

*ចិត្តខឹងក្រោធច្រឡោតគុំគួន
កំពុងតែជួញរោគឥស្សា។

*ចិត្តគាប់និងទាស់នៅជិតគ្នា
គប្បីជនាត្រូវប្រយ័ត្ន។

*ចិត្តច្បាំងមិនឈ្នះក្តីកំណាញ់
ចិត្តច្បាំងតែងចាញ់ក្តីមានះ។

*ចិត្តជាបណ្ឌិតពិតលំបាកធ្វើ
ចិត្តពាលងាយធ្វើស្រួលជាងបណ្ឌិត។

*ចិត្តជាបណ្ឌិតមិនងាយធ្វើបាន
ចិត្តពាលសាមាន្យងាយធ្វើកន្លង។

*ចិត្តដែលល្អកម្រនឹងធ្វើបាន
ចិត្តពាលសាមាន្យគ្មានអ្វីពិបាក។

*ចិត្តមានះទទឹងរឹងរូស
បង្កជាព្យុះបរាជ័យ។

*ចិត្តមានះព្រោះចង់ឈ្នះចាញ់
គឺជាសំណាញ់នៃក្តីទុក្ខ។

*ចិត្តរង្កៀសច្រណែនឥស្សា
អារម្មណ៍ឈឺផ្សាគ្មានក្តីសុខ។

*ចិត្តសប្បុរសខ្មៅមិនអាចវាយតម្លៃបាន
គួរមើលសន្តានៃអំពើសប្បុរស។

*ចិត្តសុខព្រោះក្តីស្ងប់ស្ងាត់
កំចាត់វិបត្តិផងទាំងពួង។

*ចិត្តស្ងប់បង្កប់ឧបេក្ខា
ជាទីប្រាថ្នាអ្នកក្រោមម្លប់។

*ចិត្តស្ងប់បន្ទប់ទុក្ខព្រួយ
ជួយអារម្មណ៍ឲ្យសប្បាយ។

*ចិត្តស្ងប់
ព្រោះតែបង្កប់អារម្មណ៍ល្អ។

*ចិត្តស្ងប់មានសតិរព្ងឹក
នាំឲ្យមិនស្លឹកកាយវិញ្ញាណ។

*ចិត្តស្ងប់សតិពិចារណា
អាចស្រាយបញ្ហាឲ្យជោគជ័យ។

*ចិត្តអន្យតិរ្ថិយសាមាន្យ
មិនដែលកើតបានសាន្តត្រាណសុខ។

*ចិត្តអន្យតិរ្ថិយសាមាន្យ
មិនអាចកើតបានសាន្តត្រាណសុខ។

*ចិត្តអាក្រក់ល្អកុំសម្គាល់ត្រឹមពាក្យសម្តីថា
ពិនិត្យខ្លឹមសារវិចារវាយតម្លៃជាផលពិត។

*ចុងបិកតូចអាចធ្វើឲ្យបានលទ្ធផលធំ
ដូច្នេះគួរកុំចាំបានផលធំទើបធ្វើ។

*ចូរ! ច្បាំងនឹងភាពខ្ជិល
ដែលជាមន្ទិលនៃក្តីវិនាស។

*ចូររួមគ្នាទប់ស្កាត់កម្ចាត់រោគកូរ៉ូណា
ដោយប្រការសម្អាតអនាម័យជាចម្បង។

*ចំណងសាមគ្គីដ៏រឹងមាំ
គឺជាកម្លាំងខ្លះមិនបាន។

*ចំណីអាហារគ្មានអនាម័យ
កំពុងប្រល័យជនានុជន។

*ចំណីអាហារគ្មានអនាម័យ
គឺជាបច្ច័យគ្រោះដល់សង្គម។

*ចំណីអាហារជាអាវុធមុខពីរ
មួយឲ្យរស់ជីវីពីរគឺសម្លាប់។

*ចំណីអាហារដែលមានអនាម័យល្អ
នាំឲ្យសុខភាពបវរួបកាយមាំមួន។

*ចំណីអាហារមានសារធាតុគីមី
កំពុងសម្លាប់ជីវិអ្នកពិសា។

*ចំណីអាហារអនាម័យ
មានតម្លៃដល់សុខភាព។

*ចំណេះគ្មានទីបញ្ចប់
ប្រសប់មិនដែលគ្រប់ជ្រុង។

*ចំណេះដឹងកើន
ចម្រើនពីស្តាប់។

*ចំណេះដឹងគឺគ្មានដែនកំណត់
ចង់ចេះប្រាកដរៀនគ្មានឈប់ឈរ។

*ចំណេះដឹងពិតបានមកពីការរៀន
ន្ងរមេរៀនអ្វីដែលនៅជុំវិញខ្លួន។

*ចំណេះដឹងពិតត្រឹតចេះឈ្វេងយល់
ដែលជាឫសគល់នៃការសិក្សា។

*ចំណេះដែលមិនប្រាកដក្នុងប្រាណ
មិនអាចថ្កើងថ្កានជីវភាពប្រពៃ

*ចំណេះមិនបញ្ជាក់ត្រឹមសញ្ញាប័ត្រ
ការប្រតិបត្តិបានផលទើបប្រសើរ។

*ចេះដឹងដើមហេតុមកពីល្ងង់
ព្យាយាមប្រឹងគង់បានចេះដឹង។

*-ចេះត្រឹមវាចាធ្វើមិនសម្រេច
ពោលពាក្យប្ជរបាច់ថាគ្រាន់ជាងគេ។

*-ចេះថាតាមគេតែធ្វើមិនកើត
ពិតគ្មានកំណើតបានត្រឹមរោហា។

*ចេះពិតប្រាកដ
ឈប់ស្អប់ភាពល្ងង់។

*ចេះមិនដែលចប់
ប្រសប់មិនដែលជាប់។

*ចេះសូធ្យធម៌ចាំរត់មាត់
ដល់ប្រតិបត្តិឃ្លៀងឃ្លាតឆ្ងាយ។

*ចេះឲ្យសព្វសឹមធ្វើចៅកែ
ទើបមិនប្រែជាក្បុំយទ្រព្យធន។

*ច្បាប់គឺពេលវេលា បើមានងារគោរពច្បាប់
គឺត្រូវអនុវត្តទៀងពេល។

*ច្បាប់ជាពេលវេលា
ដែលបានផ្តល់ងារជាតម្លៃ។

*ច្បាប់ពិតក្នុងចិត្តគឺពេលវេលា
ដែលអ្នកគ្រប់គ្នាមានពីធម្មជាតិ។

*ច្រណែនមិនមែនជាជំនួយ
នាំតែទុក្ខព្រួយក្តៅដល់ជីវិត។

ច ~ ឆ

*ឆន្ទៈគឺអាចនៅបណ្តុះបាន
ចំពោះសន្តានធ្វើខុសហ៊ានកែ។

*ឆាកជីវិតដែលវែងឬខ្លី
គឺវាអាស្រ័យលើគំនិត។

*ឆាកជីវិតបានចែកចេញជាពីរ
មួយគឺជីវិ ពីរគឺគំនិត។

*ឆ្នាំថ្មីអាចប្រលែយក្លាយណា
បើបានបង្ការមិនដើរផ្តេសផ្តាស។

៩ ~ ៧

*ជក់បារីខ្លួចសុខភាពអ្នកនិងខ្ញុំ
ដូច្នេះសូមកុំពិសាប៉ារី។

*-ជនជាបណ្ឌិតគំនិតប្រសើរ
មិនប្រព្រឹត្តធ្វើអំពើបាបឡើយ។

*ជនពាលមិនងាយស្តាប់សម្តីពិត
ឯជនបណ្ឌិតស្តាប់ហើយពិចារណា។

*ជាតិស្លាប់រស់ព្រោះញាតិមិត្តក្នុងសង្គម
មិនរស់ជួបជុំខ្វះការលះបង់ចែករំលែក។

*ជិតក៏បុណ្យឆ្ងាយក៏បុណ្យ
ឱ្យតែគ្រប់ជនតាំងចិត្តប្រតិបត្តិ។

*ជីវភាពមនុស្សដែលរស់នៅលើលោក
អ្នកធ្វើថាថោកអ្នកមើលមកឃើញថាថ្លៃ។

*ជីវិតតិចខំច្បិចសន្សំបាប
នាំតែបន្សាបនូវគុណតម្លៃ។

*ជីវិតចៅកថ្លៃ
អាស្រ័យអំពើ។

*ជីវិតប្រៀបដូចពពកសាត់
ត្រូវថែប្រយ័ត្នឃ្លាតពីកាយា។

*ជីវិតពិតជាខ្មៅងងឹត
នៅពេលមិនគិតខំសិក្សា។

*ជីវិតស្លាប់ពិតតែវិញ្ញាណរស់
ទើបជាកិត្តិយសរស់ឧត្តម។

*ជីវិតស្លាប់រស់ខាងមុខមិនទៀង
គប្បីចិត្តរាងសាងបាបជាផល។

*ជីវិតអ្នករស់ព្រោះធម្មជាតិ
ជាតិល្បីឈ្មោះព្រោះសង្គមល្អ។

*ជួយអ្នកតោកយ៉ាកគួរតែមើលគេ
ខំជួយខ្លួនទេពេលដែលលំបាក។

*ជួយអ្នកទន់ខ្សោយឲ្យមានស្មារតី
ជាអ្នកប្រពៃប្រសើរកន្លង។

*ជឿឲ្យមានហេតុ
មិនប្រមាទមិនសោកា។

*ជោគជ័យគួររំពៃពីលទ្ធផល
គំនិតនាំដល់ចំគោលដៅពិត។

*ជោគជ័យតែគ្រួសារម្នាក់ឯង
នាំសោកសង្រែងដល់សង្គម។

*ជោគជ័យអាស្រ័យលើទំនាក់ទំនង
កើតពីគន្លងដោយការប្រតិបត្តិ។

*ជំងឺច្រណែនសែនឈឺចុកចាប់
កំពុងសម្លាប់នូវមនសិការ។

*ជំងឺអាត្មានិយម
នាំឲ្យសង្គមវិនាស។

*ជំងឺអារម្មណ៍បង្ខូរបកាយ
ធ្វើការជិនណាយចិត្តមិនបរិសុទ្ធ។

*ជំនាញពឹងចំណេះ
ក្រោយពីចេះទើបមានជំនាញ។

*ជំនឿដែលគ្មានហេតុនិងផល
នាំទុក្ខកង្វល់ដល់អាត្មា។

*ជំពាក់ត្រូវជឿជាក់អាចដោះបំណុល
កុំឲ្យខ្វល់អារម្មណ៍កំពុងជំពាក់។

*ជំពាក់ត្រូវជឿជាក់អាចដោះបំណុល
ដែលនាំឲ្យខ្វល់អារម្មណ៍កំពុងជំពាក់។

*ជិះកង់ថោកឲ្យចរិតថ្លៃ
ជាងជិះឡានថ្លៃតែចរិតថោក។

*ជ្រលក់សម្តីឈ្លោះនឹងពាលនាំបង់យស
ស៊ូតតាំងឈ្លោះនឹងបណ្ឌិតកើតបញ្ញ។

ឈ ~ ឈ

*ឈ្នះប្រាកដបានមកពីការចាញ់
ដួលហើយក្រោកវិញរិះរកភាពឈ្នះ។

*ឈ្លើងសង្គមធ្មិពីមន្ត្រីដៃភ្លាត់
កិបកេងប្រាក់រដ្ឋទុកជាទ្រព្យផ្ទាល់ខ្លួន។

*-ឈ្លោះគ្នានៅក្នុងគ្រួសារ
ដូចស្រែតកាយបង្ហាញញាតិ។

ញ ~ ញ

*ញញឹមរាក់ទាក់
ជាទីពំនាក់នៃអ្នកដទៃ។

*ញ៉ាំអ្វីចោលសំរាមលើក្រោមតុ
ផ្តល់ផលអាក្រក់កិត្តិយសខ្លួនឯង។

*ញ៉ាំអ្វីៗចូរកុំភ្លេចភ្លាត់
ជុះធ្មេញខ្មុរមាត់ជាប្រចាំ។

៨ ~ ៧

* ដឹកនាំគួរគិតពីលទ្ធផល
ទើបបានដល់អ្នកដឹកនាំល្អ។

* ដឹកនាំគ្មានយន្តការត្រួតល្អ
រាយការណ៍បន្តភ្លូតបណ្តាក់។

* ដឹកនាំជាប្រយោជន៍សម្រាប់គេ
ចំណែកខាងជើរសម្រាប់ខ្លួនឯង។

* ដឹកនាំធ្វើល្អតែងមានបញ្ហា
ប៉ុន្តែផ្តែផ្តាំដល់ជាតិសង្គម។

* ដឹកនាំមិនឲ្យគេជួបក្តីវិនាស
គឺមិនអាចចៀសរួចពីពាក្យគេជេរ។

* ដឹកនាំឲ្យគេខ្លាចបានត្រឹមខ្លើមស្អប់
ដឹកនាំប្រសប់បានបេះដូងស្រឡាញ់។

* ដឹងខុសរួចចេះកែ
ព្រោះតែបានទូន្មានចិត្ត។

* ដឹងថាពាលគួរគេចឲ្យឆ្ងាយ
ទើបមិនអន្តរាយដល់អាត្មា។

* ដឹងថាល្ងង់ខំប្រឹងចេះ
ជាប្រឆេះនៃបណ្ឌិត។

* ដឹងថាល្ងង់គង់ក្លាយជាចេះ
ប្រហោងចំណេះល្ងង់ត្រួតត្រា។

* ដឹងល្ងង់គង់ព្យាយាមចេះ
នូវចំណេះដែលនៅល្ងង់។

* ដឹងល្អអាក្រក់ទ្រាំធ្វើមិនបាន
ព្រោះតែសន្តានចិត្តប្រចុះជួន។

* ដើម្បីទទួលផលប្រឹងប្រែងខ្វាយខ្វល់ដោយលំបាក
ភាពគោកយ៉ាកកើតមានឆាប់ ព្រោះ
មិនខ្វល់ខ្វះការថែ។

* ដើម្បីឲ្យសហគមន៍យល់ពីសាលារៀន
គួរគ្រូបង្រៀនរៀនឲ្យយល់ពីសហគមន៍។

*ដើរតែរៀនមិនដែលបានជួយធ្វើ
ខាតឥតអំពើគ្មានជួយសង្គម។

*ជាំពូជគំនិតផលពិតបញ្ញា
ជាំពូជមនសិការផ្តែផ្កាសង្គម។

៥ ~ ៧

*ឋានៈកិត្តិយសពឹងអាស្រ័យខាងក្រៅ
ចិត្តបុណ្យមិនខ្ចៅទីអាស្រ័យសប្បុរស។

*-ឋានៈខ្ពង់ខ្ពស់រស់បានឧត្តម
កុំឲ្យរាស្ត្រយំព្រោះតែបុណ្យសក្តិ។

៨ ~ ៩

*-ឪដងជាក់គ្នាជារឿងទំនាស់
អ្វីដែលខុសទាស់គឺចិត្តមានះ។

ឲ ~ ឳ

*លោលិនប្រែថាអ្នកច្បាំងមានខែលការពារ
សិក្ខាគ្រប់គ្នាមានវិជ្ជាធ្វើជាខែល។

឴ ~ ឵

*- ណាស់ខាងបាបឆ្អាបខ្លួនជាប់ស្អិត
ណាស់ខាងសុចរិតចិត្តល្អទៀងត្រង់។

ា ~ ី

*តម្កើងខ្លួនចេះតែមិនខ្វល់ដឹង
កំពុងខំប្រឹងរកក្តីវិនាស។

*តម្កើងពាលហួស
នាំគ្រោះអន្តរាយ។

*តម្លៃការងារចំណុះលើអ្នកធ្វើ
បើថាមិនធ្វើអំពើឥតប្រយោជន៍។

*តម្លៃការងារពឹងសមត្ថភាពមារយាទ
ប្រឹងប្រែងខ្មីឃ្មាតដោយមានមនសិការ។

*តម្លៃការហ៊ានលះបង់
គឺអាចស្រោចស្រង់ស្ថានការណ៍។

*តម្លៃជីវិតមិនពឹងអាស្រ័យលើបុគ្គលជោគជ័យ
តម្លៃមានន័យគឺជីវិតជោគជ័យបានជួយសង្គម។

*តម្លៃថោកថ្លៃមិនអាស្រ័យអ្នកឱ្យ
គឺថ្លៃថោកដោយមារយាទខ្លួនឯង។

*តម្លៃនៃទ្រព្យរបស់ មិនបានប្រើសោះ
ក៏ជាចំណែកនៃការចំណាយ។

*តម្លៃពិតមិនស្ថិតលើការនិយាយល្អ
ប្រព្រឹត្តស្មោះសនោះទើបជាតម្លៃពិត។

*តម្លៃមិនអាស្រ័យត្រឹមប្រាក់ស័ក្តិយស
កេរ្តិ៍ឈ្មោះពីរោះជាកិត្តិយសប្រពៃ។

*តម្លៃអាស្រ័យដោយទង្វើ
សុចរិតធ្វើជាប្រចាំ។

*តួនាទីកាន់តែខ្ពស់ដាក់ខ្លួនឲ្យទាប
ទើបជារបៀបដឹកនាំមានការចូលរួម។

*តើថោកអ្វីនឹងធ្វើអំពើល្អ
តើក្រអ្វីធ្វើមារយាទឲ្យថ្លៃ។

*តំណែងខ្ពង់ខ្ពស់ដាក់ខ្លួនឲ្យទាប
ទើបជាមារយាទនៃអ្នកបម្រើ។

*តំណែងខ្ពង់ខ្ពស់ដាក់ខ្លួនឲ្យទាប
ទើបជារបៀបធ្វើការជោគជ័យ។

*ត្រកួនភ្លេចបឹងក្លាយជាអន្លក់
នាំឲ្យចង់ភ្លក្សក្តិចត្រួយលក់ធី។

*ត្រកួនភ្លេចបឹងព្រោះតែឈ្លក់ទឹក
ដឹកនាំវរវីកព្រោះឈ្លក់អំណាច។

*ត្រូវខុសមិនកំណត់ត្រឹមការគិត
អ្វីខុសត្រូវពិតគឺផលជាក់ស្តែង។

*ត្រូវបែងចែកជាច់ជាមួយខុស
បើចាប់កំហុសខុសព្រមគ្នា។

*ត្រូវរស់ឲ្យបានគាប់
ទើបមិនងាប់សន្ដាន។

*ត្រូតពិនិត្យកំពុងធ្វើញយៗ
ទើបមិនច្ឆោះឆ្ឆោយនូវរាល់ផែនការ។

៥ ~ ៦

*ចោកក៏ចោកចុះឲ្យតែថ្លៃ
កុំឲ្យតែថ្លៃតម្លៃចោក។

*ចៅកែដែលដឹងរាក់ជ្រៅ
ព្រោះធ្លាប់នៅជាកម្មករ។

*ថ្ងៃណាក៏ជាថ្ងៃបុណ្យដែរ
ឲ្យតែខ្មែរព្រមប្រតិបត្តិ។

*ថ្នាក់ក្រោមចេះភ្ជួត
មកពីលើឆោតគាំទ្រជោគជ័យ។

ឆ ~ ឋ

*ទង្វើខុសត្រូវខ្លួនឯងអាចដឹង
គួរកុំខំប្រឹងប្រើពាក្យដោះសា។

*ទង្វើដែលធ្វើមិនចេះខ្មាស
នាំឲ្យអាម៉ាស់ដល់សង្គម។

*ទង្វើបង្ហាញពីផ្នត់គំនិតមារយាទ
បុគ្គលចោលម្សៀតឬថ្លៃថ្ងៃអនាគត។

*ទង្វើរបស់ឪពុកម្តាយ
ត្រាប់តាមបានងាយពីកូនចៅ។

*ទង្វើអាក្រក់តាមលងអាត្មា
ធ្វើល្អវិញណាសន្តានរីករាយ។

*ទម្លាប់ភូតភរ មានអ្នកគាំទ្រឲ្យចេះកុហក។

*ទស្សនកិច្ចច្រើន ចម្រើនដល់បញ្ញា។

*ទស្សនកិច្ចច្រើន ចម្រើនបញ្ញា ថ្លាដល់គំនិត។

*ទស្សនកិច្ចសិក្សា គឺការសិក្សាពីជីវិតខាងក្រៅ។

*ទស្សនៈមិនបៀតបៀនអ្នកដទៃ
គឺទស្សនៈមានន័យប្រសើរកន្លង។

*ទស្សនវិស័យ÷

-រៀនឲ្យចេះគិតបង្កើតនូវគំនិតថ្មី

-រៀនឲ្យមានស្មារតីចេះច្នៃប្រតិដ្ឋ

-រៀនឲ្យមានមិត្តចេះជួយមិត្តជាប្រចាំ។

*ទីកន្លែងណាមានសំរាម
ស្តែងចរិតកម្មនៅទីនោះ។

*ទីណាមានសំរាម អ្នកគ្រប់គ្រងទីនោះមាន
សមត្ថភាពទាបជាសំរាម។

*ទឹកចិត្តភក្តី
គឺមានអត្ថន័យកាត់ថ្លៃមិនបាន។

*ទឹកលាងជម្រះនូវមន្ទិល
ភាព័ខ្ចិលជម្រះដោយឧស្សាហ៍។

*ទឹកឡើងប្រជែងគ្នាចាក់ដីខ្ពស់
ដល់ពេលរងគ្រោះទឹកលិចទាំងអស់គ្នា។

*ទឹកអាចជម្រះនូវមន្ទិល
ខ្ចិលជម្រះដោយការព្យាយាម។

*ទំនិញអ្នកមានទិញមិនហ៊ានត
ទំនិញអ្នកក្រទិញតថ្លៃឲ្យថោក។

*ទោះបីគ្រូខំប្រឹងយ៉ាងណា គ្មានកិច្ចសហការពីគ្រួសារ
កុមារគ្មានការអភិវឌ្ឍ។

*ទ្រព្យធនចាយមិនគិតបំផ្លាញប្រាណ
ក្រតាមទាន់បានព្រោះក្តីប្រមាទ។

*ទ្រព្យធនធានប្រើបានជាប្រយោជន៍
ទើបមិនអសោចខ្វះពូជតកេរ្តិ៍។

*ទ្រព្យធនធានមានមិនចេះប្រើ
អាចប្រៀបស្មើនឹងមហន្តរាយ។

*ទ្រព្យធនមានចាយខ្ជះខ្ជាយមិនងាយរកវិញបាន
អាចក្រតសន្តានព្រោះចាយវាយគ្មានគំនិត។

*ទ្រព្យបានមកដោយពិបាករក
កុំឲ្យរបូតពីដៃងាយ។

*ទ្រព្យមានឬក្រព្រោះតែមារយាទ
ក្រវើនខំឆ្លៀតខ្ជះខ្ជាយសំចៃ។

*ទ្រព្យសម្បត្តិរកបានពីអំពើល្អ
ទើបមិនកម្រងាយបាត់បង់វិនាស។

*ទ្រឹស្តីជាមាគ៌ាពិតប្រាកដ
សម្រាប់អ្នកហ្មត់ចត់ក្នុងការងារ។

*ទ្រឹស្តីមានច្រើនសម្បរបែបណាស់
ប៉ុន្តែនៅខ្វះអនុវត្តន៍ជាក់ស្តែង។

*ទ្រឹស្តីដែលមានឬគ្មានតម្លៃ
ពំនាក់អាស្រ័យការប្រតិបត្តិ។

ច ~ ឆ

*ធនធានមនុស្សជាកម្លាំងទីពីរ
បញ្ញាមូលមីអង្គភាពខ្ពង់ខ្ពស់។

*ធម្មជាតិជួយជីវភាពមនុស្ស
ដោយយកចំណេះទៅប្រើវា។

*ធម្មជាតិជួយមនុស្ស
ពេលយើងចេះរក្សាថែ។

*ធម្មជាតិធ្វើឲ្យជីវិតរស់
បើយើងទាំងអស់ចេះការពារ។

*ធម្មជាតិបម្រើមនុស្ស
ពេលអភិវឌ្ឍដោយសក្តា។

*ធម្មជាតិបំផ្លាញមនុស្ស
ពេលណាមនុស្សបំផ្លាញធម្មជាតិ។

*ធម្មជាតិពំនាក់មនុស្ស
រីឯមនុស្សពឹងធម្មជាតិ។

*ធម្មជាតិសម្លាប់មនុស្ស
ពេលក្រុមមនុស្សបំផ្លាញវា។

*ធ្វើជាម្តាយគ្មានអ្វីរីករាយ
ជាងឃើញការសិក្សាកូនរីកចម្រើនជាង
មុននោះទេ។

*ធ្វើមិនឲ្យគេជឿលើខ្លួនឯងងាយ
ធ្វើឲ្យពណ្តាយគឺមិនងាយស្តារបាន។

*ធ្វើអាក្រក់កុំថាគេមិនដឹង
គប្បីខំប្រឹងព្យាយាមកែប្រាណ។

*ធ្វើឲ្យគេស្រឡាញ់មិនងាយទេ
ធ្វើឲ្យគេជេរជាការងាយណាស់។

*ធ្វើអ្វីកុំតាមគេប្រាប់ ជាទម្លាប់មិនប្រពៃ
ធ្វើអ្វីតាមការឆ្មៃ ឲ្យមានន័យ ទើបប្រសើរ។

*ធ្វើអ្វីកុំត្រូវតែចិត្តអ្នកថា
គួរធ្វើយ៉ាងណាត្រូវចិត្តអ្នកធ្វើ។

*ធ្វើអ្វីគង់តែអ្នកដទៃដឹង
ប៉ុន្តែខំប្រឹងលាក់ភ្នែកបំភ្លៃ។

*ធ្វើអ្វីគប្បីឲ្យមើលកាល
ទើបមិនបណ្តាលខូចការធំ។

*ធ្វើអ្វីៗដើម្បីទទួលផល
ជាងគិតមិនដល់ធ្វើដើម្បីធ្វើ។

*ធ្វើអ្វីដែលមានហេតុនិងផល
ទើបសម្រេចដល់បំណងប្រាថ្នា។

*ធ្វើអ្វីបើមិនចង់ឲ្យគេដឹង
គួរកុំខំប្រឹងធ្វើមិនគប្បី។

*ធ្វើអ្វីឲ្យតែគេថាធ្វើ
ខាតឥតអំពើគ្មានប្រយោជន៍។

ឆ ~ ឯ

* នាយកធមិមានទាំងប្រាំមួយ
ពិតជាលើកស្ទួយតម្លៃដឹកនាំ។

* នាយកជាកម្លាំងចលករចូលរួម
ត្រូវចេះបង្រួមគំនិតជាធ្លុងមួយ។

* នាយកល្អ
គឺជាសសរសហគមន៍ចូលរួម។

* និយាយតិចតែធ្វើកើតច្រើន
ទើបចម្រើនដល់ជាតិសង្គម។

* និយាយមិនរំខានអ្នកដទៃ
ជាអធ្យាស្រ័យនៃមនុស្សល្អ។

* និវត្តន៍ជនសល់ពេលវេលាកាន់តែតិច

ច្បិចជួយសង្គមគឺជាបុណ្យដ៏ប្រសើរ។

* នៅជាមួយគ្នាចេះតែខុសទាស់

ពេលបែកគ្នាអស់ទើបនឹកសោកស្តាយ។

* នៅពេលឮកុំប្រញាប់និយាយ

នាំឲ្យអន្តរាយដោយស្តាប់ច្រឡំ។

* នាំពាលសាងល្អមិនដែលស្រណុក

ព្រោះចិត្តមិនសុខចង់ឲ្យគេល្អ។

ច ~ ប

*បង្គ ក្តាប់ ឆក់ ឆ្លៀត ឱកាស
គឺជាយុទ្ធសាស្ត្រអ្នកដឹកនាំ។

*បង្គជម្លោះគ្មានផលចំណេញ
បើត្រូវគ្នាវិញចំណេញទាំងសង។

*បង្គឱកាសដល់ថ្នាក់ក្រោមសប្បាយ
ជានយោបាយនៃការដឹកនាំ។

*បង្កើតខ្ញុំសម្រាប់បម្រើអ្នក
ម្តេចគ្មានឆន្ទៈថែរក្សាខ្ញុំ។

*បង្រៀនគេភ្លេចរៀនខ្លួនឯង
គ្រោះរមែងធ្លាក់ដល់សង្គម។

*បង្រៀនគេភ្លេចរៀនខ្លួនឯង
ជាគ្រោះក្រៃលែងដល់សង្គម។

*បង្រៀនមានកិច្ចតែងការ
ប្រៀបដូចចង្វាអុំទូកទៅមុខ។

*បង្រៀនឲ្យចេះទទួលខុសត្រូវ
គឺលំនាំផ្លូវក្លាយជាមនុស្សល្អ។

*បញ្ញានាំឲ្យថ្លាគំនិត
ឲ្យអ្នកចេះគិតនូវរឿងល្អ។

*បញ្ហាតូចកុំទុកឲ្យធំ
គប្បីត្រូវផ្តុំពន្លត់បញ្ហា។

*បណ្ឌិតគប្បីធ្វើជាប្រយោជន៍
កុំឲ្យអសោចខ្ចះកេរ្តិ៍សង្គម។

*បណ្ឌិតគេចពាលទាល់តែចាកស្រុក
បើចង់ស្រណុកត្រូវខំពីក្មេង។

*បណ្ឌិតដែលងងឹតនូវចំណេះ
ព្រោះមិនប្រឹងចេះវិជ្ជាបន្ត។

*បណ្ឌិតជជែកជាមួយពាលចោលម្យៀត
ដូចយកក្លៀកត្បៀតជរំពៅចោកអស្ចារ្យ។

*បណ្ឌិតដែលចាត់ទុកថាមានយស
តែងជួយសង្គ្រោះលើកស្ទួយសង្គម។

*បណ្ឌិតតែឈ្មោះកិត្តិយសគ្មាន
ជីវិតរស់រានមិនមានតម្លៃ។

*បណ្ឌិតតែឈ្មោះកិត្តិយសមិនយូរ
ព្រោះគ្មានគំរូទុកជាប្រយោជន៍។

*បណ្ឌិតតែឈ្មោះបញ្ញាមិនគាប់
ព្រោះគ្មានទម្លាប់បន្តសិក្សា។

*បណ្ឌិតទូន្មានចង់ឲ្យស្រណុក
ត្រាប់ពាលមិនសុខរមែងជួបភ័យ។

*បណ្ឌិតធ្វើអ្វីប្លែកៗពីគេ
បានត្រឹមពាក្យជេរតែមានប្រយោជន៍។

*បណ្ឌិតប្រើមធ្យោបាយទុន្មាន
គ្មានគិតបៀតបៀនដល់អ្នកដទៃ។

*បណ្ឌិតពិត
តែងមានគំនិតចង់ជួយអ្នកដទៃ។

*បណ្ឌិតពិត
តែងមិនប្រព្រឹត្តមារយាទមនុស្សពាល។

*បណ្ឌិតមានច្រើនណាស់
ប៉ុន្តែនៅខ្វះបណ្ឌិតជាប្រយោជន៍។

*បណ្ឌិតមានច្រើនអនេក
ប៉ុន្តែចម្លែកខ្វះនូវបណ្ឌិតពិត។

*បណ្ឌិតមានត្រឹមតែសញ្ញាប័ត្រ
អាចនាំឲ្យវិបត្តិដល់សង្គម។

*បណ្ឌិតមានៈ
តម្កើងចិត្តឈ្នះ វិនាសខ្លួនឯង។

*បណ្ឌិតមានៈវិនាសអាត្មា
ព្រោះមិនត្រូវការមតិទូន្មាន។

*បណ្ឌិតសាងល្អកម្រពាលសាទរ
ព្រោះពាលវឹកវរសាងអំពើអាក្រក់។

*បណ្ណាល័យ
គឺជាបាវសម្រាប់ឲ្យអ្នកប្រើចូលស្រាវជ្រាវ។

*បណ្ណាល័យដែលមានប្រយោជន៍
ត្រង់អ្នកចេះប្រើប្រាស់ឲ្យបានជាប្រយោជន៍។

*បទពិសោធន៍ដែលចែករំលែក
អាចក្លាយជាមែកយកទៅដាំ។

*បទពិសោធន៍ល្អជិតមិនដែលមើល
ព្រោះខ្លាចការធ្វើតាមគេវាអន់។

*បរាជ័យមិនមែនជារឿងអាស្រូវ
ប៉ុន្តែជាផ្លូវនូវពិសោធន៍ពិត។

*បរិមាណបង្ហាញពីគុណភាព
រីការឆ្លៀវឆ្លាតបង្ហាញពីសមត្ថភាពប្រពៃ។

*បរិមាណបានពីគុណភាព
បរិមាណទាបគុណភាពអន់។

*បរិមាណរីកចម្រើន
គឺបានចាប់ផ្តើមពីគុណភាព។

*បរិស្ថានបរិសុទ្ធស្អាតបាន
ព្រោះមិនរំខានពីមហាជន។

*បរិស្ថានរងគ្រោះ
ព្រោះជនទុយិសបំផ្លាញ។

*បរិស្ថានរស់
ផ្តើមពីហ៊ានឈ្លោះព្រោះបរិស្ថាន។

*បរិស្ថានស្អាត
បង្ហាញភាពឆ្លាតនៃអ្នកដឹកនាំ។

*បាត់បង់វេលាអាចអស់ឱកាស
កម្រមានណាស់ឱកាសច្រើនដង។

*បិសាចសំរាមជំរប្ញាស្មុក
កំពុងកម្ទេចជីវិតបរិស្ថាន។

*បុគ្គលគ្រប់រូបសុទ្ធសឹងតែមានកំហុស
ករណីធ្វើខុសចេះកែជាបុគ្គលថ្លៃ។

*បុគ្គលចរិតថោកមិនថ្លៃ
គង់តែមានថ្ងៃអស់អាសា។

*បុគ្គលចេះគោរពកោតក្រែង
មិនដែលសម្តែងវាយឫកខ្ពស់។

*បុគ្គលចេះគ្មានចំណេះក្នុងខ្លួន
គឺសម្បុំពួនចរិតបោកប្រាស់។

*បុគ្គលចិត្តមានះឥស្សា
បានត្រឹមឈឺផ្សាក្តៅក្រហាយ។

*បុគ្គលច្រណែនឈ្នានីស
មិនអាចចៀសពីអន្តរាយ។

*បុគ្គលជាអាត្មានិយម
មិននាំសង្គមឲ្យជោគជ័យ។

*បុគ្គលជោគជ័យដោយចេះចែករំលែក
ទើបបានជាផ្នែកជោគជ័យពិតប្រាកដ។

*បុគ្គលជោគជ័យធាតុអាត្មានិយម
អាចនាំសង្គមវិនាសអន្តរាយ។

*បុគ្គលដទៃមានកំហុសគឺមិនសំខាន់
គប្បីប្រកាន់កុំខុសខ្លួនឯងទើបប្រពៃ។

*បុគ្គលដែលចិត្តសប្បុរសស្មោះ
មិនចង់បានសោះពីការតបគុណ។

*បុគ្គលដែលចេះគោរពកោតក្រែង
ទូន្មានរមែងបានជាសប្បុរស។

*បុគ្គលដែលពឹងឲ្យតែគេជួយ
ស្មារតីផ្តេកផ្តួលពឹងគេរហូត។

*បុគ្គលដែលមានឬគ្មានតម្លៃ
គឺពឹងអាស្រ័យទង្វើខ្លួនឯង។

*បុគ្គលតម្កើងបូកតាំងខ្លួនហាំ
កំពុងខិតខំធ្វើជាសត្វហ៊ីង។

*បុគ្គលថោកថ្លៃមិនអាស្រ័យមុខតំណែង
សមត្ថភាពជាក់ស្តែងជួយសង្គមទើបថ្លៃពិត។

*បុគ្គលថោកថ្លៃអាស្រ័យទង្វើ
ដែលជាអំពើផលអាក្រក់ល្អ។

*បុគ្គលនៅតែក្នុងវង់ល្បែងស្រា
ចង់ធ្វើអាចារ្យអ្នកណាគេស្តាប់។

*បុគ្គលបំពេញភារកិច្ចបានល្អ
នាំថ្លៃបវរដល់សម្ងួហភាព។

*បុគ្គលប្រព្រឹត្តតែល្បែងស្រីស្រា
ចង់ធ្វើអាចារ្យអ្នកណាគេជឿ។

*បុគ្គលពាលជេរស្តីគឺគ្មានតម្លៃ
ពាក្យទូន្មានថ្លៃគឺសម្តីបណ្ឌិត។

*បុគ្គលពាលមិនងាយពោលពាក្យឲ្យថ្លៃ
ព្រោះតែនិស្ស័យអប់រំពីបុព្វេ។

*បុគ្គលមិនស្គាល់តម្លៃខ្លួនឯង
គឺរមែងតែងជួបក្តីវិនាស។

*បុគ្គលមិនហ៊ានមើលធ្វើអំពើល្អ
ព្រោះខ្លាចគេបវរប្រសើរខ្ពស់ជាងខ្លួន។

*បុគ្គលរស់គួរចេះឲ្យតម្លៃ
កុំចាំក្បិណក្បុយទើបលើកសរសើរ។

*បុគ្គលរស់ដើម្បីជាតិរស់
ជាកេរ្តិ៍ឈ្មោះប្រសើរឧត្តម។

*បុគ្គលលេងចរិតដោយលង់អំណាច
ដៃកោងមាត់កាចព្រោះខ្លាចគេថាអន់។

*បុគ្គលសិក្សាពីគេខ្លាចអន់
ទោះបីខំបន់ក៏គ្មានតេជះ។

*បុគ្គលស្កប់ស្កល់នឹងចំណេះ
គិតថាគេចេះមិនដល់អញ។

*បុណ្យកើតពីទឹកចិត្តមានសទ្ធា
ចែករស់ដល់គ្នាដោយក្តីមេត្តា។

*បុណ្យគឺកសាងនូវអំពើល្អ
អ្នកគ្រប់ស្រករត្រូវប្រតិបត្តិ។

*បុណ្យជិតខ្លួនជាមួយឪពុកម្តាយ
បុណ្យរាប់ថាឆ្ងាយមិត្តញាតិបងប្អូន។

*បុណ្យជិតៗច្រើនតែមើលរំលង
បើឆ្ងាយវិញផងធ្វើដោយមហិច្ឆតា។

*បុណ្យជុំវិញខ្លួនមិនចូលចិត្តធ្វើ
បើឆ្ងាយវិញមើលមិនដោយបញ្ញា។

*បុណ្យធ្វើប្រកបដោយបញ្ញា
ផលពិតផ្តែផ្តាដល់សង្គម។

*បុណ្យនិងបាបតែងចែកដាច់ពីគ្នា
គួរតែជនារើសយកខាងបុណ្យ។

*បុណ្យនិងបាបមាននៅតែក្នុងចិត្ត
តាមការប្រព្រឹត្តនៃកិច្ចការងារ។

*បុណ្យនិងបាបមាននៅក្នុងចិត្ត
យើងអ្នកប្រតិបត្តិរៀនរាល់ថ្ងៃ។

*បុណ្យបាបស្ថិតនៅលើចិត្ត
ការប្រព្រឹត្តជាប្រចាំ។

*បុណ្យប្រែថាការធ្វើអំពើល្អ
ម្តេចប្រជានិករមិនព្រមប្រតិបត្តិ។

*បុណ្យកើតមានជារៀងរាល់ថ្ងៃ
ឲ្យតែហ្មទ័យឆ្ងាយពីបាប។

*បុណ្យមិនចាំបាច់ទាល់តែទៅវត្ត
ជួយជនទុគ៌តក៏គង់បានបុណ្យ។

*បុណ្យមិនសំខាន់ត្រឹមមានលំដាប់កម្មវិធី
ការជួយជីវិមនុស្សសត្វផុតទុក្ខជាបុណ្យថ្លៃ។

*បុណ្យស័ក្តិខ្ពស់គួរដាក់ខ្លួនឲ្យទាប
ទើបជាមារយាទនៃអ្នកដឹកនាំ។

*បុណ្យស័ក្តិប្រាក់មាសយសគ្រាន់តែជាឈ្មោះ
ចិត្តសប្បុរសខ្ពស់ជាកិត្តិយសលោកីយ៍។

*បុណ្យស្រុកយើងមានច្រើនអនេកណាស់
អ្នកស្គាល់បុណ្យច្បាស់មានដោយកម្រ។

*បុណ្យមានជារៀងរាល់ថ្ងៃ
ឲ្យតែឃ្លាតឆ្ងាយពីបាប។

*បុគ្គលិកធ្វើខុស
ជាកំហុសរបស់មេដឹកនាំ។

*បើកាច់ឫកហ៊ាមិនខំប្រឹងធ្វើ
គឺជាអំពើបាត់យសតម្លៃ។

*បើកំសាកតាំងខ្លួនគ្រាន់បើ
គឺជាដំណើរចិត្តគោកយ៉ាក។

*បើកំសាកមិនហ៊ានធ្វើអំពើត្រឹមត្រូវ
គឺអាចជាផ្លូវនាំទៅរកក្តីវិនាស។

*បើក្រឡិចចាយច្រើន
ក្រវើនឲ្យក្រឆាប់។

*បើក្រទ្រព្យគេអាណិតមេត្តា
បើគេស្តីថាព្រោះក្រមារយាទ។

*បើក្រទ្រព្យអាចនឹងសង្ឃឹមរកបាន
មារយាទសន្តានក្រគឺតត្រកូល។

*បើក្រព្រោះធម្មជាតិអាចមានញាតិជួយ
ក្រខ្ចិលរលួយព្រះក៏ជួយមិនបាន។

*បើក្រឲ្យសំចៃ
គង់មានថ្ងៃអភិវឌ្ឍ។

*បើខុសចេះកែទើបប្រែចរិត
រឹករវប្រមឹកមិនកែមារយាទ។

*បើខុសមិនចេះកែប្រែ
ប្រៀបដូចមិនកែចរិត។

*បើខុសហ៊ានកែកំហុស
គឺអាចមានឈ្មោះប្រពៃ។

*បើខ្ពង់ខ្ពស់ពេកគេច្រណែន
បើទាបវិញសែនគេមាក់ងាយ។

*បើខ្ពស់តែឯងដូចខ្លែងហើរគ្មានគូ
ប្រឹងធ្វើយូរៗគង់តែត្រដុសខ្យល់។

*បើខ្លាចក្រគង់ក្លាយជាមាន
ប៉ុន្តែក្រហ៊ានព្រោះខ្លាចថាក្រគឺកំពុងត្រដរស់។

*បើគិតពីហេតុឲ្យរំពឹងផល
នោះទើបបានដល់គំនិតអ្នកធ្វើ។

*បើគិតថាមានចំណេះដឹងគ្រប់គ្រាន់
ត្រូវតែបន្ទន់ន្ទូវសតិស្មារតី។

*បើគេខឹងព្រោះខំប្រឹងសាងល្អ
កុំល្អក់កករនាំខូចចិត្តបុណ្យ។

*បើគេខឹងព្រោះតែមិនដឹងខុស
មិនមែនកំហុសអ្នកទូន្មានទេ។

*បើគេជេរព្រោះមិនទាន់យល់
គួរតែយោគយល់ប្រទូស្តខឹង។

*បើគេដេញគួរគេចកុំរត់
គប្បីអត់ធ្មត់រកឧបាយ។

*បើគេថាបានចេះចាំធ្វើគិត
ព្រោះគ្មានគំនិតគិតដោយបញ្ញា។

*បើគេធ្វើអាក្រក់កុំសងត
ព្យាយាមធ្វើល្អមិនបង្កភ័យ។

*បើគ្មានគំនិតគឺគ្មានកំណើត
មិនអាចកកើតទៅជាទ្រព្យធន។

*បើគ្មានសតិគ្រប់គ្រងមារយាទ
រស់ក្នុងមួយជាតិគឺគ្មានតម្លៃ។

*បើគ្រាន់តែឮនិយាយតាមគេ
មិនគប្បីទេនាំបាត់តម្លៃ។

*បើគ្រាន់តែស្តាប់ បាត់ការចងចាំ
២៥-៣០ក្នុង២៤ម៉ោង។

*បើគ្រាន់តែស្តាប់អាចបាត់នូវការចងចាំ
បើកត់ចំណាំភ្លេចនៅចាំព្រោះកត់ត្រា។

*បើឃើញខុសភ្លាមកែភ្លាម
ទើបមានវិញ្ញាណចងចាំ។

*បើចង់ចេះមិនត្រូវខ្លាចខាត
បើចង់ឆ្លាតសង្វាតគិតគូរ។

*បើចង់ចំណេញត្រូវកុំប្រមាទ
ព្រោះខាតមកពីប្រមាទរឿយៗ។

*បើចង់ជួយគេត្រូវត្រៀមបៀមទុក្ខ
សម្រាប់ក្តីសុខដល់អ្នកត្រៀមភ័យ។

*បើចង់ដឹងត្រូវចូលឱ្យជិត
ទើបអាចស្គាល់ពិតពីតម្លៃ។

*បើចង់លើកស្ទួយដល់សិទ្ធិកុមារ
មិនមែនផ្តាច់ការឱ្យក្មេងធ្វើឡើយ។

*បើចង់អប់រំកែប្រែមារយាទអ្នកដទៃ
ប្រព្រឹត្តប្រពៃមារយាទថ្លៃខ្ជនឯងជាមុន។

*បើចង់ឲ្យកិច្ចការរីកដុះដាលធំ
គួរខិតខំផ្តុំបណ្តុះបណ្តាលពួជ។

*បើចរិតពាលគឺមិនងាយកែ
មារយាទអន់ដែរគ្រោះដល់សង្គម។

*បើចាស់គំនិតនៅក្នុងមារយាទ
កិច្ចការផ្សេងទៀតក៏នៅខ្ចីដែរ។

*បើចាប់ផ្តើមចេះបានចំណេះកើន
ទើបជួយចម្រើនដល់ជាតិសង្គម។

*បើចំណូលតិចជាងចំណាយ
នាំភ័យអន្តរាយក្នុងជីវិត។

*បើចំណេះដឹងមានតែគ្មានឆន្ទៈ
ពុំអាចជឿជាក់ពីភាពជោគជ័យ។

*បើចំណេះតិចមានគំនិតថ្មី
ជាភាពវាងវៃនៃការដឹកនាំ។

*បើចេះតាមគេថាតែមិនដឹង
ចេះរបៀបហ្នឹងចេះមិនប្រាកដ។

*បើចេះតែជឿមិនដែលគិត
គឺជាគំនិតគ្មានកំណើត។

*បើចេះថាត្រូវធ្វើឲ្យច្រើន
ទើបអាចបង្កើនការចូលរួម។

*បើចេះធ្វើល្ងង់បានកើនចំណេះ
បើល្ងង់ធ្វើចេះដូចប្រឆេះគ្មានភ្លើង។

*បើចេះពិតមិនងងឹតទេផ្លូវ
តែចេះព្រៅៗអាចទៅវិនាស។

*បើចេះលកលៃចាយសំចៃ
គឺជាបច្ច័យថ្ងៃជ័យជោគ។

*បើជាគ្រូរអ៊ូពីលំបាក
នាំឲ្យប្រាសចាកពីនាមអ្នកធ្ងន់។

*បើជាបណ្ឌិតមានតែឈ្មោះ
អាចនាំនូវគ្រោះដល់សង្គម។

*បើជាមនុស្ស
ត្រូវតែរស់ព្រោះគុណធម៌។

*បើជាមន្ត្រីគប្បីបម្រើរាស្ត្រ
គួរកុំឲ្យរាស្ត្រកញ្ជះមន្ត្រី។

*បើជាមន្ត្រីគប្បីបម្រើរាស្ត្រ
គួរកុំឲ្យរាស្ត្រវិនាសព្រោះមន្ត្រី។

*បើជួបបញ្ហាត្រូវព្យាយាមដោះ
កុំមិនធ្វើសោះនាំឲ្យក្រំក្រៀម។

*បើជួយកុំនឹកដល់ពីតាមទារ
នោះហើយទើបជាជំនួយសប្បុរស។

*បើជំនាន់ចាស់គិតថាចេះគ្រប់គ្រាន់
នាំឲ្យជំនាន់ថ្មីជួបភ័យវិបត្តិ។

*បើឈឺត្រូវចេះថែថ្នូនចំណី
បើបុលខ្ចីសម្តីឲ្យពីរោះ។

*បើដាក់ចុះនូវចិត្តមានះ
គឺពិតជាឈ្នះលើខ្លួនឯង។

*បើដឹងខ្លួនក្រក្រវើនចំណាយ
ហាំហួនតែកាយសប្បាយតោកយ៉ាក។

*បើដឹងខុសចេះកែឲ្យត្រូវ
ទើបបានជាផ្លូវសុខនិរន្តរ៍។

*បើដឹងខុសព្យាយាមកែត្រូវបាន
ជាពូជសន្តានមានដោយកម្រ។

*បើដឹងខ្លួនល្ងង់គង់អាចចេះ
នូវចំណេះចេះមិនគ្រប់គ្រាន់។

*បើដឹងថាខ្លួនធ្វើអ្វីខុស
ឆាប់កែកំហុសទើបមិនសោកា។

*បើដឹងល្ងង់ខំប្រឹងចង់ចេះ
គង់មានតម្រិះចេះប្រាកដ។

*បើដឹងថាល្ងង់ប្រឹងរៀនឲ្យចេះ
ទើបកើតចំណេះកើនជាប្រចាំ។

*បើជួយទិញរបស់ដែលកុមារលក់
ដូចជួយពង្វក់ឲ្យកុមារឈប់រៀន។

*បើតាំងខ្លួនចេះ
ប្រាកដជាចេះចំណេះមិនគ្រាន់។

*បើត្រឹមគិតទុកតែមិនបានធ្វើ
គិតឥតអំពើស្មើបរាជ័យ។

*បើត្រឹមដឹងប៉ុន្តែមិនយល់
គឺជាឫសគល់ចិត្តមានះ។

*បើត្រឹមតែចេះមិនស្មើបានដឹង
នៅពេលយល់ដឹងទើបចេះប្រាកដ។

*បើត្រឹមតែដឹងប៉ុន្តែមិនយល់
គឺជាឫសគល់នៃចិត្តមានះ។

*បើត្រៀមធ្វើត្រូវតែត្រៀមខុស
ចាំរងប្រទូស្តពាក្យឥស្សា។

*បើថ្ងៃក្តៅអាចរកម្លប់ជ្រក
ចិត្តស្មោគគ្រោកជ្រកអាចម៍ជន្លេន។

*បើថ្នាក់លើចាំតែប្រទូស្ត
ថ្នាក់ក្រោមរងគ្រោះជាប្រចាំ។

*បើទម្លាប់ធ្វើតាមត្រាប់គ្មានគំនិតមិនប្រពៃ
គប្បីលកលៃកែច្នៃតាមស្ថានការណ៍ទើបប្រសើរ។

*បើទស្សនកិច្ចគួរបានគំនិតជួយខ្ចែរ
កុំទស្សនកិច្ចដែរបែបទេសចរណ៍កម្សាន្ត។

*បើទស្សនកិច្ចសិក្សាកើតបានចំណេះ
មានឆន្ទៈចេះប្រើជាប្រយោជន៍ទើបអស្ចារ្យ។

*បើទាស់ចិត្តអ្នកខុសមិនត្រូវចិត្តអ្នកត្រូវ
ទើបបានជាផ្លូវកណ្តាលនៃអ្នកដឹកនាំ។

*បើទិញទំនិញដែលកុមារលក់
ដូចជួយពង្រក់ឱ្យគេឈប់រៀន។

*បើទុកចោលសំរាមខុសរបៀប
ដូចផ្ញើមារយាទជាមួយសំរាម។

*បើទូន្មានបំណងចង់ឱ្យគេល្អ
ដូចយកដុំថ្មដាក់លើទ្រូងឯង។

*បើធ្វើការយកបេះដូងប្តូរយកត្រីមប្រាក់
ប្រៀបដូចជាងឆ្លាក់ចម្លាក់ដោយគ្មានវិញ្ញាណ។

*បើធ្វើកិច្ចការគ្មានមារយាទ
កុំសង្ឃឹមញាតិមិត្តចូលរួម។

*បើធ្វើចេះបានត្រឹមគេស្អប់
បើធ្វើឡប់ៗគេថាល្ងង់។

*បើធ្វើតាមត្រាប់មិនស្ទាត់ចាប់
ធ្វើតាមទម្លាប់មិនប្រសើរ។

*បើធ្វើតាមបង្គាប់គ្មាននិស្ស័យ
កំពុងប្រល័យគំនិតឲ្យល្ងង់។

*បើធ្វើតាមត្រឹមត្រាប់អាចអប្បបញ្ញា
បើប្រើប្រាជ្ញាកោសិការចម្រើន។

*បើធ្វើតាមទម្លាប់អាចងាប់ដល់មនសិការ
ធ្វើតាមធម្មតាកុំសង្ឃឹមថាមានការប្រែប្រួល។

*បើធ្វើត្រឹមតែតាមទម្លាប់
គឺអាចងាប់ដល់មនសិការ។

*បើធ្វើបុណ្យកិបកេងបច្ច័យ
ព្រោះគ្មាននិស្ស័យជាមនុស្ស។

*បើធ្វើល្អគប្បីកុំសម្តែង
ត្រូវប្រយ័ត្នក្រែងអាក្រក់ជាធ្នាក់។

*បើធ្វើអាក្រក់កុំសងត
ព្យាយាមធ្វើល្អមិនបង្កភ័យ។

*បើធ្វើអ្វីមានសតិក្រើនរំឭក
កិច្ចការសន្ធឹកតែងតែជោគជ័យ។

*បើធ្វើអ្វីដែលមិនបានយល់
ជាឫសគល់នៃក្តីវិនាស។

*បើបង្រៀនគ្រាន់តែជាការសម្តែង
លទ្ធផលជាក់ស្តែងមិនមានអ្វីប្រាកដ។

*បើបង្រៀនចេះត្រឹមអាចារ្យតែថេះ
អាចសង្គមនេះនាំគ្នាចេះត្រឹមថា។

*បើបណ្ឌិតពិត
តែងមានគំនិតជួយជាតិសង្គម។

*បើបណ្ឌិតមានគំនិតពាល
ពិតជាមិនងាយកែតម្រង់។

*បើបានថ្កើងកុំដំឡើងឫកហួស
ក្រែងលោបាត់យសព្រោះបង់មារយាទ។

*បើបានមានកុំអាលទាន់ភ្លេចក្រ
មារយាទមិនល្អអាចក្រតាមទាន់។

*បើបានមានគប្បីកុំបំភ្លេចក្រ
ស្គាល់បញ្ហាក្រទើបបន្តមានបាន។

*បើប្អូសគ្រាន់តែឲ្យចាស់វស្សា
មិនបានសិក្សាសាសនាថមថយ។

*បើប្អូសចាស់តែវស្សា
មិនបានសិក្សានាំឲ្យសាសនាមានឥទ្ធិពលថយ ។

*បើបោះបង់ការព្យាយាម
អាចនឹងគ្មានអនាគត។

*បើប្រមូលកម្លាំងខាងក្នុងបានខ្លាំង
ទើបមានកម្លាំងខាងក្រៅជួយគាំទ្រ។

*បើធឹកសុរាស្មមកុំបើកបរ
នាំគ្រោះបន្តដល់អ្នកមិនដឹង។

*បើផ្តាស់ប្តូរទម្លាប់ចាស់មិនល្អអត់បាន
មិនអាចថ្កើងថ្កានដល់អនាគតគ្រប់វ័យ។

*បើពិតជាចិត្តសប្បុរស
គ្មានបំណងសោះឲ្យគេតបស្នង។

*បើពិភពលោកគ្មានកុមារ
ជាស្បែអន្ធការនៃមនុស្សចាស់។

*បើពឹងគេជួយបានតែម្តងម្យាម
បើខ្លួនព្យាយាមជួយទើបខ្លាំងពិត។

*បើព្យាយាមយល់
ស្រាវជ្រាវដល់គល់ទើបអាចដឹងបាន។

*បើមន្ត្រីកាងពីក្រោយខ្នងឈ្លួញ
កំពុងតែជួញបាត់បង់យសស័ក្តិ។

*បើមានកំហុសចេះកែ
ទើបបានប្រែកែចរិត។

*បើមានការងាររស់ជួយជាតិញាតិសន្តាន
ទើបរស់ថ្កើងថ្កានបានដោយមិនអសោចកេរ្តិ៍។

* បើមានកុំភ្លេចគ្រាកម្សត់ក្រ
ទើបអាចបន្តមានជានិរន្តរ៍។

*បើមានកំហុសមិនទទួលខុស
ប្រៀបដូចចន្ទះឆេះគ្មានឈើកៀស។

*បើមានក្តីអាណិតអាសូរ
ទើបភាពថ្លៃថ្នូរដល់មង្គល។

*បើមានគំនិតតែគ្មានកំណើត
មិនកកើតបានជាទ្រព្យធន។

*បើមានគំនិតធ្វើមិនមើលកាល
គឺអាចបណ្តាលឲ្យបរាជ័យ។

*បើមានគំនិតហ៊ានចាប់ផ្តើម
គឺបានជាដើមទុនជោគជ័យ។

*បើមានចំណេះចេះចែករំលែក
គឺបានជាផ្នែកធនធានអប់រំ។

*បើមានចំណេះតែគ្មានឱកាស
ពិបាកពេកណាស់សម្រាប់ជោគជ័យ។

*បើមានចំណេះមិនផ្គាស់ប្តូរទម្លាប់
គឺជំពាក់ជាប់ដល់តម្លៃសិក្សា។

*បើមានឆន្ទៈធ្វើនៅស្មាក់ស្មើរ
គ្មានគំនិតរើគឺបរាជ័យ។

*បើមានឆន្ទៈនៅស្មើរស្មាក់
មិនអាចពំនាក់ខ្លួនឯងបាន។

*បើមានឆន្ទៈហ៊ានជំនះធ្វើ
គឺជាទង្វើសម្រាប់ធ្វើធ្នាក់។

*បើមានជំនាញនិយាយតែមិនពូកែធ្វើ
មិនល្អដូចទងធ្វើតែមិនប្រសប់និយាយ។

*បើមានជំនាញស្មាត់
ត្រូវប្រយ័ត្នឲ្យរឹតតែទ្វេ។

*បើមានទ្រព្យពិតជាសំណាង
ប៉ុន្តែកុំអាងអាចបាត់បង់យស។

*បើមានបុណ្យសក្តិមុខមាត់កិត្តិយស
កុំវាយឫកខ្ពស់ឲ្យញាតិអស់និស្ស័យ។

*បើមានមុខការធ្វើកុំចោលម្យៀត
កើរ្តីឈ្មោះមារយាទញាតិមើលសាច់ការ។

*បើមានមោទនភាពជ្រុល
នាំឲ្យងប់ងុលបាត់តម្លៃ។

*បើមានវិជ្ជាជីវៈនិងវិជ្ជាជីវិត
អាចជួយលើកស្ទួយពិតជីវិតនៃភាពអស្ចារ្យ។

*បើមានសតិចេះសង្កេតឥរិយាបថ
ជាអ្នកមានផ្នត់ចរិតមារយាទថ្លៃ។

*បើមានសតិសង្កេតពិចារណា
ទើបបានផ្លែផ្កាដល់ការអនុវត្ត។

*បើមានហេតុផលអាចផ្តល់ប្រយោជន៍
បើកេរ្តិ៍អសោចផ្តល់ភាពអាម៉ាស់។

*បើមានអាជីពជាគ្រូបង្រៀន
គប្បីត្រូវរៀនអស់មួយជីវិត។

*បើមានអាជីពជាគ្រូបង្រៀនបម្រើសង្គម
គប្បីអប់រំជាគំរូដល់ជនជំនាន់ក្រោយ។

*បើមានឱកាសតែខ្វះមារយាទ
មិនកែជីវភាពប្រែឲ្យប្រសើរ។

*បើមានអំណាចត្រូវជួយសង្គមឲ្យបានច្រើន
ទើបអាចពួនកើនន្លូវតម្លៃមុនអស់វេលា។

*បើមានអ្វីត្រូវចេះប្រើប្រាស់រក្សាថែ
កុំបានខាងតែឲ្យកែសុំប្រើខ្ជះខ្ជាយ។

*បើមារយាទខ្ជិលមានអាជីពជាគ្រូ
សាបព្រួសគំរូអាក្រក់ដល់សង្គម។

*បើមិនចង់ឲ្យគេមើលងាយ
កុំធ្វើខ្ជះខ្ជាយឲ្យគេមើល។

*បើមិនចង់ឲ្យគេមើលងាយ
កុំធ្វើអ្វីងាយឲ្យគេមើល។

*បើមិនចេះគួរចាប់ផ្តើមចេះ
ទើបមានចំណេះចេះប្រាកដ។

*បើមិនដឹងថាខ្លួនឯងល្ងង់
គង់តែនៅល្ងង់មួយជីវិត។

*បើមិនទាន់ចេះនៅភ្លឺកៗ
បើរំលឹកយូរៗគង់ភ្លឺ។

*បើមិនធ្វើចង់ឲ្យគេសរសើរ
គឺអាចទុកស្មើនឹងដុំលាមក។

*បើមិនផ្លាស់ប្តូរកែចរិតមារយាទ
ទោះបីរាប់ជាតិនៅតែគ្មានកំណើត។

*បើមិនហ៊ានខុសមិនអាចរកត្រូវ
ដែលបានជាផ្លូវពីសោធន៍ជីវិត។

*បើមិនហ៊ានមើលនិងចង់ស្តាប់
ព្រោះខ្លាចអប្បនាំឲ្យខូចអន់។

*បើយកលុយរាស្ត្រទាក់លុយរដ្ឋ
ទើបរួមអភិវឌ្ឍន៍ជួយសង្គម។

*បើរពួកដឹងសុខអ្នកផ្សេងជាសុខខ្លួនឯង
រមែងកោតក្រែងមិនបំពានសុខអ្នកដទៃ។

*បើរស់ក្នុងសង្គមពួកក្រុមញាតិ
កុំមានមារយាទអាត្មានិយម។

*បើរស់គេរាប់បើងាប់គេសួរ
ទើបបានសមគួរមនុស្សថ្លាថ្លៃ។

*បើរស់មិនបង្កការរំខាន
គឺជាសន្តានៃមនុស្សល្អ។

*បើរស់ដោយការរមឹលគុណ
គឺរស់គ្មានទុនជាកំណើត។

*បើរស់ឲ្យគួរបើងាប់ឲ្យគាប់
គឺបានជាទ្រព្យរាប់ដ៏ប្រពៃ។

*បើរៀនកុំបានត្រឹមតែចេះសូធ្យ
ត្រូវរៀនរហូតដល់ទៅចេះធ្វើ។

*បើរៀនចេះចាំតែមិនធ្វើ
រៀនអត់អំពើគ្មានតម្លៃ។

*បើរៀនត្រូវព្យាយាមឲ្យចេះ
ទើបជាប្រឆេះបំភ្លឺជីវិត។

*បើរៀនបើកចិត្តឲ្យបានទូលាយ
ប្រាកដជាងាយមានគំនិតថ្មី។

*បើរៀនពីអ្នកមិនចេះ
គឺមានចំណេះអាចដឹង។

*បើល្ងង់ត្រូវខំព្យាយាមរៀន
ទើបក្លាយជាស្ពានៃជីវិត។

*បើល្ងង់ព្យាយាមគង់ចេះ
ខ្ជិលធ្វេសប្រហែសនាំខ្លៅ។

*បើសតិធ្វើព្រោះលុយជានុយទាញទាក់
មិនស្មើឆន្ទៈធ្វើអន្ទាក់ទាក់បេះដូង។

*បើសិក្សាចេះទ្រឹស្តីនៅវត្តឬសាលា
គប្បីប្រើការប្រតិបត្តិធ្វើជាគំរូ។

*បើសិក្សាបានកើតជាប្រយោជន៍
ទើបមិនអសោចខូចយសទ្រព្យធន។

*បើស្ងប់ស្ងាត់គួរកុំនៅស្ងៀម
គប្បីគិតត្រៀមបំរុងការណ៍។

*បើស្ងួនចិត្តត្រូវប្រយ័ត្នអារម្មណ៍
កុំបង្ខំចិត្តនាំវិបត្តិក្រោយ។

*បើស្រង់កម្ទេចគំនិតជាធាតុចូល
គឺអាចប្រមូលទស្សនវិស័យ។

*បើស្រឡាញ់ជីវិតរបស់លោកអ្នក
ត្រូវតែជឿជាក់លើសុខាភិបាល។

*បើស្រឡាញ់សុខភាព
ត្រូវខ្ជីឃ្មាតឆ្លៀតហាត់ប្រាណ។

*បើស្អប់ត្រូវនឹកដល់គ្រាស្រឡាញ់
ទើបអាចផ្ចាលផ្ចាញ់នូវចិត្តដែលស្អប់។

*បើស្អប់ត្រូវរៀនល្បិចពីសត្រូវ
ទើបបានជាផ្ចូវឈ្នះសត្រូវពិត។

*បើស្អាតនឹងមុខក្រោយកណ្តាលវាល
ពិតជាមិនងាយកែន្ធវសន្តាន។

*បើស្អាតព្រោះតែងកាយមិនបានស្អាតចិត្ត
ប្រៀបដូចជីវិតរស់ក្នុងធុងសំរាម។

*បើហ៊ានត្រូវមានហេតុ
កុំប្រមាទទើបមិនសោកា។

*បើហ៊ានថាត្រូវត្រៀមធ្វើឲ្យកើត
ទើបជាកំណើតនៃអ្នកដឹកនាំ។

*បើហ៊ានថាហើយហ៊ានធ្វើ
ទើបអំពើមិនចោលម្សៀត។

*បើហ៊ានបរាជ័យ
គឺជោគជ័យប្រាកដ។

*បើអធ្យាស្រ័យបានឆាប់ធ្វើទៅ
ព្រោះជីវិតនៅរស់មិនទៀងឡើយ។

*បើអប់រំគេកុំភ្លេចខ្លួនឯង
ប្រយ័ត្នលោក្រែងមិនដល់គោលដៅ។

*បើអប់រំឲ្យជឿពីហេតុផលមិនងាយ
បើជឿគ្រូទាយអាចតដល់ញាតិសន្តាន។

*បើអាចារ្យតែចេះគ្មានអាចារ្យធ្វើ
មិនមានអំពើដល់ការអភិវឌ្ឍ។

*បើអាណិតកុមារកុំជួយទិញ
រកវិធីវិញជួយគេបែបណា។

*បើអ្នកចង់ចេះចង់ដឹង
ត្រូវខំប្រឹងអានសៀវភៅ។

*បើអ្នកចង់ធ្វើឲ្យជីវិតកាន់តែមានន័យ
គួរតែលះកលែស្គាល់អ្នកដទៃឲ្យបានច្រើន។

*បើអ្នកធ្លាប់ជួបនូវគ្រោះបញ្ហា
ទើបដឹងថាការទូន្មានត្រឹមត្រូវ។

*បើអ្នកសន្សំចិត្តចេះរក្សា
ទើបក្តីប្រាថ្នាអ្នកបានសម្រេច។

*បំណងដែលមានមហិច្ឆតា
អាចនាំប្រាថ្នាសម្រេចជោគជ័យ។

*បំណងល្អប្រៀបដូចជាក្បូន
សម្រាប់ជួយជូនរកត្រើយវាសនា។

*បំណងល្អមិនងាយពន្យល់
បំណងពិសពុលយល់ត្រេកអរ។

*បំណុលជាឫសគល់នៃភាពក្រីក្រ
បើមារយាទល្អគង់ក្លាយជាអ្នកមាន។

*ប្តីប្រពន្ធកុំទាស់ចាប់កំហុស
គួរគិតកាលណោះស្នេហាក្មេងខ្ចី។

*ប្រតិបត្តិបុណ្យដោយបញ្ញា
ផលដល់អាត្មាផៅសន្តាន។

*ប្រយ័ត្ន! ពាលលួចទៅពឹងព្រះ
យកស្បង់ពាក់សំពះញ៉ែរដែ។

*ប្រយ័ត្ន! សំបកជាបណ្ឌិត
ឯចិត្តគំនិតជាជនពាល។

*ប្រវត្តិនៃមន្ត្រីពឹងលើអំពើ
ល្អអាក្រក់ធ្វើមកលើរាស្ត្រប្រជា។

*ប្រសិទ្ធភាពការងារសំខាន់លើអ្នកធ្វើ
មិនចំណុះលើអ្នកចាំមើលបានត្រឹមថា។

*ប្រឡាយទឹកប្រៀបជាសរសៃឈាម
ដែលធ្វើឲ្យមានមនុស្សរុក្ខជាតិសត្វ។

*ប្រាក់តិចកុំបិចចាយច្រើន
ចម្រើនខ្វល់ដល់អាត្មា។

*ប្រាជ្ញគ្មានចំណេះ
ដូចថ្ងៃរះគ្មានរស្មី។

*ប្រាជ្ញពុំស្មើលុតក្រាបអែបអប
ប្រាជ្ញខ្លាចខ្លបចរិតឡេមឡឺម។

*ប្រាជ្ញមិនស្មើអំណាចអែបអប
ស្លឹកត្រចៀកខ្លបខ្លាចឡេមឡឺម។

*ប្រាជ្ញាជាអាវុធមុតថ្លា
ខ្ជិលនាំបញ្ហាឲ្យអន់ថយ។

*ប្រើពេលវេលាខ្លីមានន័យច្រើន
បានជួយបង្កើនកិច្ចការឲ្យថ្លៃ។

*ប្រើមនុស្សគួរឲ្យចេះមើលកាល
ទើបមិនបណ្តាលដល់ការប្រទូស្ត។

*ប្រើលុយរដ្ឋទាក់ទាញលុយរាស្ត្រ
ទើបមានតេជៈឈ្នះដល់សង្គម។

*ប្រើស៊ីប្តេអ្នកចរខាងមុខមិនខុស
ជាកំហុសអ្នកបើកបរខាងក្រោយ។

៥ ~ ៦

*-ផែនដីមិនអាចឲ្យរាបស្មើបាន

ចិត្តសត្វគ្រប់ប្រាណមិនស្មើគ្នាដែរ។

*ផ្តើមពីនិស្ស័យនិងការព្យាយាម

ទើបអាចកើតមានមេរៀនជីវិត។

*ផ្តើមពីមិនចេះទើបអាចធ្វើឲ្យចេះ

ដូច្នេះចំណេះចេះពីមិនទាន់ចេះ។

៣ ~ ៧

*ពាក្យជូនពរគ្រាន់តែការផ្តល់កម្លាំងចិត្ត
ភាពជោគជ័យពិតគឺចិត្តអំណត់ព្យាយាម។

*ពាក្យដែលមិនពិតប្រតិដ្ឋនិយាយ
ជាទោសមួយងាយផ្តល់ឲ្យអន្តរាយ។

*ពាក្យដោះសារ
ជាគំនរបញ្ហានៃការដោះស្រាយ។

*ពាក្យទូន្មានក្រើនរំឭកអាត្មា
ចិត្តពាលមោហាមិនងាយប្រតិបត្តិ។

*ពាក្យទូន្មានប្រៀបដូចការប្រាប់ផ្លូវ
គួរជនទូទៅចេះទទួលយក។

*ពាក្យទូន្មានប្រៀបដូចគ្រាប់ពេជ្រ
មានអ្នកភាគតិចគិតជាប្រយោជន៍។

*ពាក្យទូន្មានប្រៀបដូចគ្រាប់ស្លែង
បញ្ហោរវិញតែងផ្អែមដូចទឹកឃ្មុំ។

*ពាក្យទូន្មានរមែងដូចគ្រាប់ស្លែង
បញ្ហោររមែងដូចសែងទៅដុត។

*ពាក្យបង្អាប់ប្រៀបដូចគ្រាប់ស្លែង
គប្បីចាស់ក្មេងកុំនាំបង្អាប់។

*ពាក្យប្រៀនប្រដៅប្រៀបដូចគ្រាប់ព្រួញ
ដែលក្រុមពាលរួញមិនងាយត្រងគ្រាប់។

*ពាក្យប្រៀនហៅប្រាប់ថា
ជាបន្ទានៃពាលស្តាប់។

*ពាក្យពិតតែងតែផ្ចាញ់ពាល
ពាក្យរោយរាយផ្ចាញ់អាត្មា។

*ពាក្យពិតពិចារណាយូរបានយល់
ស្តាប់មិនដល់គល់ចាំតែប្រទេច។

*ពាក្យអប់រំប្រៀបដូចជាបន្លា
ពាក្យគ្មានបានការប្រៀបដូចទឹកឃ្មុំ។

*ពាលចេញតាមសម្តីឥរិយាបថ
ដែលបានកំណត់ទៅតាមបុគ្គល។

*ពាលឬបណ្ឌិតស្តាប់តាមវាចា
មើលពីឥរិយាទើបកំណត់ត្រូវ។

*ពិធីបុណ្យចូលឆ្នាំមានច្រើនដង
ស្តាប់មានតែម្តងចូរញាតិចងចាំ។

*ពិធីបុណ្យមានច្រើនអនេក
ប៉ុន្តែចម្លែកមិនសម្បូរមនុស្សល្អ។

*ពិភពលោកជាទ្រុងនៃមនុស្ស
គួរជនស្រីប្រុសសង្វេគអាត្មា។

*ពឹងតែគេជួយ
ខ្លួនមិនដែលព្រួយក្តីវិនាស។

*ពួជពង្សថ្លៃថ្នូរ
តែងតែគាំទ្រដល់ការអប់រំ។

*ពួកក្មេងៗចូលចិត្តភ្លើង. ទឹក. ឈើ. ដី
ចូរជនប្រុសស្រីមានស្មារតីប្រយ័ត្ន។

*ពេលចេះត្រូវគិតពីភាពល្ងង់
ទើបមិនបាត់បង់នៃភាពចេះ។

*ពេលជួបគ្នាចេះតែធុញទាស់
ពេលឃ្លាតឆ្ងាយអស់ចិត្តនឹកអាល័យ។

*ពេលជួបត្រូវនឹកដល់ព្រាត់
ព្រោះវាជាវដ្តនៃសត្វលោក។

*ពេលដែលខឹងប្រាកដជាខុស
ពេលស្គាល់កំហុសពិតជាត្រូវ។

*ពេលដែលចេះទើបដឹងថាល្ងង់
ក្រោយពីខឹងទើបដឹងថាខុស។

*ពេលធ្វើទើបឃើញពិត
មានគំនិតបានប្រសើរ។

*ពេលធ្វើបុណ្យទម្លាប់ផឹកស្រា
បានបុណ្យពីណាមានតែបាប។

*ពេលមានគប្បីគិតដល់ក្រ
ទើបមិនបង្កឲ្យក្រតាមទាន់។

*ពេលមានភ្លេចក្រ
ជាគ្រោះបន្តដល់ពូជផៅ។

*ពេលវេលាគឺជាច្បាប់
បើគោរពច្បាប់ត្រូវទៀងពេល។

*ពេលវេលាចេះតែរំកិលទៅមុខ
គប្បីកុំទុកកិច្ចការត្រូវធ្វើកន្លង។

*ពេលវេលាទៀងទាត់ក៏នៅមិនទៀងទាត់
ការអនុវត្តនៅមានភាពប្រែប្រួល។

*ពេលវេលាមានតម្លៃ
អាស្រ័យអ្នកប្រតិបត្តិ។

*ពេលវេលាមានឬគ្មានតម្លៃ
គឺពឹងអាស្រ័យនៅលើមនុស្ស។

*ពេលវេលាឱកាសសម្រាប់មនុស្សខ្លី
មនុស្សមានន័យថ្នែវេលាជាប្រយោជន៍។

*ពោលពាក្យខ្លីតែមានន័យគ្រប់គ្រាន់
ជាងពាក្យរាប់ពាន់គ្មានន័យអ្វីសោះ។

*ពោលពាក្យដែលជាវិធីដោះសារ
គឺជាបន្ថានៃអ្នកចាំស្តាប់។

*ពោលពាក្យបាបចិត្តមិនបានសុខពិត
ព្រោះជាបាបមិត្តដល់អ្នកដទៃ។

*ពោលពាក្យល្អប្រសើរណាស់
បើធ្វើបានច្បាស់ប្រសើរក្រៃ។

*ពោលពាក្យល្អប្រសើរពិត
តែធ្វើកើតពិតប្រសើរថ្លៃ។

*ពោលពាក្យល្អពិបាករើសមកថ្លែង
រោយរាយរមែងងាយថ្លែងកន្លង។

*ព្យាយាមកើតពីមានឆន្ទៈ
សម្បជញ្ញៈទាក់ប្រយោជន៍។

*ព្យាយាមកែទម្លាប់មិនត្រឹមត្រូវ
ទើបជាផ្លូវនៃការអភិវឌ្ឍ។

*ព្យាយាមជំនះនូវកិលេសខ្ជិលបាន
ទើបជាសន្តានតម្លៃនៃមនុស្សពិត។

*ព្យាយាមពឹងអំណត់
ភាពក្រខ្សត់ពឹងខំរក។

*ព្យាយាមសិក្សា
បានផលផ្លែផ្កាមកអាត្មាវិញ។

*ព្រួយបារម្ភពីសុខទុក្ខកូនគេ
រងពាក្យស្តីជេរព្រោះគេមិនយល់។

ត ~ ភ

*ភាពកតញ្ញូជាពួជគំរូគ្រប់ជំនាន់
គប្បីរួសរាន់ផ្តើមសាងល្អទើបប្រពៃ។

*ភាពខុសត្រូវមិននៅត្រឹមតែថា
គួរគិតសិនណាទើបថាបានត្រូវ។

*ភាពខុសឬត្រូវទុកជាគ្រូ
ដែលជាគំរូមេរៀនជីវិត។

*ភាពជាអ្នកជោគជ័យ
គឺរៀនហ៊ានចាប់ផ្តើម។

*ភាពជោគជ័យ
មិនពឹងអាស្រ័យចាំតែគេជួយ។

*ភាពជោគជាំដោយការស្រវឹង
គឺបាត់ពំនឹងក្នុងជីវិត។

*ភាពទៀងទាត់គឺជាតម្លៃ
ដែលវិនិច្ឆ័យដល់បុគ្គល។

*ភាពនៃក្តីស្រមៃ
ជានិស្ស័យអភិវឌ្ឍន៍។

*ភាពល្ងង់មកពីមិនចេះ
ទើបគ្មានចំណេះសម្រាប់ខ្លួនពីង។

*ភាពល្បីល្បាញគ្រាន់តែនៅក្រៅខ្លួន
អ្វីដែលសមស្នួនចិត្តស្ងប់មេត្តា។

*ភាពល្បីល្បាញរបស់អ្នកចេះធ្វើ
មកពីអ្នកមើលចេះវាយតម្លៃ។

*ភាពស្កប់ស្កល់
អាចជាផលបរាជ័យ។

*ភាពស្មោះត្រង់មិនឱ្យបាត់បង់យស
ក្រអូបសាយឈ្មោះកេរ្តិ៍វង្សត្រកូល។

*ភាពហ្មត់ចត់
ប្រាកដជាជោគជ័យ។

*ភាពអាត្មានិយម
កិច្ចការធំៗមិនអាចដឹកនាំជោគជ័យទេ។

*ភាពអៀនប្រៀន
តែងមិនមានសិរីដល់អាត្មា។

*ភ្លើងកំពុងឆេះកុំផ្លុំផេះថែម
នាំតែហុយផ្សែងក្តៅប្រលាក់មុខ។

ᨿ ~ ᩁ

*មនុស្សកំណាញ់ការសរសើរ
ព្រោះខ្លាចគេគ្រាន់បើជាងខ្លួន។

*មនុស្សក្អែងទំនើង
មកពីចាស់ធ្វើទ្រើងឲ្យវារឡើង។

*មនុស្សខ្ជិចឈ្មោះ
ព្រោះយករបស់ដែលគេមិនបានឲ្យ។

*មនុស្សគ្រប់រូបជួបទុក្ខធម្មតា
គួរកុំសោកានាំខ្វល់ខ្វាយចិត្ត។

*មនុស្សគ្រប់រូបទៀងតែមិនទៀង
ត្រង់កាយវិញ្ញាណរលត់ពេលណា។

*មនុស្សគ្រប់រូបធ្វើចិត្តដូចសំឡេងតន្ត្រីបាន
នាំសង្គមឲ្យថ្កើងថ្កានក្នុងពិភពលោក។

*មនុស្សចរិតក្រពើ
ភ្លើចមើលខ្លួនជាជីងចក់។

*មនុស្សចរិតអន់
កុំគិតថាគ្រាន់ជាងអ្នកដទៃ។

*មនុស្សចរិតអន់
មិនដែលចេះគន់មារយាទអាក្រក់។

*មនុស្សចរិតអួតអាង
បានត្រឹមសាងទុក្ខវេទនា។

*មនុស្សចាត់ទុកថាមានអំនួត
ធ្វើអ្វីដូចឆ្កួតបានត្រឹមតែថា។

*មនុស្សចាស់ជាអ្នកបង្រៀនន្ទូវកំហុស
ឬភាពត្រឹមត្រូវទាំងអស់ដល់មនុស្សក្មេង។

*មនុស្សចាស់បានផ្តល់កំណើតចំណេះដល់ក្មេង
ចំណែកក្មេងៗរមែងក្លាយចាស់តជំនាន់។

*មនុស្សចោលសំរាមពាសវាលពាសកាល
បណ្តាលអន្តរាយកិត្តិយសសង្គម។

*មនុស្សចេះពិត
តែងមានគំនិតមើលធ្វើគិតពីអ្នកដទៃ។

*មនុស្សចេះរៀបចំខ្លួនស្អាតសាមញ្ញ
កិត្តិយសមូលវិញដោយបញ្ញាខ្ពស់។

*មនុស្សដែលគ្មានវិចារណញ្ញាណ
ធ្វើហើយមិនហ៊ានទទួលខុសត្រូវ។

*មនុស្សដែលឆាប់ប្រែធាតុ
មានមារយាទមិនប្រពៃ។

*មនុស្សដែលឆ្លាតវៃតែងតែស្វែងរកគំនិតថ្មីៗ
ដូចផ្កាឈូកវត្តរីកឃ្មាតខ្ទីរកពន្លឺព្រះអាទិត្យ។

*មនុស្សដែលជាមង្គលតែងមានធាតុបី
ធ្វើ, គិត, ស្តាប់, ន័យអ្នកដទៃជាប្រចាំ។

*មនុស្សដែលជាអាត្មានិយម
មិនជួយសង្គមរស់ស្រួលតែឯង។

*មនុស្សដែលពិបាកអប់រំបំផុត
ត្រង់មានគំនិតពីងព្រេងវាសនា។

*មនុស្សដែលមិនស្គាល់ការពិត
ធ្វើឲ្យជីវិតបរាជ័យ។

*មនុស្សដែលរស់នៅលើផែនដី
គ្រាន់តែអាស្រ័យបណ្តោះអាសន្ន។

*មនុស្សដែលសេពសុរាហើយបើកបរ
ក្លាយជាឃាតកតាមដងផ្លូវ។

*មនុស្សតែឈ្មោះ
ព្រោះតែរស់ដូចសត្វតិរច្ឆាន។

*មនុស្សទៀងស្លាប់តែមិនដឹងពេល
ប្រៀបដូចរង្វេលនៃវដ្តជីវិត។

*មនុស្សធមិពិតគឺគ្មានកម្រៃ
តែជាបុណ្យថ្លៃផ្តល់ដល់សង្គម។

*មនុស្សធ្វើអ្វីមិនចេះខ្ជាស់អៀន
ចរិតផ្តាស់ភ្លៀនហ៊ានបំពានច្បាប់។

*មនុស្សនិយាយកុហកអ្នកដទៃ
គឺមានន័យកំពុងកុហកខ្លួនឯង។

*មនុស្សបីក្រុមដែលជួយដល់កុមារ
គឺគ្រូអាចារ្យម៉ែឪនិងព្រះសង្ឃ។

*មនុស្សផ្តាប់ផ្តុនតែអ្នកក្រៅ
តែឆេវឆាវចំពោះអ្នកក្នុង។

*មនុស្សពាលងាយនឹងធ្វើអាក្រក់
រង់ចាំឆ្នក់ឆក់រកឱកាសធ្វើ។

*មនុស្សពាល
ងាយប្រព្រឹត្តអំពើអាក្រក់។

*មនុស្សពាលតែងប្រើសម្តីចោលម្សៀត
សម្តែងមារយាទសត្វធាតុប្រាប់ញាតិផៅ។

*មនុស្សពិតតែងស្រឡាញ់យស
មនុស្សតែឈ្មោះស្រឡាញ់ពាល។

*មនុស្សមានចរិតអភិវឌ្ឍ
មិនគិតមុខមាត់ឋានៈនាទី។

*មនុស្សមានពូជស្លាប់សុទ្ធតែទៀង
មិនដឹងកាយរាងរលត់ពេលណា។

*មនុស្សមិនគោរពពាក្យសម្តី
គឺបរាជ័យតម្លៃជីវិត។

*មនុស្សមិនស្គាល់ការពិត
គ្មានគំនិតអភិវឌ្ឍន៍។

*មនុស្សមិនស្គាល់គុណអន់ជាងសត្វ
ភ្លេចខ្លួនជាក្អាត់វាយឫកជាហ៊ឹង។

*មនុស្សរស់ក្នុងទ្រង់ពិភពលោក
គួរតែលៃលកចែកគ្នារួមរស់។

*មនុស្សរស់ដោយចេះចែករំលែក
ទើបបានជាផ្នែកជួយដល់សង្គម។

*មនុស្សលេងតែល្បែងស្រីស្រា
មានពាក្យពីណាប្រដៅប្រាប់។

*មនុស្សល្ងង់ធ្វើចេះ
ជាមនុស្សខ្លៅដំបៅដល់សង្គម។

*មនុស្សល្ងង់មិនដែលយកបទពិសោធន៍អ្នកដទៃ
មនុស្សឆ្លាតរៀកែច្នៃបទពិសោធន៍អ្នក
ដទៃឲ្យក្លាយជាប្រយោជន៍ខ្លួន។

*មនុស្សល្អគឺមានចិត្តល្អ
អ្នកដឹកនាំបវរប្រតិបត្តិត្រឹមត្រូវ។

*មនុស្សល្អដែលកម្ររកបាន
ធ្វើអ្វីគ្រប់យ៉ាងចង់ឲ្យគេសុខ។

*មនុស្សល្អតែងជួបឧបសគ្គ
ក្លាចចិត្តនៅស្ងៀគ្រខំប្រឹងសាងល្អ។

*មនុស្សល្អពិតជួយគ្រួសារជាតិ
មនុស្សចោលម្សៀតបំផ្លាញសង្គម។

*មនុស្សល្អពិត
មិនគេចបញ្ហា។

*មនុស្សល្អពិតរឹងមាំដូចថ្ម
គឺចិត្តកម្រងាយនឹងរលាយ។

*មនុស្សល្អមិនខ្វល់ពីការស្អប់
ព្រោះកប់កំណប់ល្អក្នុងសន្តាន។

*មនុស្សល្អមិនដែលគិតពីសំណង
រង់ចាំតបស្នងក្រោយជួយគេរួច។

*មនុស្សល្អមិនមែនអ្នកមិនខុសសោះ
អ្នកខុសចេះកែទើបជាមនុស្សល្អ។

*មនុស្សល្អស្គាល់គ្នា ចេះជួយដោះទុក្ខគ្រាលំបាក
ពិតជាពិបាករកជាង ចេះជួយគ្នាពេលសប្បាយ។

*មនុស្សវាយឫកជាអ្នកធំ
តាំងខ្លួនយ៉ាងហ៊ឹឲ្យគេកោត។

*មនុស្សវាយឫកជាអ្នកធំ
តែងពួនសម្ងំល្បិចចោលម្យៀត។

*មនុស្សវាយឫកជាអ្នកធំ
មិនដែលជំនុំនឹងអ្នកចេះ។

*មនុស្សវាយឫកជាអ្នកធំ
អែបអបយកបុណ្យមិនខ្ចាសញ្ជាតិ។

*មនុស្សស្លាប់រស់ព្រោះគំនិតសម្តី
មនុស្សឆ្លាតវៃចេះលៃប្រើបញ្ញា។

*មនុស្សស្លាប់រស់ព្រោះសម្តី
មន្ត្រីថ្កើងថ្កៃព្រោះមារយាទ។

*មនុស្សអាក្រក់ល្អកុំមើលសំបកក្រៅ
ពិនិត្យក្រយៅក្នុងទើបមិនផ្ទុងគំនិត។

*មនុស្សអាត្មានិយម
គឺធំដោយចិត្តឥស្សា។

*មន្ត្រីកាត់ក្តីដោយលម្អៀង
ចិត្តរស់តរៀងគ្មានក្តីសុខ។

*មន្ត្រីគ្រាប់ល្មៅនាំផ្លូវវិនាស
ដែលគ្មានតេជៈឱ្យរាស្ត្រសុខដុម។

*មន្ត្រីដែលក្បត់ឆន្ទៈរាស្ត្រ
តែងតែវិនាសទាំងគ្រួសារ។

*មន្ត្រីដែលក្បត់ឆន្ទៈរាស្ត្រ
វិនាសព្រោះរាស្ត្រក្តៅក្រហាយ។

*មន្ត្រីដែលចេះបម្រើរាស្ត្រ
តែងមានតេជៈជាប្រចាំ។

*មន្ត្រីនាំទុក្ខកង្វល់ដល់រាស្ត្រ
គួរតែជម្រះវះយកសាច់ស្អុយ។

*មន្ត្រីពុករលួយតែងជីកឫសក្តិចត្រួយ
មិនគិតខ្វល់ព្រួយជួយស័ង្គមឲ្យខ្ពង់ខ្ពស់។

*មន្ត្រីមានគំនិតអាត្មានិយម
រាស្ត្ររងទុក្ខធំព្រោះពំនាក់អាស្រ័យ។

*មន្ត្រីមិននាំទុក្ខភ័យដល់រាស្ត្រ
ទើបមានតេជះឈ្នះមារសត្រូវ។

*មន្ត្រីរដ្ឋធ្វើគំរូដល់រាស្ត្រ
គឺជាតេជះនាំរាស្ត្រសុខដុម។

*មន្ត្រីបូកធំ
មិនអាចពូតផ្ដុំ ចិត្តសាស្ត្រចូលរួម។

*មន្ត្រីលោភលន់
នាំទុក្ខទារុណដល់រាស្ត្រប្រជា។

*មន្ត្រីវាយឫករាងជំនាញត្រួតត្រា
រាស្ត្រមិនត្រូវការមាំនតែដាក់បណ្តាសាថែម។

*មន្ត្រីសាច់ស្អុយគួរជម្រះ ទុកនាំវិនាសដល់រាជការ។

*មន្ត្រីឡេមឡឺមចង់បានតែអំណាច
មិនចេះកោតខ្លាចទុករាស្ត្រជាធំ។

*មន្ត្រីឡេមឡឺមច្រើនជ្រើមតាមគ្នា
នាំរាស្ត្រប្រជាវេទនាប្រចាំ។

*មន្ត្រីអាជ្ញាធរអាក្រក់ឬល្អ
រាស្ត្រប្រជានិករចាំជាប្រវត្តិ។

*មានកង្វៃទើបដំរីខ្លាច
មានអ្នកប្រាជ្ញទើបជាតិសុរងរឿង។

*មានគប្បីចេះសំចៃ
មិនមិនក្សីយធននាំឲ្យក្រ។

*មានគំនិតនិងមារយាទ
ប្រមូលបានញាតិទ្រព្យធន។

*មានគំនិតមិនសម្រេចចិត្តធ្វើ
ព្រោះមិនជឿលើគំនិតខ្លួនឯង។

*មានចំណេះដឹងច្រើន ចម្រើនប្រទេសជាតិ។

*មានជំនួយតែគ្មានគំនិត
ប្រៀបបានត្រឹមគិតតែមិនធ្វើ។

*មានតែភាពប្រែប្រួល ដែលមិនប្រែប្រួល។

*-មានត្រឹមរោហារមិនស្តាប់គេឯង
និយាយក្តែងៗថាខ្លួនអស់អញ។

*មានថ្ងៃនេះគួរគិតពីថ្ងៃមុន
ពីឧបការគុណនាំដល់ថ្ងៃនេះ។

*មានទ្រព្យសម្បត្តិគ្រប់គ្រាន់
តែពុំស្ទើទាន់វិជ្ជា។

*មានទ្រព្យរបស់ហើយមិនចេះថែ
រឬតផុតបែរទើបនឹកស្តាយក្រោយ។

*មានភ្នែកត្រូវឱ្យចេះមើល
កុំមើលហើយមិនហ៊ានឃើញ។

*មានសត្រូវនឹងបណ្ឌិត
ប្រសើរមានមិត្តអន្ធពាល។

*មានសីលពីក្មេង ទើបមិនវង្វេង
ដល់ពេលជិតស្លាប់។

*មានអនាម័យល្អ
សុខភាពល្អ។

*មារយាទក្របង្កឱ្យខូចយស
បាត់កេរ្តិ៍បង់ឈ្មោះសន្ដានអសោច។

*មារយាទថោកថ្លៃអាស្រ័យទង្វើ
កំណត់នៅលើការប្រតិបត្តិ។

*មារយាទថោកមិនដែលធ្វើអ្វីថ្លៃ
ព្រោះមាននិស្ស័យធ្វើតែអាក្រក់។

*មារយាទថ្លៃគឺប្រពៃខ្ពង់ខ្ពស់
ចោកវិញខូចឈ្មោះតពូជសន្តាន។

*មារយាទបង្ហាញពីទឹកចិត្ត ដែលបានកម្រិតន្ទវតម្លៃ។

*មារយាទអាចកំណត់ន្ទវាសនា
ជាផលផ្លែផ្កាឬបរាជ័យ។

*មាសប្រាក់ជាទ្រព្យក្រៅប្រាណ
ឯចិត្តទើបបានក្នុងប្រាណប្រាកដ។

*មាសប្រាក់យសសក្តិមានកន្លង
ហេតុជាចម្បងដោយមារយាទ។

*-ម៉ាស៊ីនឆេះដោយប្រព័ន្ធដំណើរការ
ប្រទេសថ្លៃថ្លាដោយសារអ្នកចេះដឹង។

*មិត្តពេលស៊ីផឹកគឺរកបានងាយ
ជួបគ្រោះអន្តរាយមិនងាយរកមិត្ត។

*មិត្តល្អឲ្យសុខ បាបមិត្តឲ្យទុក្ខគ្រប់ទិនទិវា។

*មិនខ្វះទេជំនួយ បើចេះផ្តើមជួយខ្លួនឯងមុន។

*មិនច្បាស់កុំបង្រៀន បើបង្រៀនកុំឲ្យខុស។

*មិនប្រាកដថាមេចាំតែដឹក
កិច្ចខ្លះកូនថ្មីកនាំមេក៏មាន។

*មិនអាចផ្តាប់ចិត្តអ្នកអាត្មានិយមបាន
ព្រោះតែសន្តានមិនខ្វល់ពីអ្នកដទៃ។

*មុនជាស់តឿនដល់អ្នកដទៃ
ត្រូវស្គាល់តម្លៃខ្លួនឯងសិន។

*មុនទូន្មានគេត្រៀមទូន្មានខ្លួនឯង
ទើបមិនកោតក្រែងពេលទូន្មានគេ។

*មុននឹងជឿគួរមើលមារយាទ
ទើបមិនចាញ់ស្មៀតនូវការបោកប្រាស់។

*មុននឹងថា
ត្រូវគិតពីផែនការដែលធ្វើឲ្យសម្រេច។

*មុននឹងថាអាចធ្វើខ្លួនឯងកើត
ទើបជាកំណើតអ្នកដឹកនាំល្អ។

*មុននឹងធ្វើត្រូវគិត
រួចពិនិត្យសឹមពិចារណា។

*មុនពេលចូលគេង
ពួកយើងក្មេងៗត្រូវដុះធ្មេញរៀងរាល់យប់។

*មូលដ្ឋានគ្រឹះនៃមនុស្សល្អ
គឺគិតល្អធ្វើល្អលទ្ធផលល្អ។

*មួយមិន ប្រាំមាន គឺជាវិញ្ញាណនៃអ្នកដឹកនាំ។ ១មិន÷ មិនអាត្មានិយម, ៥មាន÷ មានឆន្ទៈ, មានការអត់ធ្មត់, មានការព្យាយាម, មានការស្មោះត្រង់, និងមានការលះបង់។ (ទស្សនៈនេះលោកនាយកយកមកប្រើជាប្រចាំ)។

*មើលឃើញគេស្អាត
គប្បីវែឆ្ងាតធ្វើឲ្យស្អាតដូចគេ។

*មេកុំធ្វើល្អតែនឹងមុខ
ប្រព្រឹត្តអាក្រក់ពីក្រោយ។

*មេជាយជាល្បាយបង្កើតយស
អ្វីល្អជាងនោះគឺយសមហាជនផ្តល់ឲ្យ។

*មេដឹកនាំបើកបេះដូងជូនកូនចៅ
ជាពូជតណៅនៃបណ្ឌិត។

*មេផ្ទះទៅផ្សារ អ្នកត្រូវដឹងថា
ចំណែកថវិកាខ្លះជាសំរាម។

*មោទនភាពជាតិ
ផ្តើមពីមន្ត្រីបម្រើញាតិមានរបៀបថ្លៃថ្នូរ។

*ម្ហូបអាហារដែលសម្លាប់គឺមានពីរ
មួយជាតិគីមីពីរគ្មានអនាម័យ។

៥៥ ~ ៦០

*យើងជាសិស្សសាលា មិនត្រូវសេពសុរា
កញ្ឆានិងជក់បារី។

*យើងជាសិស្សសាលា
ព្យាយាមសិក្សាឲ្យជាប្រចាំ។

*យើងត្រូវរួមគ្នាទប់ស្កាត់ការពារ
ទើបអាចឈ្នះមារកូវីដប្រល័យ។

*យើងធ្វើគុណកុំគិតពីគេសង
ទើបជាបំណងអ្នកមានគុណធម៌។

*យើងធ្វើគុណលើគេកុំសម្តែង
គេធ្វើគុណលើឯងកុំបំភ្លេច។

ទ ~ វ

*រក្សាញាតិមិត្តជិតខាងធ្វើជារបង
ប្រសើរកន្តែងជាងធ្វើរបងជិតជុំ។

*រស់ក្នុងសង្គមត្រូវការពឹងពាក់
តែកុំឲ្យធ្លាក់ដល់ការពឹងផ្អែក។

*រស់ជាម្ចប់ឲ្យគេសុខសាន្ត
ទើបបានជាមនុស្សសកល។

*រស់មិនរំខានដល់អ្នកដទៃ
គឺរស់មានន័យប្រសើរកន្តែង។

*រស់ឲ្យមានស្មារតីចេះជួយ
កុំរស់លើព្រួយអ្នកដទៃ។

*រាក់ទាក់ តែមិនអង្វរករ, ម៉ឺងម៉ាត់ តែមិនកោងកាច,
ទន់ភ្លន់ តែមិនទន់ជ្រាយ, សាមញ្ញ
តែមិនធម្មតា។

*រាសីខ្ពស់ទាបមកពីអំពើ
ដែលប្រព្រឹត្តធ្វើដោយមារយាទថ្លៃ។

*រាស្ត្រមានទឹកចិត្តស្រឡាញ់មន្ត្រី
ព្រោះចិត្តភក្តីស្មោះត្រង់នឹងរាស្ត្រ។

*រាស្ត្រលំបាកដោយមន្ត្រីពុករលួយ
រាស្ត្រមានទុក្ខព្រួយព្រោះមន្ត្រីខិលខូច។

*រាស្ត្រសាងជាតិ
មារយាទសាងវិជ្ជា។

*រូបកាយចាស់តែនៅថ្មីគំនិត
មិននាំជីវិតងងឹតតាមប្រាណ។

*រូបកាយបាត់បង់ទៅមែនពិត
ឲ្យតែគំនិតនៅរស់ក្បែរកាយ។

*រូបរាងក្រៅស្អាតឬមិនស្អាតអាចដឹង
តែមិនអាចថ្លឹងដឹងចិត្តល្អឬអាក្រក់។

*រួមគ្នាគិតធ្វើអំពើថ្លៃ
ទើបជានិស្ស័យមនុស្សល្អ។

*រៀនកាន់តែច្រើនចម្រើនឆ្ងល់
នោះទើបបានដល់ជាបណ្ឌិត។

*រៀនគិតរៀនពិចារណា
ទើបនាំវាសនាដូចពេជ្រថ្មែ។

*រៀនចេះជួយដល់អ្នកដទៃ
មានតម្លៃជាមនុស្សធម៌។

*រៀនថ្ងៃមិនគ្រប់ឃប់បន្ថែម
ទើបជាបង្អែមនៃជីវិត។

*រៀនឲ្យចេះគិត បង្កើតនូវគំនិតថ្មី

*រៀនឲ្យមានមិត្តចេះជួយមិត្តជាប្រចាំ។
(ទស្សន:វិស័យ)។

*រៀនឲ្យមានស្មារតី គឺឲ្យចេះច្នៃប្រតិដ្ឋ

*រៀនគន់រៀនគិត ទើបមានគំនិតធ្វើ។

*រៀនចេះជួយដល់មិត្តភក្តិ
មានពំនាក់ក្នុងសន្តាន។

*រៀនចេះពិត
មកពីគំនិតចេះស្រាវជ្រាវ។

*រៀនដើម្បីជីវិតរស់
ទើបជាឈ្មោះអ្នកព្យាយាម។

*រៀនដោះស្រាយដោយបញ្ញា
ទើបគ្មានបញ្ហាជីវិត។

*រៀនធ្វើផែនការ សម្រាប់ការអនុវត្ត។

*រៀនពីពិភពពិត ទើបជីវិតរុងរឿង។

*រៀនពីសង្គមគ្រួសារសាលា
គឺជាកត្តាវាសនាជោគជ័យ។

*រៀនពីហេតុ ទើបសង្កេតឃើញផល ស្វែងហេតុ
ដិតដល់ បានផលពណ្ណរាយ។

*រៀនមើលរៀនស្តាប់រៀនត្រាប់
ទើបអាចឆាប់ចេះចាំបាន។

*រៀនសង្កេតនិងពិនិត្យ
ជាគ្រូពិតនៃចំណេះ។

*រៀនឲ្យចេះមេត្តា
គឺជាខ្លឹមសារនៃមនុស្សពិត។

*រៀនឲ្យចេះអាណិត
ទើបស្គាល់ពិតជីវិតសង្គម។

*រៀនឲ្យមានគំនិតធ្ងុំ
ទើបសុខដុមធ្ងុំកម្លាំងប្រាជ្ញ។

*រៀនឲ្យមានទម្លាប់ល្អ
កម្រចោលមារយាទ។

*រៀនឲ្យហ្មត់ចត់
ប្រាកដជាជីវិតជោគជ័យ។

*រិះគន់មិនពិចារណា
បានត្រឹមថាតែធ្វើមិនកើត។

*ឫស្សីតែងតែដុះជាគុម្ព
គំនិតពួនធ្ងុំសុខកន្លង។

*ឫស្សីតែងតែដុះជាគុម្ព
គួររស់ជាក្រុមដូចឫស្សី។

ល ~ ឲ

* លក្ខណៈសម្បត្តិនៃមនុស្សជោគជ័យ
  មានស្មារតីជ្រះថ្លាផ្តល់តម្លៃដល់សង្គម។

* លទ្ធផល ជាម៉ែត្រវាស់នូវគុណភាព។

* លទ្ធផលជាម៉ែត្រវាស់ការគិតត្រូវខុស
  លទ្ធផលអាចឆ្លុះពីគំនិតជាក់ស្តែង។

* លទ្ធផលនៃការសិក្សាអប់រំ
  ចំណេះផ្សំផ្គុំទ្រឹស្តីប្រតិបត្តិ។

* លទ្ធផលសិក្សារបស់កុមារ
  បើមានយន្តការមានការប្រែប្រួល។

* លុយកាក់ប្រាក់កាសគង់អាចរកបាន
  តែចិត្តសន្តានរកដោយលំបាក។

*លុយធ្វើឲ្យមានកិត្តិយស
លុយអាចនាំគ្រោះខ្ចចឈ្មោះបាន។

*លង់គប្បីស្វែងរកប្រភពចេះ
ទើបមានតម្រិះសិក្សាភាពលង់។

*លង់តាំងខ្លួនចេះបាត់ន្ទូវតម្លៃ
គឺជានិស្ស័យអាចារ្យតាចាំ។

*លង់ព្យាយាមគង់អាចចេះ
រលុងតម្រិះគិតលង់។

*លង់ព្យាយាមគង់ចេះ
រលុងតម្រិះខ្ចៅ។

*ល្បែងស៊ីសងលេងតាមទីសាធារណៈ
ដូចហែកកើរ្តីខ្លាសបង្ហាញញាតិដងផ្លូវ។

*ល្វីងជូរចត់ជាឱសថកែរោគ
ផ្អែមតែស្មោកគ្រោកជារោគប្រហារ។

ទ ~ វ

*វត្តមានអ្នករៀននិងអ្នកបង្រៀន
ជះផលវិជ្ជមានដល់ការសិក្សា។

*វ័យចាស់គិតច្បាស់ចំណេះដឹងថ្មី
ទើបជាចាស់ខ្ចីមានន័យប្រាកដ។

*វ័យចាស់បានបង្កើតគំនិតថ្មី
ព្រោះនិស្ស័យវ័យនៅតែក្មេង។

*វាសនាពឹងលើអំពើគំនិត
កំពុងប្រព្រឹត្តធ្វើជាប្រចាំ។

*វេលាទៀងទាត់នៅមិនទៀងទាត់
ព្រោះតែវាលវដ្តផ្លាស់ប្តូរវេលា។

*វិជ្ជាជាមិត្ត

លោកិយពិត ជីវិតថ្កាន។

*វិជ្ជាវិសេសលើសទ្រព្យធន

ចោរខំប្រឹងប្តន់លួចមិនបាន។

*វិធីសាស្ត្របង្រៀនល្អតែមិនប្រើ

ដូចអ្នករៀនដើរលើជណ្តើរគ្មានកាំ។

*វិន័យគឺជាអាទិកន្តង

អាចនាំបំណងកិច្ចការសម្រេច។

*វិន័យជាកត្តាចម្បង

អាចនាំបំណងសិក្សាសម្រេច។

*វិបាកគុណទោសអាស្រ័យអ្នកធ្វើ

ញាតិរង់ចាំមើលផ្តល់វិនិច្ឆ័យ។

ស ~ ស

* សកម្មភាព
ជាម៉ែត្រវាស់នូវសមត្ថភាព។

* សកម្មភាពដែលមានពិតៗ
បញ្ជាក់ជីវិតប្រចាំថ្ងៃ។

* សង្គមដែលមានអត្រាអាត្មានិយមខ្ពស់
បញ្ហាជម្លោះក្នុងសង្គមមានកាន់តែច្រើន។

* សង្គមប្រែប្រួលព្រោះជួយពីញាតិ
ពីគ្រប់សញ្ជាតិទើបជាតិថ្កុំថ្កើង។

* សង្គមអភិវឌ្ឍព្រោះអប់រំល្អ
ដែលបានបង្កឲ្យគ្រួសារចូលរួម។

* សង្វេគព្រោះតែហេតុអវិជ្ជា
កំពុងរកទ្វារមហន្តរាយ។

* សង្វេគព្រោះហេតុអវិជ្ជា
នាំទុក្ខវេទនាដល់រូបកាយ។

* សញ្ញាបត្រគ្រាន់តែជាការបញ្ជាក់
លទ្ធផលជាក់លាក់អនុវត្តជាក់ស្តែង។

* សញ្ញាបត្រទុកសម្រាប់សម្គាល់
តម្លៃបន្ទាល់គឺលទ្ធផលពិត។

* សញ្ញាបត្រនៅលើក្រដាស
ការងារមិនច្បាស់គ្មានលទ្ធផល។

* សញ្ញាប័ត្រមានតែធ្វើមិនបាន
មិនអាចប្រែប្រាណមានជីវភាពល្អ។

* សត្វក្រពើសប្បាយ សត្វប្រើសខ្វល់ខ្វាយ
រកកន្លែងជ្រកកាយ ព្រោះភ្លៀង
ជន់លិច។ (សត្វទាំងពីរក្បាល
ដែលខ្ញុំចិញ្ចឹមមានគំនិតខុសគ្នា ក្នុង
ស្ថានភាពតែមួយ)។

*- សត្វរស់ដោយសារប្រព័ន្ធក្នុងខ្លួនដើរ
ប្រទេសប្រសើរដោយសារអ្នកចេះដឹង។

* សប្បាយមួយពេលកើតទុក្ខភ័យ
នាំឲ្យអស់ន័យមួយជីវិត។

* សប្បុរសហុតទឹកសម្លឹងកាក
ព្រោះក្រតោកយ៉ាកសតិស្មារតី។

* សព្វថ្ងៃមានអ្នកធ្វើបុណ្យច្រើនណាស់
ប៉ុន្តែនៅខ្វះអ្នកមានចិត្តបុណ្យ។

* សមត្ថកិច្ចដែលមិនគោរពច្បាប់
កំពុងបង្ហាប់រដ្ឋាភិបាល។

* សមត្ថភាពពិតខ្លួនឯងជាអ្នកដឹង
គួរខិតខំប្រឹងរៀនត្រង់មិនដឹងពិត។

* សមត្ថភាពពិតនាំជីវិតថ្លៃ
ដូចជានិស្ស័យថ្លៃរាសីល្អ។

* សមត្ថភាពពិតបង្កើនស្មាដៃ
គឺជានិស្ស័យនៃក្តីព្យាយាម។

* សមត្ថភាពពឹងលើចំណេះមារយាទ
ចេះតែចោលម្យៀតឆ្លៀតអាត្មានិយម។

* សមត្ថភាពវាស់ដោយលទ្ធផល
ភាពខ្ជះខ្ជាយវាស់ដល់មារយាទ។

* សមិទ្ធផលដែលកើតពីជំនួយ
ត្រូវត្រៀមគិតព្រួយក្រោយជួយបញ្ចប់។

* សម្តីគគ្រោតគគ្រាត
នាំឲ្យញាតិសៅហ្មងចិត្ត។

* សម្តីដែលគ្មានការពិត
ដូចកាំបិតចិតដងឯង។

* សម្តីដែលចាត់ទុកមិនបានការ
គឺបានត្រឹមថាតែធ្វើមិនកើត។

* សម្តីដែលសោះកក្រោះ
ផលអសប្បុរសនៃចិត្ត។

* សម្តីបណ្ឌិតតែងខុសពីពាល
មិនដែលតិះដៀលដល់អ្នកដទៃ។

* សម្តីបណ្ឌិតតែងជាប្រយោជន៍
ពាក្យពាលរោលខ្ចោចចោកដល់សង្គម។

* សម្តីបណ្ឌិតស្តាប់ហើយរើសទុក
តំណទៅមុខអាចមានតម្លៃ។

* សម្តីផ្ដែមខ្លឹមសារពិសពុល
គឺជាបុគ្គលត្រូវចៀសឲ្យឆ្ងាយ។

* សម្តីដែលសោះកក្រោះ
ផលអសប្បុរសនៃចិត្ត។

* សម្តីថ្លៃគឺពោលពាក្យពិតមានប្រយោជន៍
សម្តីអសោចគ្មានប្រយោជន៍អស់តម្លៃ។

* សម្តីពាក្យពិតនៃបណ្ឌិត
មិនបានសណ្ឋិតក្នុងចិត្តពាល។

* សម្តីបណ្ឌិតមិនប្រាកដថាត្រូវ
បើអ្នកស្តាប់នៅចាំចាប់កំហុស។

* សម្តីពីរោះកុំទាន់ថាល្អ
ទង្វើស្មោះសទើបថាល្អពិត។

* សម្តីពីរោះនឹងមិត្តមិនងាយធ្វើបាន
សម្តីនឹងកល្យាណគ្មានរសងាយធ្វើកន្តង។

* សម្តីមិនបានការ
គឺជាបន្ទាក្នុងបេះដូងនៃអ្នកស្តាប់។

* សម្តីមួយម៉ាត់មានគាប់មានទាស់
ដល់ជនទាំងអស់កំពុងចាំស្តាប់។

* សម្តីរោយរាយឥតប្រយោជន៍
បានត្រឹមអសោចកិត្តិយស។

* សម្តីល្អកម្រពាលឲ្យតម្លៃ
ពាក្យពេចន៍មិនថ្លៃពាលចងចាំចេះច្បាស់។

* សម្តីល្អតែគ្មានការពិត
ប្រៀបដូចកាំបិតចាំប្រហារ។

* សម្តីអាក្រក់មិនប្រាកដថាមិនល្អ
សម្តីផ្អែមដូចស្ករមិនប្រាកដថាមិនអាក្រក់។

* សម្តីអាក្រក់ឬល្អមិនជាថ្វី
ឲ្យតែមានន័យស្វ័យតម្លៃសង្គម។

* សម្តីអាចប្រល័យនូវគំនិត
និយាយមិនគិតខាតបង់តម្លៃ។

* សម្តីអាចារ្យអាចជាឱសថ
ក៏ជាទឹកក្រូដបំផ្លាញអារម្មណ៍។

* សម្តីអ្នកដទៃដែលគ្មានន័យ
ជាមេរៀនរាល់ថ្ងៃនៃជីវិត។

* សម្តីអ្នកដទៃដែលមានន័យ
ស្តាប់ហើយលកលែងច្នៃប្រតិបត្តិ។

* សម្តីអ្នកដទៃមានឬគ្មានន័យ
ស្តាប់ហើយត្រូវច្នៃឲ្យជាប្រយោជន៍។

* សម្តីប្រៃមួយចុបសាបមួយដៃ
ខូចឈ្មោះមួយថ្ងៃល្បីមួយជីវិត ។

* សម្តីសាបប្រៃអាស្រ័យលើអ្នកដាំស្ត
ចិត្តអាក្រក់ល្អព្រោះសារជាតិនៃបុគ្គល។

* សម្តីសាបប្រៃអាស្រ័យអ្នកភ្លក្ស
ដឹកនាំវិវក់ព្រោះគ្មានឧបាយ។

* សម្តីសាបប្រៃអាស្រ័យអ្នកភ្លក្ស
អ្នកខ្ជិលទ្រមក់ជីវភាពមិនថ្លៃ។

* សម្តីងមើលជិតត្រូវគិតឲ្យឆ្ងាយ
ទើបមិនអន្តរាយដល់កិច្ចការធំ។

* សម្លេងតន្ត្រីពីរោះទៅបាន
ដោយមិត្តគ្រប់ប្រាណមូលចិត្តសាមគ្គី។

* សម្អាតផ្ទះឯងយកសំរាមចោលផ្ទះគេ
មានដែលគិតទេសំរាមគេចោលផ្ទះឯង។

* សម្អាតសាលារៀនដូចភ្លៀងរលឹម
ទើបអាចសង្ឃឹមមានបរិស្ថានល្អ។

* សាមគ្គីល្អ
កិច្ចការបវរ ប្រសើររុងរឿង។

* សាមគ្គីល្អ
កិត្តិយសបវរ ប្រសើរឧត្តម។

* សាមគ្គីជាកម្លាំង
បែកកម្លាំងរលាយ។

* សាមគ្គីមនុស្សជាកម្លាំងទីមួយ
ជម្រុញលើកស្ទួយអង្គភាពអភិវឌ្ឍន៍។

* សារជាតិក្រពើមិនដែលស្គាល់ម្ចាស់
ពាលកម្រណាស់ស្គាល់គុណតម្លៃ។

* សារជាតិជាមនុស្សក្រពើ
មិនដែលអើពើគុណអ្នកដទៃ។

* សារជាតិនៃជនសប្បុរស
មិនរំពឹងសោះពីការតបស្នង។

* សារជាតិនៃមនុស្សក្រពើ
មិនដែលនឹកធ្វើតបគុណតម្លៃ។

* សារប្រយោជន៍នៃបណ្ណាល័យ
គឺជាលទ្ធផលចុងក្រោយនៃអ្នកស្រាវជ្រាវ។

* សាលារៀនចាស់ផ្លាស់ប្តូរឲ្យថ្មី
ព្រោះតែនិស្សិយថែទាំបានល្អ។

* សាលារៀនដែលថ្កើងថ្កានបាន
ដោយសារសន្តានគ្រូបង្រៀន។

* សាលារៀនដែលមានសោភណភាព
គ្រូនាំគ្នារៀបដោយចិត្តមេត្រី។

* សាលារៀនគ្មានតម្រូវការ
ថ្នាំញៀនកញ្ឆាស្រាបារី។

* សាលារៀនមួយមានតួឯកបួន
ទើបជួយអង្រួនការអភិវឌ្ឍ។ (១-
ថ្នាក់ដឹកនាំសាលា, ២-គ្រូបង្រៀន,
៣-មាតាបិតាសិស្ស, ៤-សិស្សានុសិស្ស)។

* សាលារៀនស្អាតកើតចេញពីបេះដួង
ទើបជាគន្លងអភិវឌ្ឍនិរន្តរ៍។

* សាលារៀនស្អាតបង្រៀនមិនល្អ
សិក្សាកម្របានដោយប្រពៃ។

* សាលារៀនស្អាតមិនមែនគ្មានសំរាមទេ
ប៉ុន្តែសាលារៀនដែលមានសំរាម
ហើយគ្មានសំរាមទើបជាសាលារៀនល្អ។

* សាលារៀន គឺជាបរិស្ថានអប់រំដែលត្រូវឆ្លើយតប
តម្រូវការបានរបស់សិស្ស។

* សាលារៀនគ្មានការគាំទ្រពីគ្រួសារ
លទ្ធផលសិក្សាកុមារនៅមានកម្រិត។

* សាលារៀនគ្មានការគាំទ្រពីគ្រួសារ
ធ្វើឲ្យកុមារគ្មានអនាគត។

* សាលារៀនដែលមានគុណភាព
គឺបរិស្ថានស្អាតប្រសិទ្ធភាពរៀនល្អ។

* សាលារៀនមានបរិស្ថានស្អាត
ដោយភាពវៃឆ្លាតនៃគ្រូបង្រៀន។

* សាលារៀនស្អាត
នាយកសង្វាតចលនាចូលរួម។

* សិក្សាពីបញ្ហាជាឧបាយ
ដែលអាចដោះស្រាយនូវឧបសគ្គ។

* សិស្សដែលល្អទៅបាន
ដោយភាពស្និទ្ធស្នាលពីគ្រូបង្រៀន។

* សិស្សដែលអាចល្អទៅបាន
ដោយភាពស្និទ្ធស្នាលពីគ្រូ។

* សិស្សដែលខុសស្បាហ៍
ត្រូវថែរក្សាបរិស្ថានសាលាឲ្យស្រស់បំព្រង។

* សិស្សមិនត្រូវទុកគ្រូត្រឹមស្ពានឆ្លង
គិតពីគុណផងទើបជាកតញ្ញូ។

* សីលក្នុងចិត្តប្រកបដោយវត្ត
ទើបបានជាប់រក្សាសីលល្អ។

* សីលក្នុងចិត្តប្រតិបត្តិក្រៅខ្លួន
តម្លៃមាំមួនដោយភាពសុចរិត។

* សីលក្រៅខ្លួនមិនមាំមួនដូចក្នុងចិត្ត
ដែលនាំជីវិតបដិបត្តិដោយស្មោះស។

* សីលដែលប្រាកដ
គឺចិត្តតែងស្ងប់ សង្វេគព្រោះកម្ម។

* សីលដែលមិនជាច់ធ្វើតាមសិក្ខា
កុំចេះសូធ្យថាកំដរតែបុណ្យ។

* សុខចិត្តធ្វើល្អឲ្យគេស្អប់
តែបានបង្កប់ក្តីស្រឡាញ់។

* សុខភាពមាត់ធ្មេញប្រសើរកន្តង
ញ៉ាំដុសធ្មេញផងក្នុងពេលមួយថ្ងៃ។

* សុជីវធម៌នៃអ្នកបើកបរ
គោរពចរាចរណ៍តាមដងផ្លូវ។

*- សុភាសិតល្អច្រើនតែបំភ្លេច
បើពាក្យគគ្រិចបំភ្លេចមិនបាន។

* សៀវភៅ
គឺជាឃ្លាំងដែលផ្ទុកនូវចំណេះដឹង។

*សៀវភៅ

គឺជាមិត្តពិតដែលស្ម័គ្រចិត្តតាមបម្រើ។

*សៀវភៅបិកជាមិត្តដ៏ប្រសើរ

អាចនាំអ្នកដើរឆកជីវិតពិត។

*សៀវភៅបិកមិត្តប្រសើរគាប់

អ្នកឆ្លាតទើបរាប់ជាមិត្តបាន។

*សេចក្តីក្រោធ

បណ្តាលមកពីឆោតល្ងង់។

*សេចក្តីប្រមាទតែងនាំឲ្យឆ្ងោយ

បាត់លាភញយៗដោយការប្រមាទ។

*សេចក្តីប្រមាទ

នាំឲ្យខូចខាតបាត់បង់តម្លៃ។

*សេចក្តីមានះក្រោធ

គ្មានការកោតសរសើរ។

*សេចក្តីល្ងង់ផ្សុំខ្ជះខ្ជាយខ្ជិល
ជាមន្ទិលនៃភាពក្រីក្រ។

*សេចក្តីល្អកម្រនឹងរក
ខ្ជះខ្ជាយស្មោកគ្រោករកបានងាយ។

*សេចក្តីល្អមិនកប់នៅបាតពាង
សប្បុរសរាល់រៀងកុសលប្រចាំ។

*សេចក្តីវិនាស
ព្រោះចិត្តមានះជាហេតុត្រូវចាំ។

*សេចក្តីសុខទុក្ខមិនទៀងគ្រប់ប្រាណ
ដែលអាចកើតបានគ្រប់ពេលវេលា។

*សេចក្តីសុខទុក្ខ
អំពើត្រីមុខប្រតិបត្តិចម្បង។

*សេចក្តីសុខព្រោះមិនលោភលន់
ដែលនាំទារុណដល់រូបកាយចិត្ត។

*សេចក្តីសុខមិនមែនការបន់ស្រន់
បង្ការអាសន្នបានបន់សុខពិត។

*សេដ្ឋីមានចិត្តសប្បុរសពិតៗ
មិននាំជីវិតហុតទឹកសម្តីងកាក។

*សេពគប់ជាមួយអ្នកប្រាជ្ញ
អ្នកនឹងអាចជាបណ្ឌិត។

*-សេពគប់បណ្ឌិតជីវិតរុងរោចន៍
គប់ពាលអសោចហិនហោចកេរ្តិ៍ឈ្មោះ។

*សេពមិត្តដែលជួបចេះជួយពេលក្រ
ទើបជាមិត្តល្អជាងជួបពេលសប្បាយ។

*សេពសុរាថាកំដរបុណ្យ
ជាពាក្យដោះកុននៃអ្នកផឹក។

*សំណាងពឹងចំណេះ
ប្រាជ្ញចេះពឹងគម្ពីរ។

* សំពះស្អាតញញឹមស្រស់ប្រតិបត្តិល្អ
គឺជាសរអប់រំឥរិយាបថថ្លៃ។

* សំពះស្អាតញញឹមស្រស់ប្រតិបត្តិល្អ
ជាគ្រឿងលម្អន្ធវត្ថែបុគ្គលឆ្នើម។

* សំរាមចាំតែបោសនិងរើស
ចោលមិនចេះទើសរើសតចៅ។

* សំរាមត្រូវសម្អាតជាបន្ត
កុំចាំភ្ញៀវមកទើបចេះសម្អាត។

* សំរាមបង្ហាញពីមារយាទ
គំនិតចោលម្សៀតឬតម្លៃ។

* សំរាមប្រៀបដូចជាសត្រូវ
បើទុកវានៅនាំបាត់យស។

* សំរាមមានឬគ្មានផ្តើមពីខ្ញុំ
ដូច្នេះគួរកុំសំរាមធ្វើម្ចាស់។

* សំរាមអាចច្នៃលក់បានជាកម្រៃ
បើទុកមិនថ្លៃតម្លៃគំនិតថោក។

* ស្គាល់ចរិតពិតនៃបណ្ឌិត
មើលការប្រព្រឹត្តចិត្តសម្តី។

* ស្តាប់ច្រើនចាំទុកជាគ្រូ
គំនិតគិតគួរទុកពិចារណា។

* ស្តាប់ពាក្យទូន្មានប្រដៅមិនខ្ចៅគំនិត
នាំឲ្យជីវិតប្រព្រឹត្តតែអំពើថ្លៃ។

* ស្តាប់នូវពាក្យពេចន៍នៃបណ្ឌិត
បានជាគំនិតក្នុងសន្តាន។

* ស្តាប់ពាក្យពាលបាន
តែនាំរំខាន ជីវិតរស់នៅ។

* ស្តាប់មិនទាន់ចប់កុំប្រញាប់សន្និដ្ឋាន
បន្តតាមដានពិចារណាទើបគិតត្រូវ។

* ស្តាប់សម្រាប់គិត
ជាផ្លូវគំនិតនៃអភិវឌ្ឍន៍។

* ស្នាដៃការងារអង្គភាពអ្នកធ្វើ
មកពីថ្នាក់លើចេះវាយតម្លៃ។

* ស្នាដៃពិតពីគំនិតប្រតិដ្ឋថ្មែ
គឺជាបច្ច័យនៃតម្លៃដឹកនាំ។

* ស្តឲ្យសាប
សម្តីឲ្យទាប ប្រាជ្ញាវែ។

* ស្តាប់កាយតែសប្បាយចិត្ត
ព្រោះត្បិតបានប្រព្រឹត្តល្អ។

* ស្តាប់ព្រោះធ្វើល្អមានកេរ្តិ៍ឈ្មោះខ្លះ
ស្តាប់ព្រោះមាសប្រាក់រាស្ត្រជួយត្រេកអរ។

* ស្រមៃខ្ពស់ពេកបែរដេករង់ចាំ
ទោះរយសែនឆ្នាំនៅចាំជដែល។

* ស្រឡាញ់កូនមួយតៅចៅមួយតោន
ព្រោះតែជ្រកក្រោមនែម្តប់មេត្តា។

* ស្ត្រីរូបស្រស់សម្រស់ស្អាតតែមួយរយៈខ្លី
ស្តីបញ្ញាវៃចរិតថ្លៃស្អាតមួយជីវិត។

* ស្វាធ្យាយមិនគ្រាន់កុំទាន់ថាគ្រប់
មិនបានជាម្តប់ជីវិតរុងរឿង។

ឯ ~ ឰ

*ហ៊ានមើលឃើញស្តាប់គិតថា
ជាប្រការកែលម្អ។

*ហ៊ានមើលពិនិត្យស្តាប់គិតថា គឺជាប្រការកែលម្អ។

*ហ៊ីហាខ្ជះខ្ជាយមិនប្រមាណប្រាណ
គ្រាក្រោយគង់បានស្តាយសម្តាយក្រ។

*ហ៊ីហាតែកាយរហាមចិត្ត
ទុក្ខព្រួយជីវិតជាប្រចាំ។

*ហូបបន្តែច្រើន បង្កើនសុខភាព។

*ហូបស្អាត ផឹកស្អាត សុខភាពល្អ។

*ហេតុដែលប្រជែងគ្នាចាក់ដីខ្ពស់
ព្រោះតែរស់គ្មានការងឹកនាំល្អ។

*ហេតុមិនចំណុះត្រឹមតែពាក្យដោះសារ
ហ៊ានស្រាយបញ្ហាទើបកត្តាជោគជ័យ។

ឡ ~ ឡ

*ឡិកឡក់នឹងក្មេងរមែងអាប់យស
លលេងសត្វពស់គ្រោះដល់អាត្មា។

*ឡេមឡឺមឡិកឡក់រលាមលុតក្រាប
ជាថ្នាំបន្សាបតម្លៃខ្លួនឯង។

៥៩ ~ ៦៧

*អង្គភាពដែលទទួលបានលទ្ធផលល្អ
មកពីបុគ្គលិកស្មោះសរួមសាមគ្គី។

*អង្គភាពថ្កុំថ្កើង
គឺអាស្រ័យឡើងដោយភាពស្មោះត្រង់។

*អង្គភាពមានបុគ្គលអាត្មានិយម
នាំឲ្យសង្គមគ្មានការអភិវឌ្ឍ។

*អតីតកាលជាមូលដ្ឋានមេរៀន
បង្កើតជាស្ពានអនុស្សាវរីយ៍ពិត។

*អតីតកាលជាមេរៀន
បង្កជាស្ពានអនុស្សា។

*អតីតកាលដំណាក់តស៊ូក្រោក
មិននាំឲ្យសោកនៅពេលបច្ចុប្បន្ន។

*អធ្យាស្រ័យបានគប្បីធ្វើចុះ
កុំចាប់កំហុសដែលមានពីមុន។

*អនាគតភ្លឺថ្លានៃកុមារ
ពឹងលើសាលាគ្រួសារសង្គម។

*អនាម័យ
ជាភារកិច្ចនៃយើងទាំងអស់គ្នា។

*អន្ទិតពាលងាយវិនាស
គ្មានតេជះជួយសង្គម។

*អាចារ្យដែលស្វែងរកលាភ
នាំទន់ទាបដល់សាសនា។

*អានច្រើន ចេះច្រើន
កើនបញ្ញា។

*អានច្រើនបង្កើនចំណេះ
ធ្វេសប្រហែសនាំអន្តរាយ។

*អានច្រើនបានបង្កើនន្ធវការគិត
បង្កើតគំនិតថ្មីនិស្ស័យល្អ។

*អាហារដែលមានរសជាតិឆ្ងាញ់ពិត
ព្រោះបុិនប្រតិដ្ឋនៃអ្នកចម្អិន។

*អាហាររសឆ្ងាញ់ដោយចុងភៅចេះផ្សំគ្រឿង
អង្គភាពរុងរឿងដោយមេចេះផ្សំគំនិត។

*ឧបសគ្គមានសម្រាប់អ្នកធ្វើ
គិតមិនផ្តើមធ្វើបរាគំនិត។

*ឧបាយកម្មាយប្រាប់ការណ៍ពិត
ជួយវិធីគិតស្រាយបញ្ហា។

*ឧបាយកម្មាយប្រាប់ហេតុពិត
ពីជីវិតរស់ដោយសុខដុម។

*ឱកាសកម្រមានណាស់
ខូចឱកាសព្រោះអស់វេលា។

*ឪពុកម្តាយកូនត្រូវចិញ្ចឹមថែ
កុំដល់បែកបែរសែនរំឭកគុណ។

*ឪពុកម្តាយមិនដែលសំពះ
ពេលនិរាសទើបថ្ងាយបង្គំ។

*អំណាចយសស័ក្តិពឹងលើលទ្ធផល
ប្រើមិនមានផលនាំដល់បង់យស។

*អំនួតនាំឲ្យឆ្គួតតសន្តាន
លទ្ធផលវិញបានត្រឹមចេះតែថា។

*អំនួតនាំឲ្យមានវិបត្តិ
កិច្ចខ្លះចាំបាច់មិនសម្រេចធ្វើបាន។

*អំពើជាក់ស្តែងនៃមនុស្សមានមារយាទមិនថ្លៃ
នាំចង្រៃដល់សង្គមគ្មានការអប់រំជាមូលដ្ឋាន។

*អំពើតែងពឹងលើគំនិត
ការប្រព្រឹត្តបង្ហាញមារយាទ។

*អំពើត្រូវពឹងលើមារយោទ
ជាសារធាតុនៃលទ្ធផល។

*អំពើនិងសម្តី
ជាតម្លៃនៃជីវិត។

*អំពើបណ្ឌិតមិនស្រណុកចិត្តកាយ
អំពើសប្បាយពាលងាយនឹងប្រព្រឹត្ត។

*អំពើល្អត្រូវត្រដង្ផើខ្លួនឯង
ទើបជាកន្លែងនៃក្តីសុខនិរន្តរ៍។

*អំពើល្អនាំឲ្យមានសេចក្តីស្ងប់
ចៀសទុក្ខគ្រប់សព្វនាំសុខសន្តិភាព។

*អំពើល្អអាចបន្តវង្សត្រកូល
អាក្រក់ជាស្នូលនាំបាត់កិត្តិយស។

*អំពើអាក្រក់ល្អកើតចេញពីចិត្ត
កំពុងសណ្ឋិតក្នុងជីវិតរាល់ថ្ងៃ។

*អំពើអាក្រក់ល្អមិនប្រាកដលើមាត់ថា
មនសិការបេះដូងជាកត្តាកំណត់។

*អ្នកកុំគប្បីរំពៃទោសគេ
គួរគិតផងដែរទោសឯងប៉ុណ្ណា។

*អ្នកក្បត់មនសិការឆន្ទៈ
មិនអាចទាញទាក់អ្នកជំនាន់ក្រោយ។

*អ្នកក្រខំប្រឹងត្រដរធ្វើមាន
ភាពក្រកើតមានតរៀងសន្តាន។

*អ្នកក្រោមចេះភរ
អ្នកលើចំហឲ្យរៀនកុហក។

*អ្នកខាកស្តោះនៅតាមដងផ្លូវ
នាំប៉ះពាល់នូវដល់សុខភាព។

*អ្នកខាកស្តោះនៅតាមដងផ្លូវ
អត់ខ្មាសប៉ះត្រូវដល់អ្នកចរ។

*អ្នកខឹងព្រោះមិនព្រមដឹងខ្លួនខុស
កិច្ចកែកំហុសប្រទូស្តចង់ថ្លៃ។

*អ្នកខ្លៅគប់រកអ្នកប្រាជ្ញ
ក្រោយគង់អាចជាបណ្ឌិត។

*អ្នកគប្បីកុំឃើញតែគេខុស
ពិនិត្យឲ្យអស់ទើបដឹងបញ្ហា។

*អ្នកគិតថាគេមិនដល់អញ
អាចនាំឲ្យចាញ់ដល់អាត្មា។

*អ្នកគោរពច្បាប់ចរាចរណ៍
ជាពលរដ្ឋល្អនៃសង្គម។

*អ្នកគ្មានគំនិតគឺពិបាកជួយ
ប្រៀបបាត់អ្វីមួយក្នុងទឹកទន្លេ។

*អ្នកគ្មានមាសប្រាក់ប្រសើរជាងគ្មានវិញ្ញាណ
បើមានធនធានបាត់វិញ្ញាណគ្មានអ្វីសល់។

*អ្នកគ្រប់គ្រងគ្មានគុណធម៌
ប្រៀបដូចផ្នាំងថ្មនៅលើស្មៅ។

*អ្នកចចេសច្រើនតែអាងខ្លួង
វាយឫកកោងប្រើចរិតកាង។

*អ្នកចាត់ទុកគេអន់ជាងខ្លួនឯង
ត្រូវរកកន្លែងឯងគ្រាន់ត្រង់ណា។

*អ្នកចិត្តបុណ្យពិត
តែងមានគំនិតជួយអ្នកទុក្ខភ័យ។

*អ្នកចូលចិត្តសិក្សាសិល្បៈតន្ត្រី
ច្រើនធ្វើការអ្វីៗដោយចិត្តព្យាយាម។

*អ្នកចោលសំរាមក្នុងទឹកលើដី
ខូចគុណតម្លៃខ្លួននិងសង្គម។

*អ្នកចេះកែច្នៃប្រតិដ្ឋ
ទើបជីវិតគាប់ប្រសើរ។

*អ្នកចេះតែបង្កប់នូវចរិតអន់
កុំថាគ្រាន់ជាងអ្នកល្ងង់ចរិតល្អ។

*អ្នកចេះត្រឹមថា
ព្រោះខ្លាចគេថា ខ្លួនមិនអ្នកធំ។

*អ្នកចេះនិយាយប្រៀបដូចជាផ្កា
អ្នកចេះតែថាប្រៀបដូចលាមក។

*អ្នកចេះនិយាយប្រៀបដូចជាផ្កា
អ្នកចេះធ្វើការប្រៀបដូចជាផ្លែ។

*អ្នកចេះប្រដូចជីវិតខ្លួនឯងនឹងអ្នកដទៃ
ជាអធ្យាស្រ័យនៃអ្នកមានព្រហ្មវិហារធម៌។

*អ្នកចេះប្រាកដ
តែងព្យាយាមសព្វ នូវគ្រប់កិច្ចការ។

*អ្នកចេះប្រាកដ
មានភាពអំណត់ មិនជេរប្រមាថ។

*អ្នកចេះប្រើប្រាស់នូវសៀវភៅ
ជាពន្លឺនូវចំណេះដឹង។

*អ្នកចេះមិនប្រាកដថាដឹង
អ្នកខឹងមិនប្រាកដថាមិនក្រោធ។

*អ្នកចេះរៀបចំទុកជាក់ទ្រព្យ
ជាអ្នកមានភ័ព្វដ៏ប្រសើរ។

*អ្នកចេះសូធ្យធម៌មានច្រើនណាស់
ម្តេចបានខ្វះអ្នកប្រតិបត្តិធម៌។

*អ្នកច្បាំងមិនឈ្នះព្រោះចិត្តកំណាញ់
អ្នកច្បាំងដែលចាញ់ព្រោះចិត្តមានះ។

*អ្នកឆ្លាតក៏អាចនៅមានល្ងង់
អ្នកស្មោះត្រង់គង់នៅមានក្បត់។

*អ្នកឆ្លាតត្រូវរៀនពីអ្នកជោគជ័យ
រួចគិតកែច្នៃឲ្យជាប្រយោជន៍។

*អ្នកឆ្លាតមិនប្រមាទ
ទើបអាចបានជោគជ័យ។

*អ្នកគិតគំនិតរបស់គេ
គប្បីរិះរេគំនិតត្រូវ។

*អ្នកជាបណ្ឌិត
តែងតែគិតគំនិតអ្នកដទៃ។

*អ្នកជាបណ្ឌិត
តែងផ្សំគំនិតអ្នកដទៃ។

*អ្នកជោគជ័យអាស្រ័យដោយការលះបង់
ដែលមានចំណង់ប្រកបដោយឆន្ទៈ។

*អ្នកជ្រៀតគេរមែងតែងជ្រុញ
បានត្រឹមរុញខ្លួនមិនដួចគេ។

*អ្នកញុះញង់ឲ្យគេជឿពួកែ
អ្នកជឿតាមដែរគឺមនុស្សល្ងង់។

*អ្នកដទៃធ្វើអ្វីគ្មានន័យកុំទោមនស្ស
ជួយកែកំហុសទើបជាមនុស្សប្រពៃ។

*អ្នកដទៃជួយបានម្តងម្យាម
គប្បីព្យាយាមជួយខ្លួនឯង។

*អ្នកដទៃអាចជួយយើងបាន
ទាល់តែសន្តានខ្លួនឯងប្រពៃ។

*អ្នកដឹកនាំ
កុំគ្រាន់តែជាអ្នកនាំពាក្យ។

*អ្នកដឹកនាំកុំគិតតែពីងគេ
ត្រូវចលនាគេបានជាជំនួយ។

*អ្នកដឹកនាំកុំជាមនុស្សអាយ៉ង
ច្នៃប្រតិដ្ឋផងទើបបំណងសម្រេច។

*អ្នកដឹកនាំកុំត្រចៀកស
ស្តាប់ហើយបន្តរកហេតុផល។

*អ្នកដឹកនាំគិតធ្វើដោយប្រមាទ
នាំឲ្យខូចខាតប្រយោជន៍សង្គម។

*អ្នកដឹកនាំគាំពារកូនចៅ
ដូចសត្វម្រឹគញីបំបៅកូន។

*អ្នកដឹកនាំគ្មានការលះបង់
កំពុងបាត់បង់នូវអំណាច។

*អ្នកដឹកនាំចង្អៀតចង្អល់
តែងមិនបានផលគាប់ប្រសើរ។

*អ្នកដឹកនាំចេះត្រឹមឆ្លើយដាក់គ្នា
លទ្ធផលការងារគ្មានផ្លូវទៅមុខ។

*អ្នកដឹកនាំចេះត្រឹមពាក្យដោះសា
សម្តីរាយការណ៍ខុសមកពីគេ។

*អ្នកដឹកនាំជាកត្តាចលករ
ធ្វើគំរូល្អទើបអង្គភាពរឹងមាំ។

*អ្នកដឹកនាំដែលសម្តែងឫក
ដូចសត្វម្រឹគនៅព្រៃតែឯង។

*អ្នកដឹកនាំដាក់ខ្លួនឲ្យទាប
ទើបរបៀបស្គាល់បញ្ហាជ្រៅ។

*អ្នកដឹកនាំដែលគ្មានការលះបង់
កុំស្រមៃចង់ទៅអភិវឌ្ឍ។

*អ្នកដឹកនាំចេះបង្កើតគំនិតថ្មី
មានបញ្ញាស្មារតីចេះច្នៃប្រតិដ្ឋ
ចេះចលនាមិត្តរួមរស់ដោយឧត្តម។

*អ្នកដឹកនាំត្រូវដាក់ខ្លួនឲ្យទាប
ដកកឲ្យខ្ពស់ទស្សនៈវែងឆ្ងាយ។

*អ្នកដឹកនាំធ្វើត្រូវតាមស្ថានការណ៍
បុគ្គលិកស្តីថាត្រូវតែស៊ូទ្រាំ។

*អ្នកដឹកនាំប្រកាន់ឫកធំជាងមាឌ
ឫកគ្មានមារយាទនាំឲ្យជាតិលិចលង់។

*អ្នកដឹកនាំពិត
ត្រូវមានគំនិតច្នៃប្រតិដ្ឋជាប្រចាំ។

*អ្នកដឹកនាំមានគំនិតចលករ
អាក្រក់ឬល្អផ្អែកលើលទ្ធផល។

*អ្នកដឹកនាំមានន្ទូវគំនិត
ទើបនាំឲ្យគិតមានជំនួយ។

*អ្នកដឹកនាំមានគំនិត
ទើបមានពិតអ្នកមកជួយ។

*អ្នកដឹកនាំមានចិត្តលម្អៀង
ដូចជាភ្លៀងកណ្តាលថ្ងៃក្តៅ។

*អ្នកដឹកនាំមានសីលប្រាំមួយ
មានតម្លៃជួយអ្នកដឹកនាំ។

*អ្នកដឹកនាំមិនសំខាន់នៅត្រឹមចេះតែថា
ធ្វើឲ្យមហាជនមានប្រយោជន៍ទើបប្រពៃ។

*អ្នកដឹកនាំល្ងង់ប្រើអំណាច
អ្នកដឹកនាំឆ្លាតប្រើបញ្ញា។

*អ្នកដឹកនាំមានលុយតែខ្វះមារយាទ
ទោះបីខំឆ្លៀតជួយក៏គ្មានតម្លៃ។

*អ្នកដឹកនាំមិនគប្បីមានសកម្មភាព
ត្រឹមតែជាអ្នកនាំពាក្យឡើយ។

*អ្នកដឹកនាំមិនគប្បីក្លាយជាអ្នកនាំពាក្យ
ដោយគ្មានភាពជាអ្នកដឹកនាំ។

*អ្នកដឹកនាំមិនស្គាល់ខ្លួនឯង
គឺគ្មានកន្លែងដឹងខ្លួនខុស។

*អ្នកដឹកនាំអង្គភាពអាត្មានិយម
មិនអាចសង្គមសុខដុមចម្រើន។

*អ្នកដឹកនាំអប់រំបុគ្គលិកដើរផ្លូវត្រូវបាន
ទើបភាពថ្កើងថ្កានសន្ដានអង្គភាពមានជានិរន្ដរ៍។

*អ្នកដឹកនាំអាត្មានិយម
មិនអាចសង្គមធ្កើកម្លាំង។

*អ្នកដឹងថាខ្លួនឯងល្ងង់
ត្រូវខំប្រឹងរកចំណេះ។

*អ្នកដែលចាត់ទុកថាចេះប្រាកដ
យល់ដឹងហួត់ចត់ហេតុផលត្រឹមត្រូវ។

*អ្នកដែលចេះគោរពពេលវេលា
ទើបមានឈ្មោះជាគោរពខ្លួនឯង។

*អ្នកដែលចេះរៀនគ្មានទីបញ្ចប់
អ្នកដែលប្រសប់មិនគ្រប់ជ្រុងជ្រោយ។

*អ្នកដែលចេះស្តាយនូវពេលវេលា
គឺអាចចាត់ជាព្យាយាមប្រាកដ។

*អ្នកដែលឆ្លាតមិនប្រាកដថាមិនធ្លាប់ល្ងង់
អ្នកដែលស្មោះត្រង់មិនប្រាកដថាមិនក្បត់។

*អ្នកដែលជឿតាមការញុះញង់
គឺជាភាពល្ងង់នៃខ្លួនឯង។

*អ្នកដែលជោគជ័យ
ព្រោះតែអាស្រ័យគោរពវេលា។

*អ្នកដែលទុកថាអាក្រក់បំផុត
ធ្វើល្អនឹងមុខពុតក្បត់ពីក្រោយ។

*អ្នកដែលទៅផ្សារ
បើមិនពិចារណាអាចថវិកាក្លាយជាសំរាម។

*អ្នកដែលធ្វើល្អបានត្រឹមរួចខ្លួន
អ្នកចាំរុកក្ខួនបានឡើងបុណ្យស័ក្តិ។

*អ្នកដែលមានចិត្តក្តៅឥស្សាច្រណែន
ចិត្តផ្សាឈឺសែនព្រោះអ្នកផ្សេងជោគជ័យ។

*អ្នកដែលមានតែមិនទៀងថាមាន
ឯរូបវិញ្ញាណទៀងតែរលត់។

*អ្នកដែលមានទម្លាប់ពឹងតែគេ
គ្មានតម្លៃទេសម្រាប់ខ្លួនឯង។

*អ្នកដែលមានសន្តានចិត្តល្អឬអាក្រក់
អាចយកកញ្ចក់មារយាទឆ្លុះពីការងារ។

*អ្នកដែលមិនទទួលស្គាល់ការពិត
ធ្វើឲ្យជីវិតជួបបរាជ័យ។

*អ្នកដែលមិនមានចំណេះដឹង
គឺគ្មានលំនឹងក្នុងកិច្ចការ។

*អ្នកដែលរៀនចេះពិត
តែងមានគំនិតច្នៃប្រតិដ្ឋជាប្រចាំ។

*អ្នកដែលរិះគន់គេថាអួត
កំពុងតែបង្ហូតខ្លួនឯងឲ្យប្រសើរ។

*អ្នកដែលលក់របស់
បើមិនគិតសោះប្រាក់ក្លាយជាសំរាម។

*អ្នកដែលលួងព្រោះតែការប្រមាទ
អ្នកដែលឆ្លាតមិនប្រមាទទើបជោគជ័យ។

*អ្នកដែលវៃឆ្លាត
មកពីសង្វាត រៀនមើលគិតស្តាប់។

*អ្នកដែលឧស្សាហ៍ព្យាយាម
ទើបរាប់ថាមានជោគវាសនា។

*អ្នកដាំពូជខ្មៅដំបៅគំនិត
នាំឲ្យជីវិតចិត្តរីករាលដាល។

*អ្នកតូចនិងធំសុទ្ធតែបម្រើរាជការ
គួរពិចារណាកុំហិង្សាបំពានសិទ្ធិ។

*អ្នកត្រូវចេះខ្មាសខ្លួនឯង
អំពើដែលតែងតែធ្វើខុស។

*អ្នកថាគេលួង
ខ្លួនឯងក៏គង់ មិនចេះប្រាកដ។

*អ្នកធ្វើខុសចេះកែកំហុស
គឺជាមនុស្សដែលជោគជ័យ។

*អ្នកធ្វើខុសមិនទទួលកំហុស
គឺជាមនុស្សដែលបរាជ័យ។

*អ្នកធ្វើខុសមិនទទួលកំហុស
ច្រើនតែប្រទូស្តនឹងអ្នកដទៃ។

*អ្នកធ្វើខុសមិនសារភាពកំហុស
ធ្វើឲ្យអ្នកនោះធ្លាក់ក្នុងរណ្តៅ។

*អ្នកធ្វើខុសហើយដោះសារ
គឺអ្នកអាត្មានិយម។

*អ្នកធ្វើគុណកុំរង់ចាំគេសង
អ្នកដែលតបស្នងគួរកុំបំភ្លេច។

*អ្នកធ្វើច្រើនបង្កើនន្ទូវកំហុស
អ្នកមិនធ្វើសោះខុសក៏ធំដែរ។

*អ្នកធ្វើតែងជួបឧបសគ្គ
ធ្វើឲ្យប្រត្យក្សជោគកន្លង។

*អ្នកធ្វើតែងមានត្រូវនិងខុស
គឺការសន្តោសប្រកបដោយសីល។

*អ្នកធ្វើបុណ្យច្រើនបង្កប់បាប
ព្រោះមិនឆ្លាតដោយមិនស្គាល់បុណ្យ។

*អ្នកធ្វើបុណ្យមានច្រើនអនេក
ប៉ុន្តែចម្លែកក្រចិត្តបុណ្យ។

*អ្នកធ្វើបុណ្យមិនស្គាល់បុណ្យ
បានចំណេញតែខាងបាប។

*អ្នកធ្វើពិបាកតម្រូវចិត្តអ្នកថា
ប៉ុន្តែយ៉ាងណាខ្លះក៏ជាប្រយោជន៍។

*អ្នកធ្វើរមែងមានត្រូវខុស
អ្នកមិនធ្វើសោះបានអ្វីត្រូវ។

*អ្នកធ្វើល្អគេមិនយល់តែងរងគ្រោះ
អ្នកចាំប្រទូស្តមានលាភយសសក្តា។

*អ្នកធំចេះស្តាប់សម្តីអ្នកតូច
ជាផលប្រយោជន៍ដល់ការដឹកនាំ។

*អ្នកធំត្រូវចេះប្រមូលផ្តុំ
ឲ្យគេបានធំទាំងអស់គ្នា។

*អ្នកនៅឆ្ងាយក្លាយជាជិត
ព្រោះស្វែងរៀនពិតគំនិតអ្នកឆ្ងាយ។

*អ្នកនៅជិតប្រៀបដូចជាឆ្ងាយ
ដោយចិត្តមាក់ងាយមើលរំលង។

*អ្នកបួសឈ្លោះព្រោះដណ្តើមលាភ
នាំឲ្យថោកទាបដល់សាសនា។

*អ្នកបើកបរខាកស្តោះចោលតាមផ្លូវ
នាំឲ្យអាស្រូវដល់ពួជសន្តាន។

*អ្នកបើកបរធឹកជក់តាមផ្លូវ
ចោលកេរ្តិ៍អាស្រូវសម្រាប់អ្នកចរ។

*អ្នកបំផ្លាញធម្មជាតិ
កំពុងតែរៀបខ្លួនឲ្យវិនាស។

*អ្នកបំផ្លាញធម្មជាតិ
ប្រៀបដូចបំផ្លាញខ្លួនឯង។

*អ្នកបំផ្លិចបំផ្លាញបរិស្ថាន
ឃ្យូរឆាប់គង់បានវិនាសអាត្មា។

*អ្នកប្រាជ្ញប្រឹងប្រែងស្វែងរកវិជ្ជា
គួរគិតថាជាមិនចាស់មិនស្លាប់។

*អ្នកប្រាជ្ញព្រោកព្រុស
មាត់បែកពពុះខ្ចកិត្តិយសព្រោះខ្លួនមិនប្រែ។

*អ្នកប្រើសារជាតិគីមីក្នុងអាហារ
ជាឃាតកទីផ្សារនៃអ្នកប្រើប្រាស់។

*អ្នកប្រៀបព្រលឹងជាតិនឹងសុរា
បង្ខូចសាវតាខ្មែរអ្នកប្រមឹក។

*អ្នកផលិតស្រាបានជាប្រយោជន៍
ដល់កេរ្តិ៍អសោចសម្រាប់អ្នកផឹក។

*អ្នកពូកែមិនដែលចេះបានប្រាកដ
អ្នកដែលប្រសប់មិនដែលគ្រប់ជ្រុងជ្រោយ។

*អ្នកពូកែថាមិនប្រាកដធ្វើអ្វីកើត
ព្រោះពីកំណើតរៀនបានត្រឹមតែចេះថា។

*អ្នកពូកែអត់ធ្មត់
តែងបានសម្រេចនូវភាពជោគជ័យ។

*អ្នកព្យាយាមរៀនកើនចំណេះ
អ្នកកម្ចិលផេះគ្មានបញ្ញា។

*អ្នកព្យាយាមរៀនគំនិតកាន់តែក្មេង
អ្នកប្រមាទតែងគំនិតកាន់តែចាស់។

*អ្នកព្រោកប្រាជ្ញនៅកណ្តាលខ្លៅ
ប្រៀបដូចជាស្មៅលើដីខ្សាច់។

*អ្នកមានកង់តម្លៃថោកចរិតថ្លៃ
ជាងមានឡានថ្លៃតម្លៃចរិតថោក។

*អ្នកមានកិត្តិយសមិនប្រាកដមានតម្លៃ
សកម្មភាពថ្លៃទើបតម្លៃបង្កើតយស។

*អ្នកមានគួររៀនកុំភ្លេចកំណើត
ប្រភពដែលកើតឱកាសផ្តើមមាន។

*អ្នកមានគំនិតខាងត្រួតត្រា
តែងប្រើហិង្សាខ្លះមិនខាន។

*អ្នកមានគំនិតខាងត្រួតត្រា
តែងប្រើហិង្សាជាប្រចាំ។

*អ្នកមានគំនិតមិនប៉ិនប្រសប់
ព្រោះគ្មានទម្លាប់ក្នុងការស្រាវជ្រាវ។

*អ្នកមានគំនិតត្រឹមតែចេះសុំ
ការគិតនៅផ្តុំជាស្ងួមយាចក។

*អ្នកមានគំនិតបញ្ចៀសបញ្ហា
ជាងមានបញ្ហាយកមកដោះស្រាយ។

*អ្នកមានគំនិតមិនប្រកបញ្ញាណ
គឺគំនិតមានតែគ្មានបញ្ញា។

*អ្នកមានគ្មានគុណធម៌
រងគ្រោះបន្តដល់ជនទន់ទាប។

*អ្នកមានចរិតមានះដោយចិត្តអន្ទះសា
តែងប៉ងប្រាថ្នាធ្វើកិច្ចការមិនសូវសម្រេច។

*អ្នកមានចរិតឡេមឡឺមលុតក្រាប
មិនចេះខ្ជបខ្ជាចអ្នកដែលទន់ខ្សោយ។

*អ្នកមានចិត្តទូលាយព្រោះសន្តានល្ហ
អ្នកខ្ជះខ្ជាយក្រងាយឲ្យសន្តានខ្សត់។

*អ្នកមានចំណេះពិតប្រាកដ
ប្លែរតិរិយាបថបានប្រសើរ។

*អ្នកមានចំណេះមែនពិត
តែប្រយ័ត្នចរិតអន់។

*អ្នកមានជំនឿដែលគ្មានហេតុផល
ពិតជាបានដល់នូវក្តីវិនាស។

*អ្នកមានជំនាញត្រូវប្រយ័ត្ន
ក្រែងលោភ្លាត់បាត់ឱ្យបរា។

*អ្នកមានប្រើរបស់ល្អ
អ្នកក្រប្រើរបស់ចាំបាច់។

*អ្នកមានទម្លាប់ប្រមាទជេរ
គ្មានសីលធម៌ទេភាពជាមនុស្ស។

*អ្នកមានបញ្ហាមិនដែលដោះស្រាយ
បៀមភាពសោកស្តាយសម្រាប់ជីវិត។

*អ្នកមានបុណ្យសក្តិធំ
គួរចេះសន្សំភាពសុខដុមដល់សន្តាន។

*អ្នកមានប្រាក់កាក់ទិញទ្រព្យរបស់
មិនបានប្រើសោះប្រាក់ជាសំរាម។

*អ្នកមានមិនប្រាកដថាមិនក្រ
អ្នកល្អមិនប្រាកដថាមិនអាក្រក់។

*អ្នកមានមិនអាចមានប្រាកដ
អ្នកខ្សត់មិនប្រាកដថាគ្មាន។

*អ្នកមិនចេះមិនប្រាកដថាល្ងង់
ប្រាជ្ញខ្លះក៏គង់ល្ងង់ត្រង់មិនដឹង។

*អ្នកមិនចេះឲ្យតម្លៃទៅគេ
ព្រោះតែខ្លាចគេគ្រាន់បើជាងឯង។

*អ្នកមិនដែលធ្វើកុំតាំងខ្លួនគ្រាន់
ត្រូវចេះរៀនឃ្លាំចាំត្រាប់អ្នកធ្វើ។

*អ្នកមិនទទួលស្គាល់ភាពត្រឹមត្រូវ
សតិសត្រូវនឹងសច្ចធម៌។

*អ្នកមិនស្តាប់គេព្រោះគ្នេរមិនដល់អញ
គំនិតគេចាញ់មិនដូចអញគិតឡើយ។

*អ្នករក្សាសីលចរិតមានន
មិនដែលបានឈ្នះចិត្តខ្លួនឯងឡើយ។

*អ្នករស់ក្នុងភូមិនាំអ្នកផងរងទុក្ខ
រស់ឧបទ្រពរត់ចាកស្រុកទើបសុខកាយ។

*អ្នករស់ក្នុងសង្គម
ត្រូវជួយពួនជ្រុំទើបសង្គមរុងរឿង។

*អ្នកនិះគន់គេថាមានអំនួត
ព្រោះគ្មានអ្វីអួតមកបង្ហាញគេ។

*អ្នកនិះគន់ថាគេមានអំនួត
កំពុងតែអួតអំនួតខ្លួនឯង។

*អ្នករុញគេឲ្យព្យាយាមរៀន
តែងតែគ្រាំក្រៀមពាក្យប្រហារ។

*អ្នករៀនដែលចេះពិត
គឺគ្មានគំនិតលួចចម្លង។

*អ្នករៀនពីកំហុស
ដូចកញ្ចក់ឆ្លុះមើលខ្លួនឯង។

*អ្នករៀនសូត្រតែងមានវិធី
អ្នកសំភីតែងមានគំនិត។

*អ្នកលក់អាហារកុំគិតតែចំណេញ
ត្រូវជួយគិតវិញសុខភាពអ្នកពិសា។

*អ្នកលក់អាហារគិតត្រូវចំណេញ
បើគិតខុសវិញស្លាប់អ្នកពិសា។

*អ្នកលើកស្នួយឲ្យគេមានតម្លៃ
ជាបុណ្យពេកក្រៃកម្រនឹងរក។

*អ្នកល្ងង់ព្យាយាមគង់ចេះ
មិនខំប្រឹងចេះលិតល្ងង់។

*អ្នកល្ងង់លង់នឹងសម្តី
ព្រោកប្រាជ្ញឥតន័យបង់នូវកិរិយា។

*អ្នកល្ងង់លង់នឹងសម្តី
ព្រោកប្រាជ្ញឥតន័យបង់យសអាត្មា។

*អ្នកល្ងង់ធ្វើចេះនាំប្រទេសលិចលង់
អ្នកចេះធ្វើល្ងង់នាំសង្គមអន់ថយ។

*អ្នកល្អមិនមែនធ្វើអ្វីមិនដែលខុស
បើមានកំហុសចេះកែពិតជាល្អ។

*អ្នកល្អរគង់តែនឹងធ្វើខុស
អ្នកខុសចេះកែមានដោយក្រ។

*អ្នកស័ក្តិតូចធំសុទ្ធតែរាជការ
គួរប្រើសិទ្ធិណាតាមក្រមប្រតិបត្តិ។

*អ្នកសាមគ្គីគំនិតទូលាយ
លះបង់ចិត្តកាយអធ្យាស្រ័យល្អ។

*អ្នកសីលតែឈ្មោះ
ចិត្តក្តៅគុំឈ្លោះប្រទូស្តរាលខឹង។

*អ្នករៀនសូត្រពឹងចំណេះ
អាចារ្យតែថេះពឹងរោហរ។

*អ្នកស្គាល់ច្បាប់បុណ្យ
ត្រូវជួយធ្វើមុន ទុកជាគំរូ។

*អ្នកស្គាល់ប្រភពនៃភាពជោគជ័យ
ទើបជាអត្ថន័យតម្លៃជីវិត។

*អ្នកស្តាប់ដើម្បីគ្រាន់តែបានស្តាប់
មិនជាលំដាប់សម្រាប់អ្នកចេះ។

*អ្នកស្តាប់ហើយអាចដឹងយល់
ទើបបានដល់ជាអ្នកចេះ។

*អ្នកស្លាប់ដោយប្រព័ន្ធក្នុងខ្លួនឈប់ដើរ
សេដ្ឋកិច្ចប្រសើរដោយចំណេះដឹងខ្ពស់។

*អ្នកស្លប់ព្រោះតែមានសេចក្តីសុខពីអ្នកជួយ
ជាងផ្តែមរលួយផ្តល់ទុក្ខព្រួយដល់អ្នកស្រឡាញ់។

*អ្នកអប់រំគ្មានគំនិតគ្រប់គ្រាន់
វិវឌ្ឍន៍មិនទាន់សង្គមប្រែប្រួល។

*អ្នកហ៊ានប្រាប់ហ៊ានតែជាញាតិដ៏កម្រ
អ្នកទូន្មានល្អកម្រពាលរាប់ជាមិត្ត។

*អ្វីដែលពិបាកត្រង់ដែលមិនដឹង
បើព្យាយាមប្រឹងដឹងមិនលំបាក។

*អ្វីដែលមានត្រូវនាំគ្នារក្សាថែ
កុំបានខ្ជាងតែមានទ្រព្យប្រើខ្ជះខ្ជាយ។

*អ្វីដែលមានគួរនាំគ្នារក្សាថែ
កុំបានពូកែសុំតែប្រើខ្ជះខ្ជាយ។

*អ្វីទៅដែលហៅថាចិត្តបុណ្យ
គឺចិត្តអត់ធន់ជួយមនុស្សសត្វ។

*អ្វីទៅដែលហៅថាចិត្តអកុសល
នោះគឺបានដល់ចិត្តដែលគ្មានមេត្តា។

*អ្វីៗដែលមានត្រូវរៀនចេះសន្សំប្រើ
កុំប៉ានគ្រាន់បើពូកែសុំមិនរក្សា។

*អ្វីៗអាចទិញបាន
សុខភាពគ្រប់ប្រាណទិញមិនបានឡើយ។

*អ្វីៗមានមាសប្រាក់អាចទិញបាន
សុខភាពខ្លួនប្រាណទិញមិនបានឡើយណា។